Australian Aid

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Published by:
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

In cooperation with:



# មិនទុកចោលនរណាម្នាក់៖ ការយល់ដឹងអំពីប្រព័ន្ធកំណត់អត្តសញ្ញាណភាពក្រីក្រជាតិនៅកម្ពុជា

ការបោះពុម្ពផ្សាយនៅក្នុងឯកសារសមូហកម្មរបស់អាល្លឺម៉ង់ស្តីពីការអនុវត្តផ្នែកសុខភាព

WWW health.bmz.de/ghpc

@HealthyDEvs

fb.com/HealthyDEvs

More information about the German Health Practice Collection can be obtained by contacting the Managing Editor at ghpc@giz.de or by visiting the Collection's homepage (health.bmz.de/ghpc) where all case studies, as well as related materials, are available for download.

## ឯកសារសម្ភូហកម្មរបស់អាល្លឺម៉ង់ស្ដីពីការអនុវត្តផ្នែកសុខភាព

*ធ្វើការជាមួយគ្នាដើម្បីបង្កើត និងចែករំលែកការរៀនសូត្រ*

ឯកសារសម្ភូហកម្មរបស់អាល្លឺម៉ង់ស្ដីពីការអនុវត្តន៍ផ្នែកសុខភាព (GHPC) គឺជាការផ្តួចផ្តើមរួមគ្នាមួយរបស់ក្រសួងសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ចនៃសហព័ន្ធអាល្លឺម៉ង់ (BMZ) និងទីភ្នាក់ងារអនុវត្តន៍របស់អាល្លឺម៉ង់ មានជាអាទិ៍ Deutsche Gesellschaft fur Internationale Zusammenarbeit (GIZ) GmbH និងធនាគារអភិវឌ្ឍន៍ KfW Development Bank (KfW) ត្រូវបានគេស្គាល់រួមគ្នាថាជាសហប្រតិបត្តិការអភិវឌ្ឍន៍អាល្លឺម៉ង់ (GDC) ។ ចាប់តាំងពីឆ្នាំ 2004 មក ឯកសារសម្ភូហកម្មនេះមានទំនាក់ទំនងជាមួយអ្នកឯកទេសនានាដែលធ្វើការក្នុងកម្មវិធីគាំពារសុខភាព និង គាំពារសង្គមដែលគាំទ្រដោយអាល្លឺម៉ង់ក្នុងដំណើរការគ្រប់គ្រងចំណេះដឹងរួមគ្នាដើម្បីស្វែងរកការកំណត់អត្តសញ្ញាណ ចងក្រងឯកសារ និងចែករំលែកចំណេះដឹងដែលបានបង្កើតក្នុងកំឡុងពេលអនុវត្តកម្មវិធីនៅជុំវិញពិភពលោក។

*ពី " ការអនុវត្តបានល្អ " ទៅកាន់ការរៀនសូត្រពីការអនុវត្ត*

នៅឆ្នាំ២០១៥ ឯកសារសម្ភូហកម្មបានបង្វែរការផ្ដោតការយកចិត្តទុកដាក់របស់ខ្លួនពីការព្យាយាមចាប់យក " ការអនុវត្តន៍ល្អ " ឆ្ពោះទៅរកការបង្កើតចំណេះដឹងថ្មីអំពីការផ្ដល់អន្តរាគមន៍លើកិច្ចអភិវឌ្ឍន៍។ នាំមុខដោយសំណួរសំខាន់ៗចំនួន 2-3 ករណីសិក្សានីមួយៗក្នុងឯកសារនេះវិភាគអំពីរបៀបដែលកម្មវិធីអាល្លឺម៉ង់ និងស្ថាប័នដៃគូ បានឈានដល់ការប្រឈមមុខនឹងការអភិវឌ្ឍន៍ជាក់លាក់ វិធីដែលអាល្លឺម៉ង់បានដោះស្រាយការលំបាក និងសម្របវិធីសាស្ត្ររបស់ពួកគេទៅតាមនោះ និងទៅតាមអ្វីដែលពួកគេបានរៀនសូត្រក្នុងដំណើរការអនុវត្តប្រកបដោយប្រសិទ្ធភាព។

*ការបង្កើតភាពជាម្ចាស់តាមរយៈដំណើរការសហការ*

ចាប់តាំងពីការបង្កើតឡើងជាងមួយទសវត្សកន្លងមកនេះ ឯកសារសម្ភូហកម្មនេះបានជួយជំរុញដល់សហគ មន៍អនុវត្តន៍ការងារក្នុងចំណោមអ្នកជំនាញផ្នែកសុខភាព និងអ្នកជំនាញផ្នែកគាំពារសង្គម តាមរយៈការដាក់បញ្ជូល និងការជ្រើសរើសដោយមានការចូលរួម និងដំណើរការផលិតកម្មរបស់គេ។

ជារៀងរាល់ឆ្នាំបុគ្គលិក GIZ និង KfW មកពីជុំវិញពិភពលោកត្រូវបានអញ្ជើញ រួមជាមួយអង្គការដៃគូរបស់ពួកគេ ដើម្បីដាក់ និងពិភាក្សារួមគ្នានូវសំណើគម្រោងបទពិសោធន៍ដែលពួកគេជឿថាគួរតែត្រូវបានចងក្រងជាឯកសារលម្អិតបាន។ តាមរយៈការចូលរួមយ៉ាងសកម្មរបស់ពួកគេក្នុងដំណើរការជ្រើសរើស ពួកគេជួយប្រែក្លាយឯកសារសម្ភូហកម្មនេះទៅជាការបង្កើតរួមគ្នាដែលករណីសិក្សារបស់ពួកគេឆ្លុះបញ្ចាំងពីបញ្ហាប្រឈម និង ប្រធានបទនានាដែលសហគមន៍ផ្ដល់តម្លៃ។

ដោយមានការចង្អុលបង្ហាញពីការវាយតម្លៃអំពីគុណសម្បត្តិនៃសំណើគម្រោងទាំងនេះ BMZ សម្រេចចិត្តថាតើគម្រោងស្នើមួយណាដែលត្រូវចងក្រងជាឯកសារ។ អ្នកនិពន្ធវិជ្ជាជីវៈត្រូវបានចុះកិច្ចសន្យា ដើម្បីបង្កើតករណីសិក្សានានាដោយសហការជាមួយបុគ្គលិកកម្មវិធី និងស្ថាប័នដៃគូរបស់ពួកគេ។ មុនពេលបោះពុម្ពផ្សាយ អ្នកត្រួតពិនិត្យឯករាជ្យដែលជាអ្នកជំនាញអន្តរជាតិក្នុងវិស័យរបស់ខ្លួន ធ្វើការពិនិត្យឡើងវិញនូវករណីសិក្សាទាំងនោះ និងផ្តល់យោបល់លើគោលគំនិតថ្មីដែលត្រូវបានបង្កើតឡើង។

*រូបថតនៅលើក្របខាងមុខ៖ អ្នកស្រី សម គន្ធា អាយុ៣៨ឆ្នាំ រកចំណូលបានត្រឹមតែជាង 2 € (អឺរ៉ូ) ក្នុងមួយថ្ងៃពីការប្រមូលសម្រាមដែលអាចកែច្នៃឡើងវិញនៅរាជធានីភ្នំពេញ។ នាពេលថ្មីៗនេះ គាត់ត្រូវបានកំណត់អត្តសញ្ញាណថាជាគ្រួសារក្រីក្រ ដោយកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្របានពង្រីកទៅកាន់ទីប្រជុំជន។*

# មាតិកា




ខ្លឹមសារសង្ខេប 04
ការណែនាំអំពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ, ខ្សែជីវិតសម្រាប់ជនក្រីក្រ 06
ពាក្យពេចន៍ខ្លះៗអំពីភាពក្រីក្រ និងអត្តសញ្ញាណកម្មជនក្រីក្រ 08
ភាពក្រីក្រ ការកាត់បន្ថយភាពក្រីក្រ និងការកំណត់ភាពក្រីក្រនៅកម្ពុជា 10
ការវិវត្តរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជាផ្នែកមួយនៃការឆ្លើយតបចំពោះភាពក្រីក្ររបស់កម្ពុជា 12
វដ្តនៃជំហានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ 14
បញ្ហាប្រឈម និង ការសម្របខ្លួន 19
សមិទ្ធផលរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ 29
គោលគំនិតសំខាន់ៗ 33
ការពិនិត្យឡើងវិញដោយអ្នកជំនាញ 35
សេចក្តីថ្លែងអំណរគុណ 37
ឯកសារយោង 38


## អក្សរកាត់និងពាក្យបំព្រួញ

| | |
|---|---|
| API | Application Programme Interface<br>សម្ព័ន្ធផ្នែករឹងនៃកម្មវិធីកុំព្យូទ័រ |
| BMZ | Federal Ministry for Economic Cooperation and Development, Germany<br>ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ |
| CARD | Council for Agricultural and Rural Development<br>ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| DFAT | Department of Foreign Affairs and Trade, Australia<br>ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី |
| GDC | German Development Cooperation<br>កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាល្លឺម៉ង់ |
| GIZ | Deutsche Gesellschaft für Internationale Zusammenarbeit GmbH<br>សហគ្រាសសហព័ន្ធផ្តល់កិច្ចសហប្រតិបត្តិការអន្តរជាតិ/អង្គការ GIZ |
| HEF | Health Equity Fund<br>មូលនិធិសមធម៌សុខាភិបាល |
| IDPoor | Identification of Poor Households Programme<br>កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ |
| IIS | IDPoor Information System<br>ប្រព័ន្ធព័ត៌មានគ្រួសារក្រីក្រ |
| IT | Information technology<br>ព័ត៌មានវិទ្យា |
| KfW | KfW Development Bank<br>ធនាគារអភិវឌ្ឍន៍ KfW |
| NGO | Non-Governmental Organisation<br>អង្គការមិនមែនរដ្ឋាភិបាល |
| PRISM | Platform for Real-time Information Systems<br>ផ្លាតហ្វ៊មប្រព័ន្ធព័ត៌មានតាមពេលម៉ោងពិតជាក់ស្តែង |
| URC | University Research Co., LLC<br>សាកលវិទ្យាល័យស្រាវជ្រាវយូអរស៊ី , LLC |
| VRG | Village Representative Group<br>ក្រុមតំណាងភូមិ |

# ខ្លឹមសារសង្ខេប

## ប្រអប់១៖ មេរៀនសំខាន់ៗ

ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលមានវិសាលភាពក្នុងក្របខណ្ឌទូទាំងប្រទេស មានភាពត្រឹមត្រូវគ្រប់គ្រាន់ សហគមន៍ទទួលយក ហើយផ្តល់មូលនិធិទាំងស្រុងដោយរដ្ឋាភិបាល។ ការប្តេជ្ញាចិត្តផ្នែកនយោបាយ និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល  ទន្ទឹមនឹងការអនុវត្តមានប្រសិទ្ធភាព ការអនុវត្តដោយសហគមន៍នៅមូលដ្ឋាន បានអនុញ្ញាតិឲ្យកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅកម្ពុជា “ IDPoor ” ពង្រីកសកម្មភាព និងក្លាយទៅជាយន្តការកំណត់គោលដៅផ្លូវការរបស់ប្រទេសកម្ពុជាសម្រាប់កម្មវិធីនានាដែលគាំទ្រជនក្រីក្រ។

ដំណើរការមានតម្លាភាព ដឹកនាំដោយសហគមន៍ ផ្តល់តម្លៃសង្គម និងរក្សាភាពក្រីក្រឲ្យស្ថិតនៅក្នុងរង្វង់នយោបាយ។ ដំណើរការបើកចំហ កើតមានជារឿយៗដូច អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជម្រុញសហគមន៍នានាឲ្យនិយាយអំពីភាពក្រីក្រ ហើយធ្វើឲ្យអ្នករៀបចំគោលនយោបាយទទួលខុសត្រូវក្នុងការលើកកម្ពស់ស្ថានភាពជីវភាពរស់នៅរបស់ជនក្រីក្រ និងជនងាយរងគ្រោះ។

ដើម្បីកសាងទំនុកចិត្តលើទិន្នន័យដែលបានបង្កើត អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវរួមបញ្ចូល និងត្រូវមានតម្លាភាពជាមួយភាគីពាក់ព័ន្ធដែលមានបំណងប្រើប្រាស់ទិន្នន័យនោះ។ យន្តការត្រួតពិនិត្យនិងវាយតម្លៃរឹងមាំ និងវិធីផ្សព្វផ្សាយលទ្ធផលក៏មានសារៈសំខាន់ដូចការប្រមូល និងផ្តល់ទិន្នន័យដែលមានគុណភាពផងដែរ។ វេទិកាផ្តល់ព័ត៌មានត្រឡប់ ឬក្រុមផ្តល់យោបល់អាចជួយ ភ្ជាប់ទំនាក់ទំនងភាគីពាក់ព័ន្ធ និងកសាងទំនុកចិត្តលើទិន្នន័យដើម្បីប្រើប្រាស់សម្រាប់កំណត់គោលដៅ។

ការពន្លឿននិងបរិយាប័ន្ន មានទំនាក់ទំនងគ្នាស្អិតរមួតយន្តការកំណត់មុខសញ្ញា និងតម្រូវការមានតុល្យភាព។ គុណសម្បត្តិនៃលក្ខខណ្ឌ “ ភាពឆាប់រហ័ស និងឪជីថល ” មិនគួរជាតម្រូវការជាអាទិភាពខ្ពស់ជាងតម្លៃដែលមានលក្ខណ: “ បរិយាប័ន្ន និងការចូលរួម ” នោះទេ។ ជាទស្សនៈ គួររួមបញ្ចូលគ្នានៃលក្ខណៈទាំងពីរដើម្បីបង្កើនអត្ថប្រយោជន៍ និងកាត់បន្ថយកំហុស និងការចំណាយដោយអនុលោមតាមបណ្តាអាទិភាពរបស់រដ្ឋាភិបាល និងសហគមន៍។

ករណីសិក្សានេះ ពិពណ៌នាអំពីការវិវឌ្ឍន៍នៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅកម្ពុជា ដែលរហូតដល់បច្ចុប្បន្ននេះ មានអាយុកាលជាងមួយទសវត្សមកហើយ ភាពចាស់ទុំលើការងារ និងផ្តល់នូវការយល់ដឹងអំពីអត្តសញ្ញាណកម្មភាពក្រីក្រដែលមាននិរន្តរភាពនៅក្នុងប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។

## បញ្ហាប្រឈម

មានប្រជាជនកម្ពុជាប្រមាណជាម្នាក់ក្នុងចំណោមប្រាំនាក់ដែលរស់នៅក្នុងភាពក្រីក្រ។ តាមរយៈការវាស់ស្ទង់មួយចំនួនអំពីភាពក្រីក្រដែលមានលក្ខណៈពហុវិស័យ ប្រជាជនរហូតដល់ 50% នៃប្រជាជនទាំងអស់ជាប្រជាជនក្រីក្រ ឬជាប្រជាជនងាយរងគ្រោះក្នុងការក្លាយជាជនក្រីក្រ ខណៈដែលកម្ពុជាអនុវត្តសេរីភាវូបនីយកម្មទីផ្សារនៅចុងទសវត្ស ១៩៩០ បាននាំឱ្យមានកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ ប៉ុន្តែវាមិនបានផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជាគ្រប់រូបនោះទេ ហើយតម្លៃលើការប្រើប្រាស់សេវាសុខាភិបាល គឺហួសពីលទ្ធភាពរបស់ប្រជាពលរដ្ឋ។ តាមរយៈសកម្មភាពរបស់រាជរដ្ឋាភិបាល និងការគាំទ្រពីបរទេស កម្មវិធីគាំពារសង្គមជាច្រើនសម្រាប់ជនក្រីក្រត្រូវបានបង្កើតឡើង រួមទាំងការថែទាំសុខភាពឥតគិតថ្លៃ និងការផ្តល់អាហារូបករណ៍នៅតាមសាលារៀនផងដែរ។ ទោះជាយ៉ាងណាក្តី កម្មវិធី និងស្ថាប័នអនុវត្តនីមួយៗមានលក្ខណៈវិនិច្ឆ័យ និងដំណើរការរៀងៗខ្លួនក្នុងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ។ ករណីបែបនេះ គឺគ្មានប្រសិទ្ធភាព និងភាពច្បាស់លាស់ ហើយជារឿយៗអត្តសញ្ញាណកម្មគ្រួសារក្រីក្រមិនបានទៅដល់ជនងាយរងគ្រោះបំផុតឡើយ។

## ការឆ្លើយតប

រដ្ឋាភិបាលអាល្លឺម៉ង់តាមរយៈជីអាយហ្សិត GIZ បានផ្តល់ការគាំទ្រដល់ក្រសួងផែនការ ចាប់តាំងពីឆ្នាំ២០០៥ មកម្ល៉េះ ដើម្បីបង្កើត និងអនុវត្តយន្តការអត្តសញ្ញាណកម្មភាពក្រីក្រថមួយ ដែលជានីតិវិធីតែមួយគត់សម្រាប់កម្មវិធីផ្តោតលើជនក្រីក្រ។ កម្មវិធីដែលត្រូវបានបង្កើតឡើងហៅថា "អត្តសញ្ញាណកម្មគ្រួសារក្រីក្រ "ឬ "IDPoor " ដែលកាលពីដំបូងផ្តោតទៅកាន់តំបន់ជនបទដែលមានប្រជាជនកម្ពុជា៨០%រស់នៅ ហើយប្រើប្រាស់គំរូកូនកាត់មួយដោយច្របាច់បញ្ចូលគ្នានូវទិដ្ឋភាពជាក់ស្តែងនៃឧបករណ៍វាស់វែងពីកម្រិតជីវភាព(proxy means test) ជាមួយនឹងភាពត្រឹមត្រូវ និងលទ្ធភាពនៃដំណើរការជ្រើសរើសនៅតាមសហគមន៍។ ស្ថាប័នរបស់រដ្ឋាភិបាល និងអង្គការជាតិអន្តរជាតិដែលផ្តល់កម្មវិធីផ្តោតលើជនក្រីក្រ បានប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ ក្នុងការកំណត់គោលដៅអ្នកទទួលផលរបស់ពួកគេ បន្ទាប់ពីការសាកល្បងមួយនៅក្នុងឃុំចំនួនបួនក្នុងឆ្នាំ២០០៧ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្របានអនុវត្តអត្តសញ្ញាណគ្រួសារក្រីក្រ នៅខេត្តចំនួន៨ក្នុងមួយឆ្នាំ ដើម្បីឲ្យខេត្តទាំង២៤ នៅប្រទេសកម្ពុជាត្រូវបានគ្របដណ្តប់ក្នុងរយៈពេលបីឆ្នាំម្តង។

អត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានជួបប្រទះបញ្ហាប្រឈមមួយចំនួន ព្រមទាំងបានធ្វើការកែសម្រួលជាបន្តបន្ទាប់ដើម្បីកែលម្អការអនុវត្ត។ ក្រសួងផែនការបានកែលម្អការគាំទ្រ និងការតាមដានការអនុវត្តដើម្បីធានាឲ្យដំណើរការការងារតាមបានត្រឹមត្រូវ។ និយមន័យ និងការយល់ឃើញផ្សេងៗគ្នាអំពីភាពក្រីក្រ ដែលបានលើកជាសំណួរអំពីមូលហេតុដែលអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មិនបានកំណត់អត្តសញ្ញាណគ្រួសារមួយចំនួនដែលទំនងជាមានជីវភាពក្រីក្រ ដូច្នេះ ការ លើកកម្ពស់ការយល់ដឹងនៅមូលដ្ឋាន និងការពិភាក្សាជាមួយអ្នកប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ ក៏បានកែលម្អសមត្ថភាពគ្រប់គ្រង និងផ្សព្វផ្សាយទិន្នន័យព័ត៌មានរបស់ខ្លួន តាមរយៈលទ្ធភាពអាចទទួលទិន្នន័យគ្រួសារក្រីក្រមកប្រើប្រាស់ពីតាមអ៊ីនធឺណិត ដោយបន្ថែមលក្ខណៈពិសេសអំពីទំរង់ផែនទីនិងងាយស្រួលមើល និងពង្រីកកិច្ចសហប្រតិបត្តិការ និងការរាយការណ៍តាមតម្រូវការ។ ការអនុវត្តសាកល្បងមួយនៃបច្ចេកវិទ្យាចល័តមួយចំនួន ក៏កំពុងដំណើរការផងដែរ។ ក្រសួងផែនការបានរៀបចំនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅទីប្រជុំជន និងបាន ប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅចុងឆ្នាំ២០១៦។

ខណៈវដ្ត នៃការកំណត់និងធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រួសារក្រីក្រ រយៈពេលបីឆ្នាំកំពុងជាទីចាប់អារម្មណ៍ ធៀបនឹងអង្កេតភាពក្រីក្រនានានៅតំបន់ដូចគ្នា គ្រួសារដែលខកខានមិនបានធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្រីក្រនៅក្នុងភូមិរបស់ខ្លួន ចាំបាច់ត្រូវរង់ចាំរហូតដល់ជុំប្រមូលទិន្ន័យបន្ទាប់ ដើម្បីទទួលការវាយតម្លៃអំពីលទ្ធភាពទទួលបានប័ណ្ណសមធម៌។ ដោយមានប្រជាជនខ្មែរម្នាក់ក្នុងចំណោមបួននាក់ធ្វើចំណាកស្រុកទៅរកការងារធ្វើ ហើយមានគ្រួសារជាច្រើនដែលងាយធ្លាក់ចូលក្នុងភាពក្រីក្រ និងចាកផុតពីភាពក្រីក្រ អត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវការវិធីសាស្រ្តទូលំទូលាយមួយ ដើម្បីអនុញ្ញាតឱ្យគ្រួសារដាក់ពាក្យស្នើសុំធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅចន្លោះជុំនៃការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ យន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ កំពុងអនុវត្តសាកល្បងចាប់ផ្តើមនៅចុងឆ្នាំ២០១៧។

## សមិទ្ធផលដែលសម្រេចបាន

- អត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានគ្របដណ្តប់នៅទូទាំងប្រទេសៈ គិតត្រឹមឆ្នាំ២០១៣ ភូមិទីជនបទទាំងអស់ត្រូវបានគ្របដណ្តប់ ហើយនៅឆ្នាំ២០១៩ នឹងគ្របដណ្តប់ទាំងភូមិទីជនបទទាំងភូមិទីប្រជុំជន។

- អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានផ្តល់ថវិកាទាំងស្រុងដោយរាជរដ្ឋាភិបាលកម្ពុជាសម្រាប់ប្រតិបត្តិការទាំងអស់ដែលទាក់ទងទៅនឹងការអនុវត្តនៅជនបទ។ ការងារនេះត្រូវបានសម្រេចដោយកិច្ចព្រមព្រៀងដំបូងរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសហព័ន្ធអាល្លឺម៉ង់ និងក្រសួងការបរទេស និងពាណិជ្ជកម្មអូស្រ្តាលី(DFAT) តាមរយៈកិច្ចសន្យាដែលផ្ទេរការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុជាបណ្តើរៗដល់ក្រសួងផែនការ។

- អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ទទួលបានទំនុកចិត្ត និងតំណាងឲ្យទស្សនៈរបស់សហគមន៍អំពីភាពក្រីក្រ។ ក្នុងមួយឆ្នាំៗ អ្នកភូមិប្រហែល ១,៦លាននាក់ចូលរួមក្នុងការជ្រើសរើសក្រុមតំណាងភូមិ (VRG) របស់ខ្លួន ហើយ ៣៥.000 នាក់ ចូលរួមដោយផ្ទាល់ក្នុងដំណើរការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ដូចប្រធានក្រុមប្រឹក្សាឃុំម្នាក់និយាយថា " យើងមិនចង់ឱ្យអ្នកក្រៅចូលមកប្រាប់យើង ថានរណាក្រីក្រនោះទេ។ យើងស្គាល់គ្នាទៅវិញទៅមក ˝ ។

- រាជរដ្ឋាភិបាល និងដៃគូផ្តល់តម្លៃដល់ទិន្នន័យគ្រួសារក្រីក្រសម្រាប់ការធ្វើផែនការ និងការកំណត់គោលដៅនៃកម្មវិធីៈ ដៃគូកាន់តែច្រើនកំពុងប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រសម្រាប់ការកំណត់គោលដៅដែលកើនឡើងពី ៤២គម្រោងក្នុងឆ្នាំ២០១២ ដល់ ១៣៦គម្រោងនៅឆ្នាំ ២០១៥ ឬ ៦៣%នៃកម្មវិធីអភិវឌ្ឍន៍ទាំងអស់ដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា។ ឯកឧត្តម ឆាយថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ចាត់ទុកថានេះគឺជាការសូចនាករមួយនៃភាពជោគជ័យរបស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រៈ " នៅពេលដែលដៃគូកាន់តែច្រើនប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រសម្រាប់ការកំណត់គោលដៅរបស់ពួកគេ អន្តរាគមន៍កាន់តែច្រើននឹងទៅដល់អ្នកដែលត្រូវការអន្តរាគមន៍ទាំងនោះ " ។

# ការណែនាំអំពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ, ខ្សែជីវិតសម្រាប់ជនក្រីក្រ

អ្នកស្រី យ៉ែម សោភ័ណ អង្គុយជាមួយកូនស្រីអាយុ២៥ឆ្នាំ ឈ្មោះ សុភ័ក្រ នៅក្បែរកូនតុតូចមួយ ក្រោមដើមត្នោតមួយដើម នៅជិតរោងឥតជញ្ជាំងដែលគេប្រើសម្រាប់ការជួបជុំគ្នាក្នុងភូមិ។ ស្ត្រីជាម្ដាយអាយុ៦៣ឆ្នាំ បានលាចង់ផ្លាស្ទិករហែកទក់មួយថ្នមៗ រួចទាញយកប័ណ្ណមួយដែលមានរូបថតគាត់ និងសុភ័ក្រ។ ថ្ងៃនេះ ពួកគាត់កំពុងរង់ចាំវេនដើម្បីថតរូបថ្មី។ គាត់ពន្យល់ថា ប័ណ្ណនេះជា ប័ណ្ណសមធម៌ ដែលផ្ដល់ឱ្យប្រជាជនកម្ពុជាក្រីក្រដូចរូបគាត់ឲ្យទទួលបាននូវការថែទាំសុខភាព និងទទួលបានអត្ថប្រយោជន៍ផ្សេងៗទៀតដោយឥតបង់ប្រាក់។

នៅពេលនាងនិយាយ អ្នកស្រី សោភ័ណ សម្លឹងមើលកូនស្រីរបស់គាត់ មិនដាក់ភ្នែកដែលកំពុងកាន់ប័ណ្ណសមធម៌ បិទបើកស្រោមផ្លាស្ទិក ហើយទាញអាវការ៉ូចម្រុះពណ៌ក្រហមលាយខៀវ។ អ្នកស្រី ចាប់ដៃ សុភ័ក្រ កុំឲ្យរើដោយគោះខ្នងកូនថ្នមៗ។ គាត់ប្រាប់ថាកូនស្រីរបស់គាត់ ឧស្សាហ៍ឈឺ។ កាលអាយុ៤ខែ សុភ័ក្រ គ្រុនក្ដៅ ដូច្នេះឪពុកម្ដាយនាងបាននាំនាងទៅមន្ទីរពេទ្យ ហើយពេទ្យប្រាប់ថានាងមានជំងឺរលាកស្រោមខួរ។

ពួកគាត់បាននាំនាងមកផ្ទះ ហើយយកនាងទៅរកគ្រូបុរាណម្នាក់ដែលពន្យល់គាត់ថាកូនស្រីគាត់មានជំងឺស្គន់ដាន់ ជាជំងឺមួយដែលកើតលើកូនក្មេងបណ្ដាលមកពីវិញ្ញាណព្រាយបិសាច។ អ្នកស្រី សោភ័ណ ពន្យល់ថា " ម្ដាយដើមរបស់ សុភ័ក្រ កាលពីជាតិមុនតាមយកនាងទៅវិញ " ប៉ុន្តែដោយសារតែខ្ញុំស្រលាញ់នាងខ្លាំងពេក ទើបខ្ញុំអាចធ្វើឲ្យនាងនៅរស់រានមានជីវិតបាន " ។

ឥឡូវសុភ័ក្រក្រធំ នាងមិននិយាយស្ដី ហើយពឹងអាស្រ័យលើម្ដាយនាង។ នាងនៅតែមានជំងឺគ្រុនក្ដៅជារឿយៗ ប៉ុន្តែចាប់តាំងពី កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានកំណត់គ្រួសាររបស់នាងថាជាគ្រួសារក្រីក្រ នាងអាចទទួលបានសេវាសុខភាពនៅពេលដែលនាងត្រូវការ។ កាលពីមុនអ្នកស្រី សោភ័ណ ដែលជាស្ត្រីមេម៉ាយ គាត់បានខ្ចីប្រាក់គេទុកបង់ថ្លៃមន្ទីរពេទ្យ។ គាត់លក់ខោអាវជជុះ ហើយជួនកាលគាត់អាចសុំបើកប្រាក់ជាមុនពីម៉ូយផ្គត់ផ្គង់ដែលទុកចិត្តគាត់ ពួកគេគិតថាគាត់នឹងសងពួកគេវិញនៅពេលដែលគាត់មានប្រាក់។



*ចំណងជើង៖ អ្នកស្រី យ៉ែម សោភ័ណ និងកូនស្រីរបស់គាត់បានរូបថតថ្មីមួយសម្រាប់ប័ណ្ណសមធម៌ ដែលអនុញ្ញាតឱ្យពួកគាត់ទទួលបានការថែទាំសុខភាពដោយឥតគិតថ្លៃ*

ប៉ុន្តែនៅពេលកូនស្រីរបស់នាងធ្លាក់ខ្លួនឈឺអ្នកស្រី សោភ័ណ មិនអាចធ្វើការបាន ហើយគាត់ពិបាកសងបំណុលកាន់តែខ្លាំង។ ការថែទាំសុខភាពដោយឥតគិតថ្លៃដែលអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ផ្តល់ឱ្យគ្រួសាររបស់គាត់ មានសារៈសំខាន់ណាស់។ អ្នកស្រីសោភ័ណ ពន្យល់ថា " ខ្ញុំធ្វើអ្វីដោយខ្លួនឯងពឹងលើរូបខ្ញុំផ្ទាល់ " ។ ប្រសិនបើកូនរបស់ខ្ញុំឈឺមួយសប្តាហ៍ ខ្ញុំនៅផ្ទះ។ ប្រសិនបើនាងមានសុខភាពល្អ ខ្ញុំសប្បាយចិត្ត ខ្ញុំអាចធ្វើការបាន "។

ដូចសមាជិកក្រុមថតរូបគ្រួសារក្រីក្រម្នាក់ទើបតែបានបញ្ចប់ការពន្យល់ទៅកាន់ក្រុមគ្រួសារទាំងឡាយ ដែលបានជួបជុំគ្នានៅក្នុងរោងសម្រាប់ជួបជុំគ្នាថតរូប ប័ណ្ណសមធម៌ ត្រូវបានហៅជាផ្លូវការថា ប័ណ្ណសមធម៌ដែលអនុញ្ញាតឱ្យអ្នកកាន់ប័ណ្ណ ទទួលបានការថែទាំសុខភាពដោយឥតគិតថ្លៃ ក៏ដូចជាទទួលបានឧបត្ថម្ភធនសម្រាប់ថ្លៃទឹក និងអគ្គីសនី អាហារូបករណ៍ សម្បទានដីសង្គមកិច្ច និងសេវាកម្មផ្សេងៗទៀត។ សព្វថ្ងៃនេះគ្រួសារប្រជាពលរដ្ឋកម្ពុជាប្រហែល ៥៧៥.០០០គ្រួសារ មានប័ណ្ណសមធម៌ដោយសារតែដំណើរការផ្តោតមុខសញ្ញាទៅកាន់សហគមន៍ដែលប្រព្រឹត្តទៅរៀងរាល់បីឆ្នាំម្តងនៅតាមខេត្តនីមួយៗ។

អត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាកម្មវិធីជាតិសម្រាប់អត្តសញ្ញាណគ្រួសារក្រីក្រនៅកម្ពុជា ដែលក្នុងរយៈពេលជាង១១ឆ្នាំទទួលបានជោគជ័យក្នុងការវាយតម្លៃគ្រួសារក្រីក្រនៅទូទាំងប្រទេស។
ដោយមានការផ្តល់មូលនិធិពីក្រសួងសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ចនៃសហព័ន្ធអាល្លឺម៉ង់ (BMZ) និងរដ្ឋាភិបាលអូស្ត្រាលី និងមានការគាំទ្រលើការអនុវត្តពីអង្គការជីអាយហ្ស៊ិតGIZ ក្រសួងផែនការនៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំដំណើរការមួយដែលមានលក្ខណៈប្រមូលផ្តុំ និងដំណើរការជាប្រក្រតីដែលផ្ទុយស្រឡះកាលពីពេលមុនអង្គការនិងកម្មវិធីដែលដឹកនាំការកំណត់អត្តសញ្ញាណកម្មសម្រាប់គោលបំណងផ្ទាល់របស់ខ្លួន និងផ្អែកលើលក្ខណៈវិនិច្ឆ័យភាពក្រីក្រផ្សេងៗ។
សព្វថ្ងៃ ក្រសួងផែនការ បានផ្តល់ហិរញ្ញប្បទានយ៉ាងពេញលេញ និងសម្របសម្រួលការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅគ្រប់តំបន់ជនបទនៃប្រទេសកម្ពុជា ដែលអ្នកស្រុកនៅតាមមូលដ្ឋានធ្វើការងារជាក់ស្តែងក្នុងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅក្នុងសហគមន៍របស់ពួកគេ។

យោងទៅតាមអ្នកស្រី សោភ័ណ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ទទួលបានជោគជ័យក្នុងការស្វែងរកប្រជាជនក្រីក្រពិតប្រាកដ។ គ្រួសារក្រីក្រគឺជាអ្នកទទួលបានប័ណ្ណ។ នេះជារបៀបដែលខ្ញុំមើលឃើញស្ថានភាពពិតប្រាកដ " ។ បន្ថែមលើសេវាកម្មដែលមានស្រាប់ ទាក់ទងនឹងប័ណ្ណសមធម៌នៅក្នុងភូមិរបស់គាត់ គាត់ចង់ឃើញការគាំទ្របន្ថែមទៀត ដូចជា កម្មវិធីជីវភាព ឬជំនួយក្នុងការសាងសង់បង្គន់អនាម័យជាដើម។ ការងារនេះមានលក្ខណៈស្របតាមផែនការរបស់រាជរដ្ឋាភិបាល ដើម្បីឲ្យកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មានការវិវត្តជាផ្នែកសំខាន់មួយនៃកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រកាន់តែមានលក្ខណៈទូលំទូលាយ។



អ្នកស្រី ម៉ក់ ដា (អាយុ២៤ឆ្នាំ) និងស្វាមី បានប្រើប្រាស់ប័ណ្ណសមធម៌របស់គ្រួសារគាត់ជាលើកទី១សម្រាប់សម្រាលកូនប្រុសរបស់គាត់, ដែលត្រូវការការព្យាលជំងឺរលាកផ្លូវដង្ហើម។ គាត់បាននិយាយថា បើមិនមានប័ណ្ណនេះទេ ពួកគាត់ច្បាស់ជាត្រូវខ្ចីលុយគេយកមកបង់ថ្លៃឱ្យមន្ទីរពេទ្យជាក់ជាមិនខាន។

## វិធីរៀបចំបង្កើតករណីសិក្សានេះ

នៅខែមករា ឆ្នាំ២០១៧ អ្នកនិពន្ធ និងអ្នកស្រាវជ្រាវមួយរូបរបស់ GHPC បានសិក្សារបាយ-ការណ៍ និងឯកសារកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រទាំងអស់ បន្ទាប់មកបានធ្វើដំណើរមកកាន់ប្រទេសកម្ពុជាដើម្បីស្វែងយល់ដោយផ្ទាល់អំពីអ្វីដែលបានធ្វើ។ នៅកម្ពុជា លោកស្រីបានសម្ភាសដៃគូ និងភាគីពាក់ព័ន្ធនានានៅក្នុងគំនិតផ្តួចផ្តើមនេះ ដូចជាបុគ្គលិកកំពុងបម្រើការងារ និងបុគ្គលិកដែលធ្លាប់បម្រើការងារ អ្នកពិគ្រោះយោបល់ ដៃគូអភិវឌ្ឍន៍ និងតំណាងក្រសួងផែនការ ព្រមទាំងភ្នាក់ងាររដ្ឋាភិបាលដទៃទៀតផងដែរ។ ករណីសិក្សានេះត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយអ្នកដែលធ្លាប់បានធ្វើការនៅក្នុងគំនិតផ្តួចផ្តើមនេះ តាមរយៈដំណើរការផ្ទះបញ្ចាំងជាចម្បងលើដំណើរការអនុវត្តន៍ បញ្ហាប្រឈមដែលបានកើតឡើង និងការយល់ដឹងក្នុងការដោះស្រាយបញ្ហាទាំងនោះ ស្របតាមការផ្តោតការយកចិត្តទុកដាក់លើបទពិសោធន៍ពីការអនុវត្ត របស់ឯកសារសមូហកម្មនេះ។

បន្ទាប់ពីការសង្ខេប ស្តីពកាកំណត់និយមន័យនៃភាពក្រីក្រ និងវិធីផ្សេងៗក្នុងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ក្នុងជំពូកទី៣ នឹងបង្ហាញនូវសាវតារនៃភាពក្រីក្រនៅកម្ពុជា និងតម្រូវការសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ជំពូកទី៤ ពិពណ៌នាអំពីដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជំពូកទី៥ ផ្តោតលើបញ្ហាប្រឈមដែលកម្មវិធីបានជួបប្រទះក្នុងអំឡុងពេលអនុវត្ត និងនិងដំណោះស្រាយបញ្ហា របស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ជំពូកជាបន្តបន្ទាប់ពិនិត្យឡើងវិញនូវសមិទ្ធផល របស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគោលគំនិតសំខាន់ៗដែលបានកើតឡើងនៅអំឡុងពេលអនុវត្ត។ ករណីសិក្សានេះបញ្ចប់ដោយមានការពិនិត្យឡើងវិញពីអ្នកជំនាញឯករាជ្យពីររូបក្នុងវិស័យភាពក្រីក្រ និងការគាំពារសង្គម។

# ពាក្យពេចន៍ខ្លះៗអំពីភាពក្រីក្រ និងអត្តសញ្ញាណកម្មជនក្រីក្រ

## ការកំណត់និយមន័យ និងការវាស់វែងភាពក្រីក្រ

ជាធម្មតា ខ្សែបន្ទាត់នៃភាពក្រីក្រផ្អែកលើតម្លៃរូបិយវត្ថុនៃការប្រើប្រាស់របស់បុគ្គលម្នាក់ទាក់ទងនឹងតម្រូវការអប្បបរមានៃអាហារូបត្ថម្ភ សម្លៀកបំពាក់ និងជម្រកស្នាក់នៅ។ គិតត្រឹមខែតុលាឆ្នាំ២០១៥ ធនាគារពិភពលោកបានកំណត់ខ្សែបន្ទាត់ភាពក្រីក្រអន្តរជាតិស្មើនឹង ១,៩០ដុល្លារក្នុងម្នាក់ក្នុងមួយថ្ងៃ និងរាយការណ៍អំពីការកាត់បន្ថយភាពក្រីក្រសកលពី៣៧,១% ក្នុងឆ្នាំ ១៩៩០ មក ១២,៨%ក្នុងឆ្នាំ២០១២(Cruz et al, 2015)។ ការរិះគន់របស់ធនាគារពិភពលោកលើចំណុចគោល និងការគណនាភាពក្រីក្រសាកល បានចង្អុលបង្ហាញថា ចំណុចទាំងនោះអាចត្រូវបានជំរុញដោយរបៀបវារៈនយោបាយ និងបិទបាំងស្ថានភាពក្រីក្ររបស់អ្នកដែលមានជីវភាពក្រីក្រក្បែរក្រ ″ ដែលនៅខ្សែលើបន្ទាត់ភាពក្រីក្រតែបន្តិចបន្តួចប៉ុណ្ណោះ (Hickel 2015 Reddy & Pogge, 2009)[1] ។ រាជរដ្ឋាភិបាលបានកំណត់កម្រិតភាពក្រីក្រផ្ទាល់របស់ខ្លួនដោយផ្អែកលើការចំណាយក្នុងស្រុកលើទំនិញសំខាន់ៗក្នុងទម្រង់ជាម្ហូបអាហារ និងមិនមែនជាម្ហូបអាហារ។

ផ្ទុយទៅនឹងការគណនាភាពក្រីក្រដែលផ្អែកលើប្រាក់ចំណូល (ជាទូទៅនៅក្នុងប្រទេសអភិវឌ្ឍន៍) ឬការគណនាភាពក្រីក្រដែលផ្អែកលើការប្រើប្រាស់ ទស្សនទាននៃភាពក្រីក្រពហុវិស័យពិនិត្យមើលលើភាពខ្វះខាតដែលប្រជាជនជួបប្រទះលើផ្នែកសុខភាព អាហារូបត្ថម្ភ ការអប់រំ និងកម្រិតជីវភាពរស់នៅ (ការទទួលបានទឹកស្អាតប្រើប្រាស់) អនាម័យ និងឥន្ធនៈចម្អិនអាហារទំនើប) ជាដើម។ ទស្សនទាននោះឆ្លុះបញ្ចាំងពីរបៀបដែលប្រជាជនក្រីក្រពិពណ៌នាអំពីភាពក្រីក្ររបស់ខ្លួន និងទទួលស្គាល់ឧបសគ្គផ្សេងៗដែលរារាំងពួកគេមិនឲ្យទទួលបានគុណភាពជីវិតសមរម្យ (UNDP, 2016 Oxford Poverty and Human Development Initiative, 2015) ។

## ការស្វែងរកជនក្រីក្រ៖ វិធីសាស្ត្រកំណត់មុខសញ្ញា និងការដោះដូរ

ប្រសិទ្ធភាពនៃវិធីសាស្ត្រកំណត់មុខសញ្ញាជាទូទៅ ត្រូវបានវាស់ស្ទង់លើលទ្ធភាពក្នុងការបញ្ចៀស ១)-ការរួមបញ្ចូលអ្នកទទួលផលដែលមិនមែនជាជនក្រីក្រ (គិតទាំងកំហុស ឬ " ការលេចធ្លាយ ") និង ២)-ការខកខានមិនបានរួមបញ្ចូលអ្នកក្រីក្រពិតប្រាកដ (កំហុសពីការមិនបានដាក់បញ្ចូល ឬកំហុសពី ' ភាពគ្របដណ្តប់មិនបានគ្រប់គ្រាន់' (Oxford Policy Management, 2009; McBride and Nichol, 2016)។

ការកំណត់មុខសញ្ញាទាមទារឲ្យមាននិយមន័យអំពីភាពក្រីក្រដែលអាចវាស់ស្ទង់បាន។ នៅប្រទេសអភិវឌ្ឍន៍ សិទ្ធិទទួលបានអត្ថប្រយោជន៍សង្គម ជាទូទៅត្រូវបានកំណត់តាមរយៈឧបករណ៍វាស់វែងកម្រិតជីវភាពដែលវាស់ស្ទង់ចំនួនប្រាក់ចំណូល និងប្រាក់សន្សំដែលមនុស្សម្នាក់មាន ឬអាចពាក់ព័ន្ធនឹងការអង្កេតអំពីការប្រើប្រាស់។ ឧបករណ៍វាស់វែងពីកម្រិតជីវភាព ជាញឹកញាប់ត្រូវបានប្រើប្រាស់នៅតំបន់ដែលមានប្រាក់ចំណូលទាបដែលមានមនុស្សជាច្រើនធ្វើការនៅក្នុងវិស័យក្រៅប្រព័ន្ធ ខណៈដែលការប្រមូលព័ត៌មានច្បាស់លាស់អំពីប្រាក់ចំណូល ឬការប្រើប្រាស់ជួបការពិបាក ត្រូវចំណាយប្រាក់កាស និងចំណាយពេលច្រើន។

### *ឧបករណ៍វាស់វែងពីកម្រិតជីវភាព*

ឧបករណ៍វាស់វែងពីកម្រិតជីវភាពមានទំនាក់ទំនងរវាង ″ វត្ថុប្រហាក់ប្រហែល " ដែលងាយកំណត់បរិមាណ ឬងាយសង្កេត ដូចជា ទ្រព្យសម្បត្តិ( ឧទាហរណ៍ កម្មសិទ្ធិលើវិទ្យុ ប្រភេទដំបូលផ្ទះ) ឬការប្រព្រឹត្ត (កុមារទៅសាលារៀន) ជាមួយនឹងការប្រើប្រាស់ដែលអនុញ្ញាតឱ្យអ្នកសម្ភាសន៍គណនាពិន្ទុ ហើយប្រើបន្ទាត់បែងចែកសិទ្ធិទទួលបានដែលគេបានបង្កើតឡើង។ ឧបករណ៍វាស់វែងពីកម្រិតជីវភាពត្រូវបានបង្កើតឡើងនៅអាមេរិកឡាទីនក្នុងទសវត្ស១៩៨០ ដើម្បីកំណត់មុខសញ្ញាជនក្រីក្រឱ្យបានល្អប្រសើរសម្រាប់កម្មវិធីសង្គមនានា បន្ទាប់ពីមានវិធានការកំណែទម្រង់រចនាសម្ព័ន្ធរបស់ធនាគារពិភពលោកនិងមូលនិធិរូបិយវត្ថុអន្តរជាតិ ឧបករណ៍វាស់វែងពីកម្រិតជីវភាពមានប្រសិទ្ធភាពជាបង្គួរ ហើយក៏ជាវិធីសម្របតាមស្ថានភាពក្នុងស្រុកក្នុងការកំណត់គ្រួសារក្រីក្រផងដែរ (Lavallée et al, 2010)។ ទោះបីជាយ៉ាងណាក្តី កំហុសក្នុងការរួមបញ្ចូល និងការមិនរាប់បញ្ចូលរបស់វិធីសាស្ត្រនេះ នៅតែអាចមានចំនួនច្រើនដោយសារកត្តាមួយចំនួន ដូចជាការជ្រើសរើសវត្ថុតំណាង និងវិធីធ្វើតេស្ត ជាដើម(AusAID, 2011)។ ឧបករណ៍វាស់វែងពីកម្រិតជីវភាពក៏អាចមិនបានគិតបញ្ចូលនូវលក្ខណ:ពហុទិដ្ឋភាពនៃភាពក្រីក្រ និងមិនអើពើដល់ការយល់ឃើញរបស់សហគមន៍ចំពោះភាពក្រីក្រផងដែរ (Savadogo et al, 2015)។

[1] ភាពស្ទើរក្រីក្រ ត្រូវបានកំណត់ថាជាការរស់នៅកម្រិតភាពក្រីក្រតែបន្តិច ចំណែកឯ ភាពងាយរងគ្រោះចំពោះភាពក្រីក្រវិញគឺជាលទ្ធភាពនៃការក្លាយទៅជាជនក្រីក្រក្នុងពេលអនាគតដែលច្រើនតែបានដឹងតាមកត្តាមួយចំនួន ដូចជា គ្មានការគាំពារសុខភាព ឬជំពាក់បំណុលគេច្រើន (ធនាគារពិភពលោក , 2014a; Mendoza, 2009)។

មានវិធីសាស្ត្រកំណត់មុខសញ្ញាផ្សេងទៀត រួមមានការកំណត់មុខសញ្ញាតាមប្រភេទ (វិធីសាស្ត្រសាមញ្ញមួយដែលផ្អែកលើលក្ខណៈវិនិច្ឆ័យមួយ ឬច្រើនដែលងាយសង្កេត ដូចជា អាយុ ភេទ ស្ថានភាពពិការ)ការកំណត់មុខសញ្ញាតាមភូមិសាស្ត្រ (ជាប្រភេទមួយនៃការកំណត់មុខសញ្ញាតាមប្រភេទផ្តោតជាសំខាន់លើប្រជាជនដែលរស់នៅក្នុងតំបន់ដែលត្រូវបានរកឃើញថាមានភាពក្រីក្រខ្ពស់ ហើយជារឿយៗត្រូវបានផ្គួបជាមួយវិធីសាស្ត្រកំណត់មុខសញ្ញាមួយផ្សេងទៀត) និងការកំណត់មុខសញ្ញាដោយខ្លួនឯង(អ្នកចូលរួមជ្រើសរើសដោយខ្លួនឯងនូវអត្ថប្រយោជន៍ដែលត្រូវបានរៀបចំឡើងដើម្បីរារាំងជនមិនមែនជាអ្នកក្រីក្រ ឧទាហរណ៍ ឱកាសការងារដែលផ្តល់ប្រាក់ឈ្នួលទាបជាងទីផ្សារ) (Lavallée et al, 2010; Conning & Kevane, 2002)។ វិធីសាស្ត្រនីមួយៗទាំងនេះមានភាពងាយស្រួលក្នុងការអនុវត្ត ប៉ុន្តែខ្វះទឡ្ហីករណ៍ ហើយក្នុងករណីមួយចំនួននៅតែមិនបានកំណត់អត្តសញ្ញាណអ្នកក្រីក្រ ជាពិសេសប្រជាជនចល័ត។

## *ការកំណត់មុខសញ្ញាដោយសហគមន៍*

នៅទសវត្សឆ្នាំ ១៩៩០ មានការមិនឯកភាពជាមួយនឹងវិធីសាស្ត្រទូទៅ ដែលត្រូវបានប្រើប្រាស់ដោយកម្មវិធីកាត់បន្ថយភាពក្រីក្រជាច្រើន ដែលនាំឱ្យមានការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើវិធីសាស្ត្រកំណត់មុខសញ្ញាតាមសហគមន៍។ វិធីសាស្ត្រទាំងនេះពាក់ព័ន្ធនឹងការប្រមូលផ្តុំសមាជិកដោយខ្លួនឯងដើម្បីចាត់ ឬកំណត់ថាជាគ្រួសារណាខ្លះដែលពួកគេកំណត់ថាក្រីក្រ តាមធម្មតាមានការពិភាក្សាខ្លះក្នុងចំណោមក្រុមនោះនៅគ្រាដំបូងលើនិយមន័យ ឬលក្ខណៈវិនិច្ឆ័យដែលទាក់ទងនឹងភាពក្រីក្រ (Alatas et al, 2012) ។ ការកំណត់មុខសញ្ញាដោយសហគមន៍អាចមានភាពត្រឹមត្រូវជាងឧបករណ៍វាស់វែងពីកម្រិតជីវភាពក្នុងការកំណត់អត្តសញ្ញាណជនក្រីក្រខ្លាំង និងទទួលបានការពេញចិត្តកាន់តែច្រើននៅក្នុងសហគមន៍ ដែលច្រើនតែផ្តល់ផលវិជ្ជមាន ដូចជាការមិនយល់ស្របគ្នា ឬការតវ៉ាមានចំនួនកាន់តែតិចនៅពេលដែលកម្មវិធីត្រូវបានអនុវត្ត ជាពិសេសនៅទីណាដែលមានការតាមដាន និងតម្លាភាពខ្លាំងក្លា (Yusuf, ឆ្នាំ 2010 Alatas et al, 2012) ។

គុណវិបត្តិនៃការកំណត់មុខសញ្ញាដោយសហគមន៍គឺ អាចមានកំហុសឆ្គងក្នុងការរាប់បញ្ចូលនូវគ្រួសារអ្នកមាន ដោយសារអំពើពុករលួយ (ឧទាហរណ៍ ដូចជាការផ្តល់អត្ថប្រយោជន៍ដល់សមាជិកគ្រួសារ) ឬ " ការដាក់បញ្ចូលអ្នកខ្ពង់ខ្ពស់ " (សមាជិកសហគមន៍ដែលមានឋានៈខ្ពង់ខ្ពស់មានឥទ្ធិពលដល់ការបែងចែកផលប្រយោជន៍ផ្សេងៗ) ឬសហគមន៍មិនដឹងពិតប្រាកដអំពីទ្រព្យសម្បត្តិពិតរបស់គ្រួសារមួយចំនួន (Handa et al, 2012) ។ ទោះជាយ៉ាងណាក្តី ដោយសារវិធីសាស្ត្រកំណត់មុខសញ្ញាដោយសហគមន៍បង្ហាញឲ្យឃើញកំហុសឆ្គងអំពីការរាប់បញ្ចូល គេច្រើនតែរាប់បញ្ចូលអ្នកមានជីវភាពក្បែរក្រមិនមែនរាប់បញ្ចូលអ្នកមានឡើយ (Alatas et al, 2012) ។

ចំណុចមួយទៀតនៃការប្រៀបធៀបគឺថាឧបករណ៍វាស់វែងពីកម្រិតជីវភាពតាមកម្រិតបន្ទាត់ពិន្ទុ មិនអាចរួមបញ្ចូលនូវស្ថានភាពពិសេស ក្រៅពីអថេរដែលបានកំណត់ ដែលអាចធ្វើឱ្យស្ថានភាពគ្រួសារកាន់តែមានលក្ខណៈមិនទៀងទាត់បន្ថែមទៀត ក្នុងពេលដែលវិធីសាស្ត្រកំណត់មុខសញ្ញាដោយសហគមន៍អាចធ្វើបែបនេះបាន។



*ផ្ទះប្រពៃណីយ៍ខ្មែរតាមទីជនបទ- អ្នកស្រី ជូ យឹម រស់នៅក្នុងផ្ទះដូចនេះ ជាមួយនឹងកូនបីនាក់របស់គាត់។ ផ្ទះនេះបាន សាងសង់ឡើងអំពីសសរបង្គោលកូនឈើលាយជាមួយអែបឡែបធ្វើនោបលើកផុតពីផ្ទៃដី ដំបូល និងជញ្ជាំងប្រក់និងបិទបាំងដោយកណ្តាបស្លឹកត្នោត ដែលមិនមានទេផ្ទះដែលប្រក់និងបាំងជញ្ជាំងដោយស័ង្កសីឡើយ។ លក្ខណៈដែលអាចសង្កេតមើលឃើញបាន ដូចជា សម្ភារសំណង់, ទំហំ និង គុណភាពរបស់ផ្ទះសម្បែងគឺជា ផ្នែកមួយនៃបញ្ជីសំណួរសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ។*

ជាទូទៅ ថ្លៃចំណាយនៃវិធីសាស្ត្រកំណត់មុខសញ្ញាជាក់លាក់មួយក៏ប្រែប្រួលផងដែរ នៅពេលណាដែលការកំណត់មុខញ្ញាកាន់តែមានភាពជាក់លាក់ ការចំណាយលើការគ្រប់គ្រងកាន់តែខ្ពស់(Grosh, 1994) ។ បណ្តាប្រទេសដែលមានប្រាក់ចំណូលទាបច្រើនតែជ្រើសរើស ថាតើត្រូវដោះដូរឬថ្លឹងថ្លែងកម្រិតភាពត្រឹមត្រូវនៃការកំណត់មុខសញ្ញា ឬយ៉ាងណា ដើម្បីបញ្ជូនប្រាក់ឱ្យបានច្រើនតាមដែលអាចធ្វើបានសម្រាប់ជាគុណប្រយោជន៍ដល់ប្រទេសទាំងនោះ ឬមួយត្រូវចំណាយច្រើនលើការកំណត់មុខសញ្ញាដើម្បីធានាឲ្យមូលនិធិបានទៅដល់ជនក្រីក្របំផុត។ យន្តការកំណត់មុខសញ្ញាដោយសហគមន៍អាចមានប្រសិទ្ធភាពក្នុងការចំណាយ និងអាចមានភាពត្រឹមត្រូវប្រសិនបើត្រូវបានអនុវត្តក្នុងទ្រង់ទ្រាយធំល្មម ហើយដែលអាចចៀសវាងបាននូវការរាប់បញ្ចូលក្រុមអ្នកធូរធារ (Conning & Kevane, 2002) ។

## *វិធីសាស្ត្រកូនកាត់*

ជម្រើសមួយទៀតគឺ ត្រូវរួមបញ្ចូលគ្នានូវគុណសម្បត្តិនៃឧបករណ៍វាស់វែងពីកម្រិតជីវភាពជាមួយតេស្តនៃការកំណត់មុខសញ្ញាដោយសហគមន៍។ វិធីសាស្ត្របែបនេះជានានូវតម្លាភាពនិងការទទួលយកដោយដាក់បញ្ចូលសហគមន៍ទាំងមូលក្នុងដំណើរការកំណត់មុខសញ្ញា ទន្ទឹមនឹងការពង្រឹងលក្ខណៈវិនិច្ឆ័យដែលមានសង្គតភាពមួយចំនួន និងកាត់បន្ថយលម្អៀងតាមរយៈឧបករណ៍វាស់វែងពីកម្រិតជីវភាពដែលកាន់តែមានលក្ខណៈសត្យានុម័ត។

# ភាពក្រីក្រ ការកាត់បន្ថយភាពក្រីក្រ និងការកំណត់ភាពក្រីក្រនៅកម្ពុជា

## សង្គមមួយក្នុងអន្តរកាល

តាមរបៀបខ្លះ ប្រជាជនកម្ពុជាដែលរស់នៅតាមជនបទ ហាក់ដូចជារស់នៅតាមទម្លាប់ដែលមានរាប់រយឆ្នាំមកហើយ គឺរស់នៅក្នុងផ្ទះតូចៗផុតពីដី ធ្វើពីឈើជញ្ជាំងនិងដំបូលស្លឹក ចម្អិនអាហារដោយដាក់ឆ្នាំងលើថ្មចង្ក្រានបីដុំ ដាំស្រូវ ឬដំឡូងនៅលើផ្ទៃដីតូចៗ អាចមានមាន់ ឬគោមួយក្បាលប្រសិនបើគ្រួសារមានដំណើរការល្អ។ តាមពិតទៅ សង្គមកម្ពុជាមួយផ្នែកធំនៅតែមានលក្ខណៈកសិកម្មដែលមានប្រជាជន 80% នៃប្រជាជនសរុប ប្រមាណជា 15,6 លាននាក់រស់នៅតាមតំបន់ជនបទ យ៉ាងហោចណាស់កំពុងពឹងអាស្រ័យមួយផ្នែកលើការប្រកបរបរកសិកម្ម ( Asia Pacific Observatory on Health Systems and Policies, 2015 ) ។ ជាមួយគ្នានេះ គេក៏ឃើញមានសញ្ញានៃជីវិតសម័យទំនើបផងដែរ។ ម៉ូតូរត់លើផ្លូវដី កូនវិទ្យុព្យួរនឹងទំពក់ក្រោមសំយ៉ាបផ្ទះ ប្រជាជនភាគច្រើនមានទូរស័ព្ទដៃប្រើ ហើយនៅផ្ទះខ្លះឃើញមានពន្លឺព្រាលៗចេញពីទូរទស្សន៍តូចៗភ្ជាប់ទៅនឹងអាគុយ បំភ្លឺរាត្រីកាលជាមួយនឹងមនុស្សកុះករ ជុំគ្នាមើលទូរទស្សន៍។

ជាផ្នែកមួយនៃ ′ចលនាបម្លាស់ទី′ ដែលមានទ្រង់ទ្រាយកាន់តែធំទូលំទូលាយនៅអាស៊ីអាគ្នេយ៍ក្នុងប៉ុន្មានទសវត្សរ៍កន្លងទៅ ចំណាកស្រុកបានពង្រឹងសេដ្ឋកិច្ចកម្ពុជា ទន្ទឹមគ្នាជាមួយការបង្ករភាពស្មុគស្មាញដល់សមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការតាមដាន និងផ្តល់សេវាកម្មដល់ប្រជាជនផ្លាស់ទី (Rigg, 2013) ។ ប្រជាជនប្រមាណជា ១,១៩លាននាក់ កំពុងធ្វើការនៅក្រៅប្រទេសក្នុងឆ្នាំ២០១៥ (ប្រមាណ១២%នៃចំនួនប្រជាជនសរុបដែលកំពុងស្ថិតក្នុងវ័យធ្វើការ ) ហើយបានផ្ញើប្រាក់មកផ្ទះវិញចំនួន៥៤២លានដុល្លារ ( OECD និងវិទ្យាស្ថានបណ្តុះបណ្តាលដើម្បីអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០១៧ )។ ប្រជាជនកម្ពុជាប្រហែល៦០%ដែលជាជនចំណាកស្រុកក្នុងប្រទេសបានរក្សាការងារនៅតាមជនបទ ( ឧទាហរណ៍ វិលត្រឡប់ទៅធ្វើស្រែចម្ការគ្រួសារវិញក្នុងរដូវវស្សា ) ហើយបន្ទាប់មកវិលត្រឡប់ទៅធ្វើការនៅទីក្រុងវិញ មិនដូចបណ្តាប្រទេសកំពុងរីកដុះដាលនគរូបនីយកម្មយ៉ាងឆាប់រហ័សផ្សេងទៀតនៅក្នុងតំបន់ ដូចជា បង់ក្លាដេស ( Parsons et al, 2014 ) ។

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា បានរីកចម្រើនយ៉ាងឆាប់រហ័សលឿនជាងតំបន់ទាំងមូលក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ ដោយកំណើនផលិតផលក្នុងស្រុកសរុបជាមធ្យមជាង 7% ក្នុងមួយឆ្នាំ រវាងឆ្នាំ២០១០ និងឆ្នាំ២០១៥ ( World Bank Open Data ) ។ ជាមួយនឹងចំណូលជាតិសរុបជាមធ្យមក្នុងមនុស្សម្នាក់ៗ ចំនួន ១.០៧០ដុល្លារ នៅឆ្នាំ២០១៥ ប្រទេសកម្ពុជាសព្វថ្ងៃត្រូវបានចាត់ថ្នាក់ដោយធនាគារពិភពលោកថា ជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប បើទោះបីជានៅពីក្រោយប្រទេសភាគច្រើននៅក្នុងតំបន់ ( World Bank Open Data ) ។ ក្រៅពីវិស័យទេសចរណ៍ និងឧស្សាហកម្មវាយនភ័ណ្ឌកំពុងរីកចម្រើន កត្តារួមចំណែកធំបំផុតក្នុងការកាត់បន្ថយភាពក្រីក្រលើប្រាក់ចំណូលគឺ ការកើនឡើងនូវថ្លៃអង្ករពិភពលោក( ឡើងខ្ពស់បំផុតក្នុងឆ្នាំ២០០៨ ) និងក្នុងផលិតកម្មស្រូវ ការកើនឡើងប្រាក់ឈ្នួលកសិកម្ម និងប្រាក់ចំណូលខ្ពស់ជាងមុនពីការងារមិនមែនកសិកម្ម( ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០១៤ )។ ទស្សនវិស័យសម្រាប់កំណើនសេដ្ឋកិច្ចនាពេលអនាគតមានសុទិដ្ឋិនិយមតិចតួច៖ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ថ្លៃអង្ករពិភពលោកបានធ្លាក់ចុះដោយសារតែការផ្គត់ផ្គង់ច្រើនហួស ដែលអាចជំរុញឱ្យកសិករ និងរោងម៉ាស៊ីនកិនស្រូវខ្នាតតូចប្រកបរបរកសិកម្ម (អង្គការស្បៀងអាហារនិងកសិកម្មនៃ U.N. , 2017 ) ។ កត្តាស្មុគស្មាញមួយទៀតគឺ ការប្រែប្រួលអាកាសធាតុដែលត្រូវបានព្យាករណ៍ថានឹងធ្វើឱ្យប៉ះពាល់ដល់ផលិតកម្មស្រូវនៅក្នុងតំបន់ ដែលជាហេតុធ្វើឲ្យអង្ករឡើងថ្លៃ ( Furuya et al, 2014 ) ។

## ទោះជាមានវឌ្ឍនភាពក៏នៅតែមានវិសមភាព

ប្រទេសកម្ពុជា មានវឌ្ឍនភាពក្នុងការកាត់បន្ថយវិសមភាពសេដ្ឋកិច្ចចាប់តាំងពីកម្រិតខ្ពស់បំផុតនៅក្នុងឆ្នាំ២០០៧ ទោះបីជាគម្លាតរវាងអ្នកមានបំផុតនិងអ្នកក្រជាងគេនៅតែអាចមើលឃើញតាមវិធីផ្សេងគ្នាក្តី។ បើគិតពីប្រាក់ចំណូលវិញ នៅឆ្នាំ 2014 ប្រាក់ចំណូលរបស់គ្រួសារដែលអាចចំណាយបាននៃបញ្ចភាគប្រជាជនដែលមានជាងគេបំផុតគឺខ្ពស់ជាងប្រាក់ចំណូលរបស់គ្រួសារដែលស្ថិតក្នុងបញ្ចភាគប្រជាជនក្រីក្របំផុតចំនួន១៨ដង( វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០១៥ )។

នៅក្នុងវិស័យអប់រំ បើទោះបីជាមានការរីកចម្រើនយ៉ាងខ្លាំងចាប់តាំងពីរបបខ្មែរក្រហម[2] បានបំបាត់ការរៀនសូត្រ ក្មេងៗដែលមកពីគ្រួសារក្រីក្ររៀនមិនបានជិតដល់ដូចក្មេងៗដែលមកពីគ្រួសារមានទ្រព្យសម្បត្តិច្រើនឡើយ។ នៅឆ្នាំ២០១៤ កុមារដែលស្ថិតក្នុងបញ្ចភាគក្រីក្របំផុតនៃចំនួនប្រជាជនរៀនជាមធ្យមបានត្រឹមតែ ៤,៨ឆ្នាំប៉ុណ្ណោះ ធៀបនឹង 10,4 ឆ្នាំចំពោះកុមារដែលមកពីបញ្ចភាគគ្រួសារមានបំផុត(ទិន្នន័យមូលដ្ឋានរបស់អង្គការយូណេស្កូអំពីវិសមភាពពិភពលោកស្តីពីការអប់រំ)។

[2] ខ្មែរក្រហមដែលដឹកនាំដោយប៉ុលពតគឺជាចលនាកុំម្មុយនីស្តជាច់ខាតដែលគ្រប់គ្រងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ប្រជាជនកម្ពុជារហូតដល់២លាននាក់បានស្លាប់ក្រោមរបបឃោរឃៅរបស់ពួកនេះ។ ថ្វីបើភាគច្រើននៃចំនួនប្រជាជនដែលនៅសេសសល់គឺជាអនក្ខរជនក្នុងឆ្នាំ១៩៧៩ក្តី ប្រជាជនកម្ពុជាវ័យក្មេងសព្វថ្ងៃនេះមានអត្រាអក្ខរកម្ម៨២ភាគរយ ( កម្រងទិន្នន័យវិសមភាពពិភពលោករបស់អង្គការយូណេស្កូស្តីពីការអប់រំឆ្នាំ 2014 ) ។

ប្រជាជនជាច្រើននាក់បានបាត់បង់ដីធ្លីដែលជាប្រភពនៃជីវភាពរស់នៅ និងប្រាក់ចំណូល នៅពេលខ្មែរក្រហមបានលុបបំបាត់ទ្រព្យសម្បត្តិឯកជន និងបំផ្លាញឯកសារដីធ្លីក្នុងឆ្នាំ១៩៧៥។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងបែងចែកដីធ្លីចាប់តាំងពីឆ្នាំ១៩៨៩ ក៏ដោយ ក៏ដីត្រូវបានប្រមូលផ្តុំកាន់តែខ្លាំងឡើងទៅក្នុងដៃឯកជនដែលមានទ្រព្យសម្បត្តិ ឬធ្លាក់ទៅក្នុងដៃក្រុមហ៊ុន (Thiel, 2010) ។ ប្រមាណជា 30% នៃផ្ទៃដីរបស់ប្រទេសកម្ពុជាគឺជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋចំនួន 1% (Neef, Touch & Chiengthong, 2013) ។ តាមការប៉ាន់ស្មានគ្រួសារជនបទ 20-40% មិនមានដីធ្លីក្នុងឆ្នាំ២០០៩ កើនឡើងពី 13% ក្នុងឆ្នាំ១៩៩៧ (World Bank, 2007, Murotani, 2014) ។ ស្ថិតិភាពក្រីក្រជាផ្លូវការរបស់ប្រទេសកម្ពុជា បង្ហាញពីរឿងលើកទឹកចិត្តមួយ ទោះបីជាអាស្រ័យលើនិយមន័យណាមួយដែលត្រូវបានយកមកប្រើប្រាស់ក្តី។ និយមន័យមួយចំនួនមានភាពវិជ្ជមានជាបង្គួរ៖ កម្រិតភាពក្រីក្រថ្នាក់ជាតិបច្ចុប្បន្នត្រូវបានកំណត់ឱ្យស្មើនឹង 0,95 ដុល្លារក្នុងមួយថ្ងៃ (ក្រសួងផែនការនៃប្រទេសកម្ពុជាឆ្នាំ ២០១៣) ។ យោងតាមនិយមន័យនេះ ភាពក្រីក្របានថយចុះយ៉ាងខ្លាំងពី 47,8% នៃចំនួនប្រជាជនក្នុងឆ្នាំ២០០៧ មកប្រមាណ 13,5% នៅឆ្នាំ២០១៥ ដោយមាន 90% នៃប្រជាជនរស់នៅតាមតំបន់ជនបទ (ក្រសួងផែនការឆ្នាំ២០១៣ ធនាគារពិភពលោកឆ្នាំ២០១៧ ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០១៤)។

ទោះជាយ៉ាងណាក៏ដោយ ការស្ទង់មតិគ្រួសារបានបង្ហាញថា ប្រជាជនភាគច្រើនដែលធ្លាប់រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ បច្ចុប្បន្ននេះបានផ្លាស់ប្តូរទៅខាងលើខ្សែបន្ទាត់ភាពក្រីក្រតែបន្តិចប៉ុណ្ណោះ និងស្ថិតក្នុងកម្រិតងាយរងគ្រោះដែលនៅតែមានការលំបាកនិងការខ្វះខាតជាបន្ត។ យោងតាមការវិភាគទិន្នន័យឆ្នាំ២០១១ ការបាត់បង់ការប្រើប្រាស់របស់មនុស្សម្នាក់ស្មើនឹង 0,28 អឺរ៉ូក្នុងមួយថ្ងៃ នឹងអាចបង្កើនអត្រាភាពក្រីក្រទ្វេដង ឡើងដល់ 41% (World Bank, 2014a)។ ដោយប្រើប្រាស់ការពិនិត្យភាពក្រីក្រលើពហុទិដ្ឋភាព កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ បានប៉ាន់ប្រមាណថាអត្រាភាពក្រីក្រពហុទិដ្ឋភាពនៅកម្ពុជាក្នុងឆ្នាំ២០១៤ ស្មើនឹង ៣៤% ជាមួយនឹងការបន្ថែមជនងាយរងគ្រោះ២២% (UNDP, ទិន្នន័យឆ្នាំ២០១៤)។

ទិន្នន័យទាំងនេះ បង្ហាញពីបញ្ហាប្រឈមនានាចំពោះអត្តសញ្ញាណកម្មភាពក្រីក្រនៅកម្ពុជា ពោលគឺការផ្លាស់ប្តូរយ៉ាងឆាប់រហ័សទៅលើអ្នកដែលត្រូវបានកំណត់ថាជាអ្នកក្រ យោងតាមខ្សែបន្ទាត់នៃភាពក្រីក្ររបស់កម្ពុជា ចំនួនប្រជាជនមួយផ្នែកធំ និងដែលមិនសូវត្រូវបានពិភាក្សាជាអ្នកដែលមានជីវភាពក្បែរក្រ និងសំណួរអំពីវិធីល្អបំផុតដើម្បីវាស់វែងភាពក្រីក្រពហុទិដ្ឋភាពតាមរបៀបមួយដែលមានអត្ថន័យដល់ជនក្រីក្រខ្លួនឯង និងអាចអនុវត្តនៅក្នុងក្របខណ្ឌជាតិ។

## តម្រូវការប្រព័ន្ធកំណត់មុខសញ្ញានៅថ្នាក់ជាតិ

នៅក្នុងទសវត្សដំបូងក្រោយរបបខ្មែរក្រហម កម្ពុជាបានព្យាយាមកសាងសេដ្ឋកិច្ចឡើងវិញ និងចូលរួមជាមួយសហគមន៍ក្នុងតំបន់និងអន្តរជាតិ ដែលជាផ្នែកមួយអាចបង្ហាញពីភាពជឿនលឿននៃបញ្ហាសង្គម និងបង្កើនទំនុកចិត្តរបស់វិនិយោគិន។ នៅចុងទសវត្សឆ្នាំ១៩៨០ និង១៩៩០ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតផែនការជាបន្តបន្ទាប់ដើម្បីស្តារឡើង និងអភិវឌ្ឍន៍ ″ សេដ្ឋកិច្ចសង្គមកិច្ច ហើយនៅពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ បានចាប់ផ្តើមផ្លាស់ប្តូរពីសេដ្ឋកិច្ចផែនការប្រមូលផ្តុំទៅជាសេដ្ឋកិច្ចទីផ្សារ។ ចាប់ផ្តើមក្នុងឆ្នាំ១៩៩៦ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តថ្លៃប្រើប្រាស់សេវាសុខភាពនៅគ្រប់មន្ទីរពេទ្យជាតិ និងមណ្ឌលសុខភាពទាំងអស់ដែលជាផ្នែកមួយនៃច្បាប់ហិរញ្ញប្បទានសុខាភិបាលថ្មី (Bigdeli & Annear, 2009) ។ ច្បាប់ស្តីពីការរៀបចំរចនាសម្ព័ន្ធពន្ធដារក៏ត្រូវបានអនុម័តផងដែរក្នុងឆ្នាំ១៩៩៧ ដែលរួមបញ្ចូលការពង្រីកពន្ធមួយចំនួន និងបានធ្វើឲ្យប្រព័ន្ធវាយតម្លៃពន្ធមានលក្ខណៈស្តង់ដារ (Rattana, 2013) ។

រដ្ឋាភិបាលបានទទួលស្គាល់ថា ទោះបីប្រជាជនក្រីក្រ ប្រហែលជាជាង៥០% ដូចបានបញ្ជាក់ពីខាងដើមក្តី តួលេខប៉ាន់ប្រមាណក្នុងអំឡុងពេលនេះមិនអាចជឿទុកចិត្តបានឡើយ ពួកគេត្រូវទទួលបានការលើកលែងពីការបង់ថ្លៃសេវាសុខភាព និងពន្ធដារនានា។
ខណៈដែលកំណើនសេដ្ឋកិច្ចបានផ្តល់អត្ថប្រយោជន៍ដល់គ្រួសារដែលមានទ្រព្យសម្បត្តិច្រើន វិសមភាពកំពុងកើនឡើង ជាពិសេសនៅតំបន់ជនបទ (ធនាគារពិភពលោកឆ្នាំ២០០៧)។ ច្បាប់ថ្មីៗត្រូវបានអនុម័តដោយចាប់ផ្តើមនៅចុងទសវត្សឆ្នាំ១៩៩០ ដើម្បីចាប់ផ្តើមរៀបចំជាផ្លូវការនូវទិដ្ឋភាពមួយចំនួនអំពីសំណាញ់សុវត្ថិភាពដើម្បីការពារជនក្រីក្រ និងជនងាយរងគ្រោះ រួមទាំងកម្មវិធីទាក់ទងនឹងការងារធានារ៉ាប់រង និងសន្តិសុខសង្គម។ រាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តអាទិភាពជាផ្លូវការសម្រាប់ដោះស្រាយភាពក្រីក្រ ជាមួយនឹងកញ្ចប់គោលនយោបាយដែលមានសង្គតិភាពនឹងគ្នា គឺយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅឆ្នាំ២០០២ យុទ្ធសាស្ត្រចតុកោណដែលរួមបញ្ចូលជាតុផ្សំនៃផែនការអភិវឌ្ឍសេដ្ឋកិច្ច និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រដែលចាប់ផ្តើមក្នុងឆ្នាំ២០០៤។

វិស័យសុខភាពត្រូវបានកំណត់ជាអាទិភាព ដោយសារមានបញ្ហាសុខភាព និងកង្វះថវិកាដើម្បីបង់ថ្លៃសេវា ដែលនាំទៅដល់ការចៀសវាងមិនថែទាំសុខភាព ហើយធ្វើឲ្យស្ថានភាពសុខភាពកាន់តែធ្ងន់ធ្ងរ។ ក្នុងឆ្នាំ២០០០ មូលនិធិសមធម៌សុខាភិបាលមួយ (HEF) ត្រូវបានដាក់ឲ្យដំណើរការសាកល្បងជាលើកដំបូង ដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ហើយមួយរយៈខ្លីក្រោយមកត្រូវបានពង្រីកតាមរយៈកិច្ចសហការរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាល។ មូលនិធិនេះត្រូវបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងត្រូវបានផ្តល់ហិរញ្ញប្បទានពីមូលនិធិជំនួយពហុភាគីរបស់ប្រទេសកម្ពុជា ដែលប្រទេសអាល្លឺម៉ង់រួមចំណែកតាមរយៈធនាគារអភិវឌ្ឍន៍ KfW ។ មូលនិធិទាំងនេះត្រូវបានប្រើដើម្បីទូទាត់ដល់មន្ទីរពេទ្យក្នុងវិស័យសាធារណៈសម្រាប់សេវាកម្មដែលផ្តល់ដលពលរដ្ឋក្រីក្រ។ អង្គការមិនមែនរដ្ឋាភិបាលដែលបានសហការជាអង្គការដៃគូជាមួយក្នុងស្រុក ក្នុងឋានៈជា ′ ប្រតិបត្តិករ ′ មូលនិធិក្នុងការជ្រើសរើសអ្នកជំងឺក្រីក្រនៅពេលពួកគេទៅដល់មន្ទីរពេទ្យ។ ក្នុងករណីពុំមានវិធីសាស្ត្រជ្រើសរើស និងលក្ខណៈវិនិច្ឆ័យដែលបានព្រមព្រៀងគ្នា នោះអង្គការមិនមែនរដ្ឋាភិបាលនីមួយៗបានបង្កើតវិធីសាស្ត្ររៀងៗខ្លួន។ ការវាយតម្លៃដំណាក់កាលដំបូងបានកំណត់ពីតម្រូវការសំរាប់ការជ្រើសរើសជាមុននៅថ្នាក់ភូមិ ហើយការអនុវត្តផ្សេងៗ ដែលត្រូវបានប្រើប្រាស់ដោយមូលនិធិសមធម៌សុខាភិបាល សម្រាប់ដាក់បញ្ចូលនូវការចូលរួមរបស់សហគមន៍ (Ir et al ។ , 2010) ។ កម្មវិធីអភិវឌ្ឍន៍ផ្សេងៗទៀតដែលផ្តោតទៅលើអ្នកក្រីក្រ ឧទាហរណ៍ កម្មវិធីសន្តិសុខស្បៀង និងកម្មវិធីអាហារូបករណ៍សាលារៀន ក៏បានប្រើប្រាស់វិធីផ្សេងៗដើម្បីកំណត់អត្តសញ្ញាណអ្នកទទួលផលពីកម្មវិធីផងដែរ។ ដោយសារតែប្រជាពលរដ្ឋជាច្រើននាក់មកពីតំបន់ភូមិសាស្ត្រដូចគ្នា គ្រួសារក្រីក្រត្រូវឆ្លងកាត់ការធ្វើតេស្តជាច្រើនដង ហើយចុងបញ្ចប់ពួកគេមានសិទ្ធិទទួលបានកម្មវិធីមួយចំនួន ហើយមួយចំនួនមិនបានទទួល។ ភាពច្របូកច្របល់ និងអប្រសិទ្ធភាព បណ្តាលមកពីប្រព័ន្ធអត្តសញ្ញាណកម្មជនក្រីក្រ ស្របគ្នាទាំងនេះ ចាំបាច់ត្រូវមានយន្តការអត្តសញ្ញាណកម្មជនក្រីក្រដែលកាន់តែមានភាពច្បាស់លាស់។

# ការវិវត្តរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជាផ្នែកមួយនៃការឆ្លើយតបចំពោះភាពក្រីក្ររបស់កម្ពុជា

## ការនាំយកគ្រប់គ្នាទៅកាន់តុពិភាក្សា៖ ការកសាងមតិឯកភាព និង សហហិរញ្ញប្បទាននៅគ្រាដំបូង

នៅដើមឆ្នាំ២០០៥ ក្រសួងផែនការ បានរៀបចំសិក្ខាសាលាជាច្រើនលើកដើម្បីផ្តល់ឱកាសដល់អ្នកផ្តល់ជំនួយ និងដៃគូដែលមានចំណាប់អារម្មណ៍ពិភាក្សាគ្នាអំពីការបង្កើតប្រព័ន្ធកំណត់ភាពក្រីក្ររួម។ ទោះបីជាមានការជជែកវែកញែកពីដំបូងអំពីថាតើក្រសួងមួយណាដែលគួរដឹកនាំគំនិតផ្តួចផ្តើមបែបនេះ សិក្ខាសាលាជាបន្តបន្ទាប់បានឈានដល់កិច្ចព្រមព្រៀងដោយថាហេតុដែលក្រសួងផែនការគឺជាកន្លែងសមស្រប ដោយសារក្រសួងទទួលខុសត្រូវចំពោះការប្រមូលព័ត៌មានប្រជាសាស្ត្រ និងស្ថិតិជាតិសម្រាប់ប្រើប្រាស់នៅគ្រប់វិស័យ។

រដ្ឋាភិបាលអាល្លឺម៉ង់បានផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍកម្មវិធីដំបូង និងសាកល្បង ហើយបានប្រគល់ភារកិច្ចដល់ GIZ ឲ្យគាំទ្រក្រសួងផែនការ។ ក្នុងឆ្នាំ២០០៩ ដោយសារតែមានការចាប់អារម្មណ៍ក្នុងការកំណត់មុខសញ្ញាទាក់ទងនឹងគម្រោងមូលនិធិសមធម៌សុខាភិបាល និងគំនិតផ្តួចផ្តើមផ្នែកសុខភាពដទៃទៀត ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី ក៏បានបន្ថែមមូលនិធិដែលកាលនោះត្រូវបានគេស្គាល់ថាជា " កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ " ឬ " IDPoor " ។ អង្គការ យូនីសេហ្វក៏បានរួមចំណែកក្នុងការផ្តល់មូលនិធិដើម្បីពង្រីកការអនុវត្តរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រឱ្យបានកាន់តែឆាប់កាលពីប៉ុន្មានឆ្នាំដំបូង។

ក្នុងឆ្នាំ២០១០ សហភាពអឺរ៉ុបបានផ្តល់មូលនិធិរយៈពេលពីរឆ្នាំ ដែលមានចំនួន ២លានអឺរ៉ូ ដោយភ្ជាប់លក្ខខណ្ឌថារដ្ឋាភិបាលកម្ពុជានឹងផ្តល់ថវិកាចំនួន 20% នៃទឹកប្រាក់សរុបដែលជាការវិនិយោគមួយដ៏សំខាន់។ ក្រសួងផែនការបានរៀបចំកិច្ចពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអស់រយៈពេលជាច្រើនខែ ហើយនៅទីបំផុតទទួលបានជោគជ័យក្នុងការធានានូវការផ្តល់មូលនិធិនេះជាផ្នែកមួយឆ្ពោះទៅរកកិច្ចព្រមព្រៀងមួយដែលរាជរដ្ឋាភិបាលកម្ពុជា បានធ្វើជាមួយម្ចាស់ជំនួយអន្តរជាតិដើម្បីបង្កើនការចូលរួមចំណែករបស់ខ្លួនចំពោះការចំណាយលើវិស័យសុខាភិបាល។

ចាប់តាំងពីការផ្តល់ហិរញ្ញប្បទានរបស់សហភាពអឺរ៉ុបបានបញ្ចប់នៅក្នុងឆ្នាំ២០១២ មក ប្រទេសអាល្លឺម៉ង់ និងអូស្ត្រាលីបានបន្តផ្តល់ហិរញ្ញប្បទានដល់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ រហូតមកដល់បច្ចុប្បន្ននេះ និងបានធ្វើការជាមួយក្រសួងផែនការ ដើម្បីបង្កើនវិភាគទានហិរញ្ញវត្ថុរបស់ខ្លួនបន្ថែមទៀត ( សូមមើលទំព័រ៥១ )។

## ពីគំរូជំហានដំបូងទៅជាការបង្កើតច្បាប់

នៅខែមិថុនាឆ្នាំ២០០៥ ក្រសួងផែនការបានបង្កើតក្រុមការងារពិគ្រោះយោបល់ដែលមានសមាសភាពពី ក្រសួងសុខាភិបាល អប់រំ មហាផ្ទៃ និងសង្គមកិច្ច ព្រមទាំងដៃគូអភិវឌ្ឍន៍ផងដែរ។ ក្រុមការងារនេះ ទទួលបន្ទុកកំណត់ប្រព័ន្ធកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រថ្មី និងរៀបចំនីតិវិធី និងកម្រងសំណួរចាំបាច់នានាអំពីភាពក្រីក្រ។ សេចក្តីណែនាំនីតិវិធីនេះត្រូវមានប្រសិទ្ធភាព ( ជៀសវាងកំហុសក្នុងការដាក់បញ្ចូល និងកំហុសក្នុងការផាត់ចេញ ) ចំណាយមានប្រសិទ្ធផល មានតម្លាភាព និងរួមបញ្ចូលរចនាសម្ព័ន្ធវិមជ្ឈការដែលទើបចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០០២ ជាមួយនឹងការបោះឆ្នោតក្រុមប្រឹក្សាឃុំជាលើកដំបូង។

យោងតាមលោក Julian Hansen អ្នកផ្តល់ប្រឹក្សា GIZ របស់កម្មវិធីនៅពេលនោះនិយាយថា « លក្ខណៈវិនិច្ឆ័យចម្បងនៃជោគជ័យសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺការទទួលយកកម្មវិធីនេះពីប្រជាជនមូលដ្ឋាន។ គាត់បានពន្យល់ថាយើងត្រូវការការទទួលយកពីពួកគេ ប្រសិនបើរដ្ឋាភិបាលតម្រូវឲ្យកម្មវិធីកំណត់មុខសញ្ញាជនក្រីក្រទាំងអស់ ដើម្បីកំណត់អ្នកទទួលផលតាមរយៈបញ្ជីគ្រួសារក្រីក្រ។ បន្ថែមពីលើនេះ ចាំបាច់ត្រូវបង្ហាញឲ្យបានច្បាស់ដល់រដ្ឋាភិបាល និងភាគីពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ថា អត្តសញ្ញាណកម្មគ្រួសារក្រីក្រមិនមែនជាជំរឿនភាពក្រីក្រឡើយ គឺជាការប្រមូលកម្រងទិន្នន័យម៉ត់ចត់ ដើម្បីអាចកំណត់អត្តសញ្ញាណគ្រួសារដែលស្ថិតនៅលើ ឬនៅក្រោមខ្សែបន្ទាត់ភាពក្រីក្រផ្អែកលើការប្រើប្រាស់។ ផ្ទុយទៅវិញ អត្តសញ្ញាណកម្មគ្រួសារក្រីក្រមានបំណងបង្ហាញភាពក្រីក្រពហុវិស័យហើយផ្តល់អំណាចដល់សហគមន៍ដើម្បីកំណត់ថាតើអ្នកណាជាជនក្រីក្រ។

ក្រុមការងារបានយល់ស្របក្នុងការប្រើគំរូកំណត់មុខសញ្ញាបែបកូនកាត់ (មើលទំព័រ១៥) ដោយរួមបញ្ចូលគ្នានូវឧបករណ៍វាស់វែងពីកម្រិតជីវភាពជាមួយនឹងការចូលរួមយ៉ាងសកម្មរបស់សហគមន៍ និងជាតុចូល។ កម្មវិធីអភិវឌ្ឍន៍ជនបទដែលគាំទ្រដោយអាល្លឺម៉ង់បានបង្កើតអភិក្រមមួយដោយប្រើប័ណ្ណពិន្ទុនៃសូចនាករភាពក្រីក្រ សម្រាប់គ្រួសារក្រីក្រដែលក្រុមតំណាងភូមិមួយបានពិភាក្សា និងកិច្ចប្រជុំពិគ្រោះយោបល់ក្នុងភូមិដើម្បីធានានូវតម្លាភាព។ គំរូទូទៅនេះត្រូវបានសម្រប និងពង្រីកតាមវិធីជាច្រើនសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ៖ កម្រងសំណួរពីស្តារមួយនៃសូចនាករភាពក្រីក្រត្រូវបានបង្កើតឡើង អ្នកភូមិរៀបចំកំរងសំណួរទៅកាន់គ្រួសារ នឹងមានឱកាសបន្ថែមសម្រាប់ទទួលជាតុចូលពីភូមិ និងប្រព័ន្ធជាតិនៃការបណ្តុះបណ្តាល ការគ្រប់គ្រងទិន្នន័យ និងការផលិតប័ណ្ណស្តីពីសិទ្ធិ ត្រូវបានបង្កើតឡើងដើម្បីឱ្យកម្មវិធីអាចពង្រីកបាន។ យោងតាមស្ថានភាពនៃភាពក្រីក្រនៅជនបទក្នុងប្រទេសកម្ពុជា យន្តការនេះត្រូវបានគេគិតជាលើកដំបូងសម្រាប់ទីជនបទតែប៉ុណ្ណោះ។

យោងតាម Anne Erpelding អ្នកសម្របសម្រួលកម្មវិធីនៃកម្មវិធីសុខភាពរបស់ GIZ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៩ ទិដ្ឋភាពផ្តោតលើសហគមន៍ផ្តល់អត្ថប្រយោជន៍យ៉ាងច្រើន។ កម្មវិធីនេះបានជួយដល់អត្តសញ្ញាណកម្មគ្រួសារក្រីក្ររួមបញ្ចូលទាំងដំណើរការនៃការប្រមូលផ្តុំសហគមន៍ និងការកសាងទំនុកចិត្ត និងសាមគ្គីភាព បន្ទាប់ពីមរតករឈឺចាប់នៃសម័យខ្មែរក្រហម។

បន្ទាប់ពីកិច្ចប្រជុំអស់រយៈពេលមួយឆ្នាំកន្លះ ក្រុមការងារបានផលិតសេចក្តីព្រាងសៀវភៅណែនាំអំពីនីតិវិធី និងកម្រងសំណួរស្តីពីអត្តសញ្ញាណកម្មភាពក្រីក្រផ្អែកលើឧបករណ៍វាស់វែងពីកម្រិតជីវភាពដែលបានធ្វើតេស្តសម្ភាសន៍សាកល្បងជាមួយមេគ្រួសារ។ នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានរៀបរាប់លម្អិតនៅក្នុងជំពូកបន្ទាប់ ត្រូវបានអនុវត្តសាកល្បងនៅក្នុងឃុំចំនួន៤នៅដើមឆ្នាំ២០០៧ ហើយបន្ទាប់ពីមានការកែប្រែខ្លះៗ ជុំទីមួយនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្របានអនុវត្តជាផ្លូវការនៅឆ្នាំ២០០៧ នៅខេត្តចំនួនពីរបន្ទាប់មកត្រូវបានអនុវត្តនៅខេត្តចំនួនប្រាំពីរក្នុងឆ្នាំ២០០៨។ សម្រាប់រយៈពេលប៉ុន្មានឆ្នាំបន្ទាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានគ្រោងផែនការដ៏ធំមួយដោយគ្របដណ្តប់ហាសិបភាគរយនៃខេត្តទាំង២៤ក្នុងមួយជុំនៅទូទាំងប្រទេស។ ការងារនេះបានធ្វើឲ្យប៉ះពាល់ដល់ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ហើយចាប់ពីឆ្នាំ២០១២មក ក្រសួងផែនការបានសម្រេចអនុវត្តលើមួយភាគបីនៃរាជធានី ខេត្ត ឬ៨ខេត្តក្នុងមួយឆ្នាំ។ នៅចុងឆ្នាំ២០១០ ភូមិជនបទទាំងអស់យ៉ាងហោចណាស់បានធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រម្តង មានន័យថាអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានគ្របដណ្តប់ស្ទើរទូទាំងប្រទេស ជាមួយនឹងអត្ថិភាពនៃទិន្នន័យគ្រួសារក្រីក្រសម្រាប់កម្មវិធីណាមួយដែលផ្តោតលើជនក្រីក្រ។ នៅឆ្នាំ២០១១ ក្នុងជំហានមួយដ៏សំខាន់ដែលអត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវបានទទួលស្គាល់ជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជា ដែលជាយន្តការអត្តសញ្ញាណកម្មភាពក្រីក្រជាផ្លូវការរបស់ខ្លួន។



ក្រុមតំណាងភូមិពិនិត្យបញ្ជីសំណួរឡើងវិញ និង រៀបចំបញ្ជីព្រាងគ្រួសារក្រីក្រសម្រាប់ការពិគ្រោះយោបល់ជាមួយសហគមន៍

## ពីការកាត់បន្ថយភាពក្រីក្រទៅការគាំពារសង្គមដ៏ទូលំទូលាយ

ខណៈពេលដែលកិច្ចខិតខំប្រឹងប្រែងក្នុងកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាលត្រូវបានបង្កើតឡើងតាមរយៈផែនការយុទ្ធសាស្ត្រដែលទាក់ទងគ្នាជាបន្តបន្ទាប់ តថភាពជាក់ស្តែងក្នុងការអនុវត្តអស់រយៈពេលជាច្រើនឆ្នាំមកហើយគឺជាការងារកម្មវិធី និងគោលនយោបាយដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ដែលគ្មានលក្ខណៈជាប្រព័ន្ធ។

នៅខែកក្កដាឆ្នាំ២០១៧ ទិដ្ឋភាពនេះបានផ្លាស់ប្តូរនៅពេលដែលរដ្ឋាភិបាលកម្ពុជា បានចេញក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមមួយដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០១៧) ។ ក្របខណ្ឌគោលនយោបាយនេះ បង្ហាញពីយុទ្ធសាស្ត្រទូលំទូលាយមួយសម្រាប់ប្រជាជនទាំងមូល ដោយមានសកម្មភាពនានាដើម្បីគាំទ្រដល់សសរស្តម្ភពីរនៃការគាំពារសង្គម គឺប្រព័ន្ធជំនួយសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ និងប្រព័ន្ធសន្តិសុខសង្គមសម្រាប់អ្នកដែលធ្វើការនៅក្នុងវិស័យក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។ ប្រព័ន្ធជំនួយសង្គមរួមមាន ៖ ការថែទាំសុខភាពដោយឥតគិតថ្លៃ កម្មវិធីបំរុងស្បៀង ប្រាក់សោធនពិការភាព ការផ្ទេរសាច់ប្រាក់សម្រាប់ស្ត្រីវ័យចាស់ និងស្ត្រីមានផ្ទៃពោះ និងកុមារ និងរៀបចំកម្មវិធីសម្រាប់អាហារូបត្ថម្ភ អាហារូបករណ៍ ការផ្តល់អាហារនៅសាលារៀន និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ប្រព័ន្ធសន្តិសុខសង្គមមានគោលបំណងដើម្បីទុបស្កាត់ភាពក្រីក្រតាមរយៈកម្មវិធីសោធននិវត្តន៍ និងធានារ៉ាប់រងសុខភាព ពិការភាព គ្រោះថ្នាក់ការងារ និងនិកម្មភាព។

ក្របខណ្ឌគាំពារសង្គមគឺជាជំហានសំខាន់មួយក្នុងការធ្វើឲ្យមានសុខុដុមការូបនីយកម្មនូវគំនិតផ្តួចផ្តើមខុសៗគ្នាជាច្រើន និងការផ្តោតការយកចិត្តទុកដាក់លើកន្សោមគាំពារសម្រាប់ពលរដ្ឋកម្ពុជា ទោះជាក្រីក្រ ឬមិនក្រីក្រក្តី។ ជាយន្តការកំណត់គោលដៅទូទៅ របស់ក្របខណ្ឌអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាការដែលតភ្ជាប់កិច្ចខិតខំប្រឹងប្រែងជំនួយសង្គមរួមគ្នា " នេះបើយោងតាមលោក Ole Doetinchem ប្រធានគម្រោងGIZ គាំទ្រដល់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្រសួងផែនការ។

# វដ្តនៃជំហានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

ខ្លឹមសារនៃអនុក្រឹត្យលេខ២៩១ អនក្រ.បក (អនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ) ដែលបានប្រកាសឱ្យអនុវត្តនៅក្នុងឆ្នាំ២០១១ មានជាភាសាខ្មែរ និងអង់គ្លេស គឺជាកូនសៀវភៅពណ៌សមាន១៦ទំព័រ ដែលមានរឹមពណ៌ទឹកមាស (រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០១១)។ កូនសៀវភៅនេះកំណត់ច្បាស់នូវតួនាទីរបស់រដ្ឋាភិបាលក្នុងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រតាមរយៈដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងក្នុងការផ្សព្វផ្សាយព័ត៌មាននោះដល់អ្នកពាក់ព័ន្ធទាំងអស់។ អនុក្រឹត្យនេះតម្រូវឱ្យស្ថាប័នទាំងអស់ផ្តោតលើគ្រួសារក្រីក្រទាំងស្ថាប័នរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬអន្តរជាតិ ធ្វើកិច្ចការនេះដោយផ្អែកលើទិន្នន័យគ្រួសារក្រីក្រ។ ជំពូកនេះពិពណ៌នាអំពីជំហាននៃដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ក្រសួងផែនការកម្ពុជាឆ្នាំ២០១២)។

## ការជ្រើសរើស និងបណ្តុះបណ្តាលក្រុមតំណាងភូមិ

អត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាឧបករណ៍វាស់វែងពីកម្រិតជីវភាពនៅសហគមន៍ដែលគ្រប់គ្រងដោយអ្នកភូមិនីមួយៗហើយត្រូវបានពិនិត្យនិងទទួលស្គាល់ដោយសហគមន៍ទាំងមូល។ ការវាយតម្លៃ ប្រព្រឹត្តទៅនៅកម្រិតគ្រួសារដែលពាក្យថា 'គ្រួសារ' ត្រូវបានកំណត់ន័យថាជា 'សមាជិកដែលទទួលទានអាហារពីឆ្នាំងតែមួយ ឬចេញថ្លៃចំណាយសម្រាប់ម្ហូបអាហារ' ។

ការវាស់វែងពីកម្រិតជីវភាពត្រូវបានធ្វើឡើងដោយអ្នកភូមិជាច្រើនមកពីភូមិនិមួយៗ ដែលជាក្រុមតំណាងភូមិ (VRG) ជ្រើសតាំងដោយអ្នកភូមិសម្រាប់ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ នេះគឺជាលក្ខណៈពិសេសមួយរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ព្រោះថាជាធម្មតាឧបករណ៍វាស់វែងពីកម្រិតជីវភាពនៅកន្លែងដទៃជាទូទៅ ធ្វើឡើងដោយក្រុមខាងក្រៅធ្វើដំណើរពីភូមិមួយទៅភូមិមួយ។

ដោយសារតែដំណើរការការងារនេះដឹកនាំដោយសហគមន៍ ហើយភូមិនីមួយៗត្រូវធ្វើបច្ចុប្បន្នភាពទិន្នន័យរៀងរាល់បីឆ្នាំម្តង ជាផ្នែកមួយនៃវដ្តរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលចាំបាច់ត្រូវមានការបណ្តុះបណ្តាល។ ការងារនេះចាប់ផ្តើមពីមន្ទីរផែនការខេត្តបញ្ជូនតំណាងទៅចូលរួមកិច្ចប្រជុំជាមួយក្រុមប្រឹក្សាឃុំនីមួយៗ។ ក្រុមប្រឹក្សាទាំងនេះត្រូវបានបង្កើតឡើងជាលើកដំបូងក្នុងឆ្នាំ២០០២ ដែលជាផ្នែកមួយនៃកិច្ចប្រឹងប្រែងអនុវត្តគោលនោបាយវិមជ្ឈការរបស់រាជរដ្ឋាភិបាល ដែលមានតំណាងជ្រើសតាំងពី៥ទៅ១១រូបអាស្រ័យទៅតាមទំហំរបស់ឃុំ[3] ។ នៅ

### ប្រអប់២៖ សូចនាករសម្រាប់វាស់វែងពីកម្រិតជីវភាព

ផ្នែក គ កម្រងសំណួរលម្អិតនៃសូចនាករសម្រាប់វាស់វែងពីកម្រិតជីវភាពដូចតទៅ៖

**ផ្ទះ៖** ជាកម្មសិទ្ធិ ឬជួលគេ សម្ភារៈប្រើសំរាប់ប្រក់ដំបូល និងធ្វើជញ្ជាំង ស្ថានភាពរួម និងទំហំជាម៉ែត្រការ៉េ;

**ប្រភពចំណូល៖** រួមមានការធ្វើកសិកម្ម នេសាទ ការងារផ្សេងទៀត ប្រភេទសត្វជាកម្មសិទ្ធិ និងចំនួនមនុស្សក្នុងគ្រួសារមានប្រាក់ និងគ្មានប្រាក់ចំណូល។

**ទ្រព្យសម្បត្តិ៖** តើគ្រួសារមានវិទ្យុ ឬទូរទស្សន៍ ឬម៉ាស៊ីនភ្លើង និងមធ្យោបាយដឹកជញ្ជូនដែរឬទេ(កង់ ម៉ូតូ រទេះគោ ។ល។)

**ម្ហូបអាហារ៖** តើគ្រួសារមានបានខ្វះអង្ករគេដែរឬទេក្នុងរយៈពេល១២ខែកន្លងមក។

សៀវភៅណែនាំអនុវត្តន៍ និងកម្រងសំណួរអាចរកបាននៅលើវែបសាយត៍អត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅ idpoor.gov.kh ។

ក្នុងកិច្ចប្រជុំទាំងនោះតំណាងមន្ទីរផែនការខេត្តជំរាបក្រុមប្រឹក្សាឃុំអំពីដំណើរការ និងជ្រើសរើសសមាជិកក្រុមតំណាងគ.ផ.ថដើម្បីជាភ្នាក់ងារទំនាក់ទំនង និងផ្តល់ការគាំទ្រសំខាន់ៗដល់ភូមិនីមួយៗនៅក្នុងដំណើរការទាំងមូល។ តំណាងទាំងនោះចូលរួមក្នុងការបណ្តុះបណ្តាលគ្រូបង្គោល ដែលគ្របដណ្តប់លើនីតិវិធីរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ការបំពេញបញ្ជីសំណួរ បូកពិន្ទុ កំណត់ប្រភេទនៃគ្រួសារក្រីក្រ និងពិចារណាស្ថានភាពពិសេសក្នុងការផ្លាស់ប្តូរចំណាត់ថ្នាក់គ្រួសារក្រីក្រ។

នៅពេលចាប់ផ្តើមដំណើរការ អ្នកសម្របសម្រួលក្រុមតំណាងភូមិ ត្រូវរៀបចំបញ្ជីបេក្ខភាពសមាជិកក.ត.ភ បន្ទាប់មកអញ្ជើញបេក្ខភាពទាំងចូលរួមប្រជុំដើម្បីពន្យល់អំពីដំណើរការកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងបញ្ជាក់ជំហរចូលរួម ។សមាសភាពបស់ក្រុមនេះមានទំនាក់ទំនងជិតស្និទ្ធជាមួយចំនួនគ្រួសារក្នុងភូមិ (អ្នកតំណាងម្នាក់សម្រាប់៣០គ្រួសារ )ដែលមានចំនួនសមាជិកអតិបរមា៧នាក់ និងអប្បបរមា៥នាក់។ សមាជិកក្រុមតំណាងភូមិ ត្រូវចេះអាន និង សរសេរអក្សរខ្មែរបាន (ករណីលើកលែងសម្រាប់ភូមិដែលជនជាតិភាគតិចមានសមាមាត្រខ្ពស់) យ៉ាងហោចណាស់មួយភាគបួនជាស្ត្រី ហើយក្រុមទាំងមូល

[3] ខេត្តចំនួន 25 របស់ប្រទេសកម្ពុជា (រួមទាំងរាជធានីភ្នំពេញ) ត្រូវបានបែងចែកទៅជាស្រុក ដែលត្រូវបានបែងចែកបន្តទៅជាឃុំ (ឬនៅទី ប្រជុំជន សង្កាត់) ។ យោងតាមជំរឿនឆ្នាំ 2008 នៅប្រទេសកម្ពុជាមានឃុំសង្កាត់ចំនួន ១.៦២១ ដែលឃុំសង្កាត់មួយមានភូមិចំនួនប្រហែល១០ និងមានចំនួនប្រជាជនពីរាប់ពាន់នាក់ទៅជាង ២០.000 នាក់ក្នុងមួយឃុំ។

គប្បីតំណាងបានល្អមកពីផ្នែកផ្សេងៗនៃសហគមន៍ ទាំងទីតាំងនៅក្នុង ភូមិ សាសនា និងស្ថានភាពសេដ្ឋកិច្ច។ ដំណើរការបោះឆ្នោតប្រព្រឹត្តទៅតាមបែប មួយដែលអនុញ្ញាតឱ្យបេក្ខជននីមួយៗរូបសត្វធ្វើជាតំណាងខ្លួនឯង ហើយអ្នកភូមិ គូសសញ្ញាធីកនៅលើក្រដាសនៅក្បែររូបតំណាងរបស់បេក្ខជនដែលពួកគេជ្រើស រើស)។ គូសធីកនៅលើក្រដាសមួយនៅជាប់រូបតំណាងបេក្ខជនដែលបានជ្រើស រើស)។ តាមរបៀបនេះអ្នកភូមិមានព័ត៌មានអំពីអ្នកតំណាងរបស់ពួកគេចំពោះ ដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។

ក្រោយពេលដែលសមាជិកក្រុមតំណាងភូមិ ត្រូវបានជ្រើសតាំង ក្រុមតំណាងគ.ផ.ថ ដែលទើបបានទទួលការបណ្តុះបណ្តាលធ្វើការ បណ្តុះពួកគេ ហើយខ្លះទៀតជាធ្វើជាអ្នកសម្របសម្រួលដើម្បីគាំទ្រVRGs ក្នុងភារកិច្ចរបស់ពួកគេ។ បន្ទាប់មក ក្រុមតំណាងភូមិ ជួបគ្នាដើម្បីបំពេញតារាង ផែនការសកម្មភាពដែលគូសបញ្ជាក់ជំហាននីមួយនៃការអនុវត្តនៅមូលដ្ឋាន កំណត់ អត្តសញ្ញាណអ្នកទទួលខុសត្រូវចំពោះលទ្ធផលមួយណា និងកំណត់ពេលវេលា។ ជារួម ដំណើរការកំណត់អត្តសញ្ញាណកម្មមិនត្រូវចំណាយពេលយូរជាង៧៦ថ្ងៃ ក្រោយពីការជ្រើសរើសនិងបណ្តុះបណ្តាលក្រុមតំណាងភូមិរហូតដល់បញ្ជីគ្រួសារ ក្រីក្រត្រូវបានបញ្ចប់។

## ដំណើរការសំភាសន៍តាមគ្រួសារ

ជំហានដំបូង VRG ប្រធានភូមិ និងអនុភូមិ រួមគ្នាចងក្រងនិងធ្វើបច្ចុប្បន្នភាព បញ្ជីគ្រួសារក្នុងភូមិសម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ។ ផ្អែកលើបញ្ជីនេះ VRG កំណត់ថាគ្រួសារណាខ្លះដែលសង្ស័យថាគ្រួសារក្រីក្រ ហើយដែលគួរធ្វើការសម្ភាសន៍។ សមាជិក VRG ម្នាក់ៗសម្ភាសប្រមាណជា ៣០ គ្រួសារក្នុងរយៈពេលពីរសប្តាហ៍ ហើយត្រូវចំណាយប្រាក់ ២,000 រៀល (ប្រហែល 0,46 €) ក្នុងការសម្ភាសន៍កម្រងសំណួរមួយនីមួយៗ។

កម្រងសំណួរនោះមានបួនផ្នែក៖ ក) ព័ត៌មានមូលដ្ឋានអំពីអ្នកដែលបាន ចូលរួមក្នុងការសម្ភាសន៍ ខ) ផ្នែកប្រជាសាស្ត្រសម្រាប់កំណត់អត្តសញ្ញាណ សមាជិកគ្រួសារទាំងអស់ គ) សូចនាករវាស់វែងពីកម្រិតជីវភាពជា មួយការដាក់ពិន្ទុ (សូមមើលប្រអប់ទី២) និង ឃ) ព័ត៌មានគ្រួសារបន្ថែម សម្រាប់ក្រុមអ្នកតំណាងភូមិពិចារណា ដែលមិនដាក់ពិន្ទុ។ នៅក្នុងផ្នែក ឃ អ្នកសំភាសន៍បង្ហាញថា១២ខែកន្លងមក តើគ្រួសារនោះមានភាពងាយរងគ្រោះ ដែរឬយ៉ាងណា ឧទាហរណ៍ សមាជិកមានពិការភាព ឬមានជំងឺរ៉ាំរ៉ៃ តើមេគ្រួសារជាឪពុកម្តាយទោល ឬមួយមានការលំបាកចំពោះការទៅសាលារៀន របស់កុមារដែរឬទេ។

នៅចុងបញ្ចប់នៃការសម្ភាសន៍គ្រួសារនីមួយៗ អ្នកសំភាសន៍បញ្ជាក់លើទំព័រមុខ តើ មានស្ថានភាពពិសេសអ្វីដែលត្រូវយកមកពិចារណាចុងក្រោយចំពោះស្ថានភាពនៃ ភាពក្រីក្រ ហើយផ្តល់កម្រងសំណួរដែលបានបំពេញរួចទៅឲ្យ VRG ដើម្បីពិនិត្យមើល និងបូកពិន្ទុពីផ្នែកនីមួយៗដើម្បីបានពិន្ទុសរុបសម្រាប់គ្រួសារនីមួយៗ។

**ប្រអប់១៖ គន្លឹះសំខាន់ៗនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ**
(ដ្យាក្រាមនៃដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅទីជនបទ).



## ប្រអប់៣៖ ការដោះស្រាយសំណូមពរនិងមតិជំទាស់របស់អ្នកភូមិ

ជាដំបូងអ្នកភូមិអាចលើកឡើងពីការមិនពេញចិត្តអំពីឈ្មោះនៅក្នុងបញ្ជីព្រាងនៃគ្រួសារក្រីក្រលើកដំបូងនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅតាមភូមិ ឬតាមរយៈការសរសេរទៅកាន់ក្រុមអ្នកតំណាងភូមិក្នុងរយៈពេលប្រាំពីថ្ងៃបន្ទាប់ពីកិច្ចប្រជុំនោះ។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីធានាឱ្យមានការអនុវត្តត្រឹមត្រូវនិងតម្លាភាពនៃដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (សូមមើលទំព័រ៣១) ក្រសួងផែនការបានពង្រីកយន្តការបណ្តឹងតវ៉ា។



អ្នកភូមិក្នុងកិច្ចប្រជុំពិគ្រោះយោបល់មួយនៅខេត្តពោធិ៍សាត់មានឱកាសលើកសំណួរអំពីបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង។

បច្ចុប្បន្ននេះអ្នកភូមិអាចផ្ញើរពាក្យបណ្តឹងដោយផ្ទាល់ទៅក្រុមប្រឹក្សាឃុំ ប្រសិនបើពួកគេមិនយល់ស្របនឹងស្ថានភាពគ្រួសារក្រីក្រដែលក្រុមតំណាងភូមិបានផ្តល់ឱ្យពួកគេ ឬបើពួកគេមិនយល់ស្របនឹងទិដ្ឋភាពមួយចំនួននៃដំណើរការនេះ។ ចំណុចនេះមានសារៈសំខាន់ណាស់ប្រសិនបើពួកគេមានសំណួរថា ហេតុអ្វីបានជាពួកគេមិនត្រូវបានកំណត់អត្តសញ្ញាណជាជនក្រីក្រ ឬសង្ស័យថាមានទំនាក់ទំនងបុគ្គលនៅក្នុងភូមិ។ បន្ទាប់មកក្រុមប្រឹក្សាឃុំនឹងពិនិត្យឡើងវិញនូវករណីនេះហើយស្នើសុំឱ្យក្រុមតំណាងភូមិពិចារណាឡើងវិញលើការសម្រេចចិត្តរបស់ខ្លួន ទោះបីជាក្រុមនោះគ្មានសិទ្ធិក្នុងការបដិសេធសំណើរបស់ពួកគេក៏ដោយ។

លោក ឌឹម ឌន ប្រធានមន្ទីរផែនការខេត្តកំពង់ឆ្នាំងបានពន្យល់ថា „អារម្មណ៍របស់ប្រជាជនមានសារៈសំខាន់ណាស់ „ ។ គាត់និយាយថា យើងមានកម្រងសំណួរដែលមានលក្ខណៈស្តង់ដារ ការវាយតម្លៃមានលក្ខណៈស្តង់ដារ មានតម្លាភាព និងវិធីប្តឹងតវ៉ា ហេតុនេះហើយបានជាប្រជាជនជឿប្រព័ន្ធនេះ។

ជាធម្មតាប្រជាជនពីរបីនាក់ប៉ុណ្ណោះក្នុងភូមិនីមួយៗដែលសាកសួរលទ្ធផលនៃដំណើរការអត្តសញ្ញាណកម្មនេះ។ នៅក្នុងកិច្ចប្រជុំពិនិត្យចំណាត់ថ្នាក់គ្រួសារក្រីក្រនៅថ្នាក់ឃុំនាពេលថ្មីៗនេះ មេភូមិ ប៉ាង ខុម បានពន្យល់ថាមានគ្រួសារបី ឬបួនក្នុងភូមិរបស់គាត់បានសំណូមពរនិងផ្តល់មតិជំទាស់បន្ទាប់ពីការប្រមូលទិន្នន័យគ្រួសារក្រីក្រជុំចុងក្រោយ។ អ្នកខ្លះធ្លាប់មានប័ណ្ណសមធម៌ ហើយឆ្ងល់ថាហេតុអ្វីបានជាពួកគេមិនទទួលបានប័ណ្ណនេះម្តងទៀត។ ក្រុមអ្នកតំណាងភូមិបានបញ្ជាក់អំពីព័ត៌មាននៃកម្រងសំណួររបស់ខ្លួន ដោយបានបង្ហាញឱ្យឃើញថា ស្ថានភាពរបស់ពួកគេបានប្រសើរឡើង ដូចជា ក្មេងជំទង់ ឬក្មេងពេញវ័យបានចាប់ផ្តើមធ្វើការ និងរួមចំណែករកចំណូលឲ្យគ្រួសារ។ ក្នុងករណីមួយទៀត គ្រួសារពីមុនធ្លាប់មានជីវភាពធូរធា ហេតុនេះពួកគេគ្មានឈ្មោះនៅក្នុងបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូងឡើយ។ កិច្ចសម្ភាសន៍បានបង្ហាញថាចាប់តាំងពីជុំចុងក្រោយមកគ្រួសារនោះបានធ្លាក់ខ្លួនឈឺ ហើយបាត់បង់ប្រាក់ចំណូល និងបាត់បង់ដីធ្លី ដូច្នេះគ្រួសារនោះឥឡូវនេះមានលក្ខណៈសម្បត្តិជាគ្រួសារក្រីក្រ។



ចំណងជើង៖ លោក ឌឹម ឌន (ស្តាំ) ប្រធានមន្ទីរផែនការខេត្តកំពង់ឆ្នាំងពិនិត្យមើលទិន្នន័យ IDPoor ជាមួយ លោក កែវ អ៊ូលី ប្រធានកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្រសួងផែនការ។

ក្រសួងផែនការ មានបំណងបង្កើតបណ្តាញទូរស័ព្ទទាន់ហេតុការណ៍មួយខ្សែដើម្បីដោះស្រាយបណ្តឹង ឬបញ្ហានានាក្នុងដំណើរអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងដើម្បីពង្រឹងសិទ្ធិរបស់ប្រជាជនកម្ពុជាក្នុងការចូលរួមក្នុងដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ប្រកបដោយតម្លាភាព។ ជាចុងក្រោយ គឺត្រូវបានរៀបចំប្រព័ន្ធគ្រប់គ្រងពាក្យបណ្តឹងគ្រប់ជ្រុងជ្រោយ ដែលមាននរណាម្នាក់អាចលើកឡើងនូវការព្រួយបារម្ភក្នុងអំឡុងពេលធ្វើ អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងក្នុងអំឡុងពេលផ្សព្វផ្សាយទិន្នន័យ មិនថាជួបដោយផ្ទាល់ក្នុងកិច្ចប្រជុំនៅតាមភូមិ ឬឃុំ តាមរយៈទូរស័ព្ទ ឬអ៊ីនធឺណែតឡើយ។ ដំណោះស្រាយពាក្យបណ្តឹងនឹងត្រូវបានតាមដានដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងអ៊ីនធឺណិតដែលជាផ្នែកមួយនៃការត្រួតពិនិត្យប្រព័ន្ធអ៊ីនធឺណែត (កំពុងដំណើរការនៅឆ្នាំ២០១៧ និងមានពិពណ៌នានៅក្នុងជំពូកបន្ទាប់)។

បន្ទាប់មកទៀត សមាជិកក្រុមតំណាងភូមិជួបជុំគ្នាដើម្បីពិនិត្យមើលពិន្ទុសារជាថ្មី និងធ្វើចំណាត់ថ្នាក់ ថាតើជាគ្រួសារក្រីក្រកម្រិតទី១ (= ក្រខ្លាំង) គ្រួសារក្រីក្រកម្រិតទី២ (= ក្រ) និងផ្សេងៗ (មិនក្រ)។ កម្រិតក្រីក្រចំនួនពីរត្រូវបានកំណត់ក្នុងករណីកម្មវិធីមួយចំនួនសម្រេចចិត្តផ្តោតតែទៅលើគ្រួសារក្រីក្រខ្លាំង។ ក្នុងកិច្ចប្រជុំនេះក្រុមតំណាងភូមិ ក៏ពិចារណាអំពីស្ថានភាពពិសេសដែលប៉ះពាល់ដល់គ្រួសារមួយចំនួនផងដែរ ហើយតើគួរផ្លាស់ប្តូរចំណាត់ថ្នាក់គ្រួសារក្រីក្រ តាមស្ថានភាពជាក់ស្តែងរបស់ពួកគេដែរឬទេ។ ជាគោលការណ៍ការផ្លាស់ប្តូរចំណាត់ថ្នាក់មិនលើសពី១០%នៃគ្រួសារដែលបានសម្ភាសន៍ដោយយោងលើស្ថានភាពពិសេសរបស់គ្រួសារ ហើយការផ្លាស់ប្តូរត្រូវមានការឯកភាពពី VRG ចំនួនពីរភាគបី។

## ការផ្តល់សុពលភាពលើលទ្ធផល

អ្នកសម្របសម្រួលក្រុមតំណាងភូមិនីមួយៗ បង្ហាញពីបញ្ជីព្រាងចំណាត់ថ្នាក់គ្រួសារក្រីក្រនៅក្នុងកិច្ចប្រជុំនៅថ្នាក់ឃុំដែលមានការចូលរួមពីសមាជិកក្រុមប្រឹក្សាឃុំ នាយកសាលា និងប្រធានមន្ទីរពេទ្យឬមណ្ឌលសុខភាព និងតំណាងមកពីអង្គការនានាដែលធ្វើការនៅក្នុងឃុំ។ ឧទាហរណ៍ អ្នកចូលរួមកិច្ចប្រជុំពិនិត្យមើលថាតើសមាមាត្រនៃគ្រួសារក្រីក្រសមស្របនឹងស្ថានភាពជាក់ស្តែងដែរ ឬយ៉ាងណានៅក្នុងភូមិនោះ ហើយតើសមាមាត្រគ្រួសារក្រីក្រមានការប្រែប្រួលដោយសារស្ថានភាពពិសេសក្នុងកម្រិតសមហេតុសមផលដែរឬទេ។ អ្នកសំរបសំរួលក្រុមតំណាងភូមិ ឆ្លើយតបគ្រប់សំណួរអំពីមូលហេតុដែលបណ្តាលឲ្យមានការផ្លាស់ប្តូរស្ថានភាពគ្រួសារ ឬពន្យល់អំពីរបៀបអនុវត្តនៅក្នុងភូមិ និងនាំមកនូវមតិត្រឡប់ ឬសំណូមពរណាមួយពីកិច្ចប្រជុំទៅកាន់ក្រុមតំណាងភូមិ។ការផ្តល់សុពលភាពលើលទ្ធផល

ក្រោយពីកិច្ចប្រជុំ (បើចាំបាច់) ក្រុមតំណាងភូមិ ត្រូវកែសម្រួលនិងបិតផ្សាយជាសាធារណៈនូវបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូងនៅក្នុងភូមិយ៉ាងតិចពីពីរទៅបីថ្ងៃ ជាមួយនឹងសេចក្តីជូនដំណឹងអំពីកាលបរិច្ឆេទ និងទីកន្លែងប្រជុំពិគ្រោះយោបល់។ នៅក្នុងកិច្ចប្រជុំនេះ តំណាងគ្រួសារប្រជាពលរដ្ឋម្នាក់ៗអាចចោទសួរ ឬដាក់ពាក្យបណ្តឹងបាន ប្រសិនបើ ពួកគេគិតថាពួកគេគួរតែត្រូវបានសម្ភាសន៍ ប៉ុន្តែមិនបានសម្ភាស ឬប្រសិនបើពួកគេមិនយល់ស្របទៅនឹងការចាត់ថ្នាក់អំពីភាពក្រីក្ររបស់ពួកគេផ្ទាល់ ឬរបស់គ្រួសារផ្សេងទៀត។ បន្ទាប់ពីកិច្ចប្រជុំនេះ  VRG ត្រូវបិតផ្សាយបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូងរយៈពេលប្រាំពីរថ្ងៃបន្ថែមទៀត ដោយមានការណែនាំអំពីការការផ្តល់ជំទាស់បន្ថែមទៀត ទៅកាន់ក្រុមប្រឹក្សាឃុំដោយផ្ទាល់។ បន្ទាប់មក ក្រុមតំណាងភូមិ ត្រូវដោះស្រាយសំណូមពរឬមតិជំទាស់ ឬអាចសម្ភាសគ្រួសារដែលមិនមានឈ្មោះក្នុងបញ្ជីបន្ថែមទៀត រួចផ្ទៀងផ្ទាត់ព័ត៌មានឡើងវិញនិងរៀបចំបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ។

បន្ទាប់មក VRG ត្រូវបិតផ្សាយរៀបចំបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយនៅក្នុងភូមិរយៈពេលប្រាំពីរថ្ងៃបន្ថែមទៀតដើម្បីទទួលសំណូមពរនិងមតិជំទាស់។ បញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ និងកំណត់ហេតុនៃកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភូមិ ត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំឱ្យបានមុនពេលបើកកិច្ចប្រជុំដើម្បីពិនិត្យ និងបញ្ជាក់ទទួលស្គាល់បញ្ជីគ្រួសារក្រីក្រចុងក្រោយនេះ រួចបញ្ជូនបន្តទៅមន្ទីរផែនការខេត្តសម្រាប់ជំហានបន្ទាប់។ ក្រុមប្រឹក្សាឃុំប្រគល់មកវិញនូវបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយទៅឱ្យក្រុមតំណាងភូមិ សម្រាប់ភូមិដែលពុំមានព័ត៌មានគ្រប់គ្រាន់ ហើយស្នើឱ្យផ្ទៀងផ្ទាត់សាជាថ្មី ឬសុំការពន្យល់មុនពេលបញ្ជីព្រាងគ្រួសារក្រីក្របានបញ្ជូនជាថ្មីម្តងទៀត និងមុនពេលពិនិត្យ និងបញ្ជាក់ទទួលស្គាល់។



ចំណាងជើង៖ កំពុងស្កេនប័ណ្ណសមធម៌ IDPoor នៅមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង។ ប័ណ្ណសមធម៌អនុញ្ញាតឲ្យអ្នកមាន ប័ណ្ណបានទទួលសេវាសុខភាពឥតបង់ប្រាក់ និងទទួលបានអត្ថប្រយោជន៍ផ្សេងទៀតដែលថ្លៃចំណាយនានាត្រូវបានបើកផ្តល់ឲ្យមន្ទីរពេទ្យដោយមូលនិធិសមធម៌សុខាភិបាល។

## ការបញ្ចូលទិន្នន័យ និងផលិតប័ណ្ណសមធម៌

មន្ទីរផែនការរាជធានី ខេត្តបញ្ជូនបញ្ជីគ្រួសារក្រីក្រ បញ្ជីសំណួរ និង ឯកសារទាក់ទងទាំងអស់ទៅក្រសួងផែនការ ដើម្បីសម្របសម្រួលការបញ្ចូលទិន្នន័យនៅថ្នាក់ជាតិ។ ការព្យាយាមពីដំបូងគឺបុគ្គលិកនៅថ្នាក់ខេត្តបញ្ចូលទិន្នន័យ ប៉ុន្តែជាលទ្ធផលធ្វើឲ្យគុណភាពទិន្នន័យមិនល្អ និងពិបាកថែទាំកម្មវិធីកុំព្យូទ័រពីសំណាក់ការិយាល័យ នៃមន្ទីរផែនការខេត្ត ដែលច្រើនតែខ្វះការគាំទ្រផ្នែកព័ត៌មានវិទ្យា។ ដូច្នេះ ក្នុងឆ្នាំ២០១០ ភារកិច្ចនេះត្រូវបានប្រគល់ឲ្យក្រុមហ៊ុនដែលមានជំនាញក្នុងការបញ្ចូលនិងគ្រប់គ្រងទិន្នន័យ ហើយជាលទ្ធផលបានផ្តល់គុណភាពទិន្នន័យប្រសើរជាងមុន និងកាន់តែមានប្រសិទ្ធផល។

ខណៈដែលទិន្នន័យកំពុងត្រូវបានបញ្ចូល ក្រសួងផែនការ រួមជាមួយមន្ទីរផែនការខេត្ត រៀបចំក្រុមថតរូបនិងបានផ្តល់ការបណ្តុះបណ្តាល ដើម្បីចុះថតរូបថតរូបគ្រួសារក្រីក្រនៅតាមភូមិ សម្រាប់ផលិតប័ណ្ណសមធម៌ ។ ក្រុមអ្នកថតរូបជូនដំណឹងដល់គ្រួសារក្រីក្រនីមួយៗឱ្យនាំសមាជិករបស់ខ្លួនមកថតរូបបានជុំគ្នា ព្រមទាំងជម្រាបអំពីប្រភេទសេវាកម្មនិងជំនួយផ្សេងៗដែលពួកគេអាចទទួលបាននៅពេលពួកគេមានប័ណ្ណសមធម៌។

ដោយប្រើលេខកូដគ្រួសារ រូបថតត្រូវបានផ្គូរផ្គងជាមួយនឹងព័ត៌មាននៅក្នុងមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ។ បន្ទាប់មកប័ណ្ណសមធម៌ត្រូវបានបោះពុម្ពនៅថ្នាក់ជាតិ និងប្រគល់ទៅមន្ទីរផែនការខេត្ត ដើម្បីប្រគល់ប័ណ្ណទាំងនោះទៅឲ្យគ្រួសារក្រីក្រដែលមានឈ្មោះក្នុងបញ្ជីគ្រួសារក្រីក្រចុងក្រោយ។

ដើម្បីត្រួតពិនិត្យការអនុវត្តគ្រប់ជំហានការងារទាំងអស់ក្រសួងផែនការចាត់មន្ត្រីកម្មវិធីមួយរូបឱ្យទទួលខុសត្រូវសម្របសម្រួលខេត្តគោលដៅដែលអនុវត្តការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមឆ្នាំនីមួយៗ។

# ការគ្រប់គ្រង និងការផ្សព្វផ្សាយទិន្នន័យ

នៅពេលដែលការបញ្ចូលទិន្នន័យត្រូវបានបញ្ចប់ ក្រសួងផែនការ រៀបចំសិក្ខាសាលាផ្សព្វផ្សាយទិន្នន័យគ្រួសារក្រីក្រ នៅថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនៅក្នុងខេត្តនីមួយៗ។ សព្វថ្ងៃនេះ កម្រងទិន្នន័យគ្រួសារក្រីក្រ ក៏អាចរកបានតាមអ៊ិនធឺណេតតាមរយៈប្រព័ន្ធព័ត៌មានគ្រួសារក្រីក្រ (IIS) ផងដែរ ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ដែលបានចុះឈ្មោះអាចមើលប្រព័ន្ធរបាយការណ៍ស្តង់ដារ។ ដៃគូអាចស្នើសុំការចូលប្រើ IIS ពីក្រសួងផែនការតាមរយៈគេហទំព័រអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមអាសយដ្ឋាន www.idpoor.gov.kh ដែលផ្តល់ព័ត៌មានអំពីការរៀបចំ និងការប្រើប្រាស់ទិន្នន័យរបស់ខ្លួន។ អ្នកប្រើប្រាស់ដែលបានចុះឈ្មោះក៏អាចស្នើសុំទិន្នន័យដើម ឧទាហរណ៍ ប្រសិនបើពួកគេចង់សំដៅលើអនុក្រុមជាក់លាក់នៃគ្រួសារក្រីក្រដែលមានសេវាសម្រាប់គ្រួសារក្រីក្រ។ ក្រុមការងារក៏បញ្ជូនកម្រងទិន្នន័យគ្រួសារក្រីក្រទៅកាន់ដៃគូនានាលើមូលដ្ឋានកំពុងដំណើរការ ផ្តល់វីដេអូ សន្លឹកព័ត៌មាន ការបង្ហាញតាមអ៊ីនធឺណិត និងសិក្ខាសាលានានា ដើម្បីពន្យល់ថាតើមានទិន្នន័យណាដែលអាចរកបាន និងរបៀបប្រើប្រាស់ទិន្នន័យដើម្បីកំណត់រកអ្នកទទួលផលពីកម្មវិធីកាត់បន្ថយភាពក្រីក្រ។

# ដំណើរការល្អិតល្អន់នៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

ជាសង្ខេបការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្នុងមួយជុំៗត្រូវចំណាយពេល១ឆ្នាំ ឬលើសពីនេះ ចាប់ពីការចាប់ផ្តើមរហូតដល់ការចែកប័ណ្ណសមធម៌ដល់គ្រួសារក្រីក្រ និងការផ្សព្វផ្សាយទិន្នន័យ។ អ្នកពាក់ព័ន្ធប្រហែល៣៥.000នាក់បានចូលរួមនៅក្នុងដំណើរការនេះ ចាប់ពីពីមន្ត្រីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រចំនួន១៧នាក់នៅក្រសួងផែនការ រហូតដល់ក្រុមតំណាងភូមិដែលបានចូលរួមក្នុងដំណើរការនេះ ហើយពួកគេម្នាក់ៗមានការយល់ដឹងកាន់តែប្រសើរអំពីភាពក្រីក្រនៅក្នុងសហគមន៍ រួមទាំងនរណាខ្លះជាជនក្រីក្រ របៀបដែលពួកគេរស់នៅ និងអ្វីដែលពួកគេត្រូវការ។

ជាដំណើរការលម្អិតដែលត្រូវការពេលវេលាដើម្បីវិវឌ្ឍ ហើយជាញឹកញាប់ដំណើរការនេះប្រព្រឹត្តទៅបែបនេះ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា។ ជំពូកបន្តបន្ទាប់ពិនិត្យមើលយ៉ាងស៊ីជម្រៅអំពីប្រភេទនៃបញ្ហាប្រឈមនានាដែលអត្តសញ្ញាណកម្មគ្រួសារក្រីក្របានប្រឈមមុខក្នុងអំឡុងពេលអភិវឌ្ឍន៍ និងប្រឈមមុខចំពោះគោលគំនិតនានាដែលកើតចេញពីដំណោះស្រាយរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

# បញ្ហាប្រឈម និង ការកែតម្រូវ

រហូតដល់បច្ចុប្បន្ន មានរយៈពេលជាង១១ឆ្នាំ ដែលការងារ**អត្តសញ្ញាណកម្មគ្រួសារក្រីក្រ** បានប្រឈមមុខនឹងបញ្ហាប្រឈមជាច្រើនលើការអនុវត្ត ដែលនាំទៅដល់ការរៀនសូត្រជាក្រុមនិងការកែសម្រួលកម្មវិធី ជាដំណើរការមួយដែលបន្តរហូតមកដល់បច្ចុប្បន្ន។ ជំពូកនេះនឹងពិនិត្យឡើងវិញនូវបញ្ហាប្រឈម និងការសម្របសម្រួលសំខាន់ៗដែលស្ថិតនៅក្រោមសំណួរសំខាន់ចំនួនបីគឺ៖

## ● ធ្វើដូចម្តេចដើម្បីធានាថាយើងមិនរំលងនរណាម្នាក់?

ការងារនេះរួមបញ្ចូលការកែសម្រួលដែលទាក់ទងនឹងការធានាឱ្យ**អត្តសញ្ញាណកម្មគ្រួសារក្រីក្រ** គ្របដណ្តប់គ្រួសារក្រីក្រទាំងអស់រួមទាំងការត្រួតពិនិត្យឱ្យបានល្អប្រសើរនៃដំណើរការនេះ ដោះស្រាយនូវមតិយោបល់ផ្សេងៗគ្នានៃភាពក្រីក្រ ពិនិត្យមើលយន្តការនានាក្នុងការដាក់បញ្ចូលពលរដ្ឋក្រីក្រនិងជនចំណាកស្រុកថ្មីៗ និងកែសម្រួលដំណើរការដើម្បីឈានដល់ពលរដ្ឋក្រីក្រនៅទីប្រជុំជន។

## ● តើយើងគ្រប់គ្រងទិន្នន័យដូចម្តេច?

ការកែសម្រួលនេះទាក់ទងទៅនឹងការយល់ដឹងជាបន្តបន្ទាប់អំពីការដាក់បញ្ចូលការគ្រប់គ្រង ការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រយ៉ាងច្រើន ដែលអត្តសញ្ញាណកម្មគ្រួសារក្រីក្របានដំណើរការ ។ ការកែសម្រួលរួមមាន ការផ្លាស់ប្តូរពីប្រព័ន្ធប្រើក្រដាសបញ្ជីសំនួរទៅប្រព័ន្ធឌីជីថល ការកែលម្អការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យ ជាពិសេសតាមរយៈការចូលប្រើអ៊ីនធឺណិត។

## ● តើយើងរួមបញ្ចូលភាគីពាក់ព័ន្ធនិងកសាងទំនុកចិត្តក្នុងប្រព័ន្ធនេះដោយរបៀបណា?

ការទទួលស្គាល់លើកទីបីនិងមានលក្ខណៈជាសាកលអំពី សារៈសំខាន់នៃការទំនាក់ទំនងនិងដាក់បញ្ចូលអ្នកពាក់ព័ន្ធទាំងអស់ក្នុងពេលបច្ចុប្បន្ន និងភាគីពាក់ព័ន្ធដែលមានសក្តានុពលក្នុងពេលអនាគតក្នុងការអភិវឌ្ឍន៍អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលកំពុងដំណើរការ ដើម្បីធានាឲ្យមានតម្លាភាពនិងការជឿទុកចិត្តលើនិយមន័យនៃភាពក្រីក្រ ដំណើរការ និងការសម្រួលការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។

## ការធ្វើឱ្យប្រសើរឡើងនូវភាពត្រឹមត្រូវអត្តសញ្ញាណកម្មភាពក្រីក្រតាមរយៈការកែសម្រួលដំណើរការ និងការតាមដានត្រួតពិនិត្យការអនុវត្ត

ការផ្តល់អំណាចដឹកនាំការងារដោយសហគមន៍ មានន័យថាការវិវត្តរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានផ្សារភ្ជាប់ទៅនឹងសមត្ថភាពនៅមូលដ្ឋាន ។ អាស្រ័យហេតុនេះការកែតម្រូវពីជុំដំបូងៗនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រទាក់ទងទៅនឹងរបៀបដំណើរការឧបករណ៍ ឬការបណ្តុះបណ្តាល ចាំបាច់ត្រូវរៀបចំកែតម្រូវឲ្យបានល្អទៅតាមតថភាពកម្រិតភូមិ និងទៅតាមតម្រូវការចាំបាច់សម្រាប់ត្រួតពិនិត្យនិងគាំទ្រការអនុវត្តឲ្យបានកាន់តែប្រសើរ។

ឧទាហរណ៍ ដំបូងសមាជិកក្រុមតំណាងភូមិ មានការលំបាកមួយចំនួនក្នុងការគ្រប់គ្រងផ្នែកមួយចំនួននៃកម្រងសំណួរ ដូចជា ការប៉ាន់ប្រមាណទំហំនៃភាពក្រីក្ររបស់គ្រួសារ ដូច្នេះ កម្មវិធីបណ្តុះបណ្តាលត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីកសាងជំនាញរបស់អ្នកសម្ភាសន៍លើផ្នែកទាំងនេះ។ ដោយសារតែអ្នកមានវ័យក្មេងមានសមត្ថភាពខ្ពស់ក្នុងការធ្វើផែនការ និងសម្រេចបានចំនួនគ្រួសារដែលបានចាត់ឲ្យបំពេញតាមកាលកំណត់ បន្ថែមលើជំនាញអាននិងសរសេរបានល្អ ការបណ្តុះបណ្តាលអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានចាប់ផ្តើមសង្កត់ធ្ងន់បន្ថែមទៀតនូវតម្លៃនៃការជ្រើសរើសយុវជនដើម្បីធ្វើជាសមាជិកក្រុមតំណាងភូមិ។ ជារួម អ្នកអនុវត្តនៅតាមមូលដ្ឋានពីភូមិរហូតដល់ថ្នាក់ខេត្តទទួលបានជំនាញកាន់តែច្រើនបន្ទាប់ពីជុំទីមួយ ឬជុំទីពីរ ទោះបីជាការបណ្តុះបណ្តាលជាបន្តបន្ទាប់នៅតែមានលក្ខណៈដដែលៗនៅរៀងរាល់ពេលចាប់ផ្តើមនៃជុំនីមួយៗដើម្បីរំលឹកការចងចាំរបស់អតីតសិក្ខាកាម និងក្នុងការបណ្តុះបណ្តាលសិក្ខាកាមថ្មី។

ដើម្បីកាត់បន្ថយលទ្ធភាពដែលការអនុវត្តមិនត្រឹមត្រូវ អាចនាំឱ្យមានការខកខានក្នុងការដាក់បញ្ចូលគ្រួសារក្រីក្រ ដែលក្រសួងផែនការបានបង្កើនការអនុវត្តតាមដាននិងការគាំទ្រចំពោះការអនុវត្ត។ មន្ត្រីសម្របសម្រួលខេត្ត នៃក្រុមការងារកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ របស់ក្រសួងផែនការ ចាប់តាំងពីពេលចាប់ផ្តើម ប៉ុន្តែចំនួនរបស់ពួកគេបានកើនឡើងតាមពេលវេលាដើម្បីសម្របសម្រួលដំណើរការឲ្យបានល្អប្រសើរ និងផ្តល់ការគាំទ្រដល់ខេត្តចំនួន 8ឬ9 ដែលអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្នុងឆ្នាំណាមួយ។ ក្រសួងផែនការក៏បានបង្កើតគោលការណ៍ណែនាំថ្មីសម្រាប់ការត្រួតពិនិត្យដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅថ្នាក់ឃុំ

និងថ្នាក់ខេត្តផងដែរ។ ឧទាហរណ៍ ចំណុចដែលត្រូវពិនិត្យ និងរាយការណ៍ ថា តើបញ្ជីឈ្មោះគ្រួសារត្រូវសម្ភាសន៍ត្រូវបានបង្កើតឡើងដោយក្រុមតំណាងភូមិ ឬត្រូវបានរៀបចំដោយមេភូមិ។ ចាប់តាំងពីឆ្នាំ២០១១មក ជំហាននានានៃការអនុវត្ត ត្រូវបានតាមដានដោយប្រុងប្រយ័ត្ន និងរួមបញ្ចូលគ្នានៅថ្នាក់ខេត្ត ហើយត្រូវបានរាយការណ៍ទៅក្រសួងផែនការ។

## ការតស៊ូជាមួយទស្សនៈ ផ្សេងគ្នានៃភាពក្រីក្រ

ថ្វីបើមានការកែតម្រូវចំពោះដំណើរការនិងការត្រួតពិនិត្យបានល្អយ៉ាងណាក៏ដោយ ក៏ដៃគូមួយចំនួនផ្អែកលើបទពិសោធន៍នៃកម្មវិធីរបស់ខ្លួននៅតែលើកសួរថា តើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គ្របដណ្តប់អ្នកក្រទាំងអស់ឬយ៉ាងណា ។ ឧទាហរណ៍ ដូចជានៅពេលដែលដៃគូអភិវឌ្ឍន៍មួយបានចាប់ផ្តើមគាំទ្រកម្មវិធីផ្ទេរសាច់ប្រាក់របស់ក្រសួងសង្គមកិច្ចសម្រាប់ជនពិការនៅក្នុងខេត្តតូចមួយ ដៃគូនោះបានប្រើបញ្ជីគ្រួសារក្រីក្រ ដើម្បីកំណត់រកអ្នកទទួលផល ប៉ុន្តែក៏បានចុះទៅដល់កន្លែងផងដែរដើម្បីឲ្យប្រាកដថាពួកគេរកឃើញអ្នកទទួលផលសក្តានុពលគ្រប់ៗគ្នា។ ដោយសារជនពិការច្រើនតែខ្វះឱកាសប្រកបរបរចិញ្ចឹមជីវិត ដៃគូអភិវឌ្ឍន៍មានការភ្ញាក់ផ្អើលដែលថាអ្នកដែលពួកគេបានកំណត់ថាមានពិការភាព មានសមាមាត្រគ្រួសារក្រីក្រទាបជាងការរំពឹងទុក។ អង្គការមិនមែនរដ្ឋាភិបាលមួយទៀតដែលបានដំណើរការកម្មវិធីផ្ទេរសាច់ប្រាក់ភ្ជាប់លក្ខខណ្ឌសម្រាប់គ្រួសារក្រីក្របានប្រមូលទិន្នន័យច្បោលៗហើយលើកឡើងថានៅក្នុងខេត្តមួយចំនួនអ្នកទទួលផលពីកម្មវិធីមានតែ 30% -50% ប៉ុណ្ណោះដែលត្រូវបានកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ កំណត់ថាជាអ្នកក្រីក្រ។

ការធានាឲ្យអត្តសញ្ញាណគ្រួសារក្រីក្រ ប្រាកដជាកំណត់បាននូវគ្រួសារក្រីក្រទាំងអស់ពិតប្រាកដ គឺស្មុគ្រស្មាញជាងដំណើរការបានត្រឹមត្រូវរបស់ក្រសួងផែនការ ។ ចំណាកស្រុក និងការប្រែប្រួលយ៉ាងខ្លាំងនៃគ្រួសារធ្លាក់ចូលក្នុងភាពក្រីក្រ និងចាកផុតពីភាពក្រីក្រគឺជាមូលហេតុដ៏សំខាន់ដែលបញ្ជាក់ថា ហេតុអ្វីបានជាអាចមានគ្រួសារមួយចំនួនមិនស្ថិតនៅក្នុងជុំនានានៃការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ បញ្ហាទាំងនេះនិងការឆ្លើយតបរបស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានពិភាក្សានៅក្នុងផ្នែកបន្ទាប់។ ប៉ុន្តែមានកត្តាជាច្រើនដែលបានរួមចំណែកដល់ទស្សនៈនេះ ទោះជាផ្អែកលើ ឬមិនផ្អែកលើតថភាពដែលថាអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មិនគ្របដណ្តប់អ្នកក្រីក្រទាំងអស់ក្តី។

ទី១ ប្រជាជនងាយរងគ្រោះ ត្រូវការការផ្សព្វផ្សាយខ្លាំងក្លាបន្ថែមទៀតពីព្រោះជាញឹកញាប់ពួកគេមិនត្រូវបានគេយកចិត្តទុកដាក់ ហើយមិនសូវយល់ដឹង ឬមិនចង់ចូលរួមនៅក្នុងដំណើរការសហគមន៍ដូចជាអត្តសញ្ញាណកម្មគ្រួសារក្រីក្រឡើយ។ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ពិតជាបានខិតខំក្នុងការកំណត់អត្តសញ្ញាណប្រជាជនងាយរងគ្រោះ ពោលគឺតាំងពីដំបូង កម្រងសំណួរបានសួរថា តើមានសមាជិកគ្រួសារណាមានពិការភាព ឬមានជំងឺរ៉ាំរ៉ៃឬទេ មានក្មេងកំព្រា មនុស្សចាស់ មិនអាចធ្វើការបាន ឬសួរថា តើមានមេគ្រួសារគឺជាស្ត្រីដែរឬទេ ទាំងនេះជាប្រភេទងាយរងគ្រោះជាធម្មតាចំណាត់ថ្នាក់នៃភាពងាយរងគ្រោះគឺអនុលមតាមរដ្ឋាភិបាល។ ក្រសួងផែនការ ក៏បានរៀបចំកែសម្រួលវគ្គបណ្តុះបណ្តាលនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីលើកទឹកចិត្ត VRGs ឱ្យខិតខំប្រឹងប្រែងចុះផ្សព្វផ្សាយបន្ថែមទៀតចំពោះសហគមន៍ជនជាតិដើមភាគតិច និងលើកទឹកចិត្តឱ្យពួកគេចូលរួមក្នុងកិច្ចប្រជុំសហគមន៍ និងចូលរួមក្នុងទិដ្ឋភាពផ្សេងទៀតនៃដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ប៉ុន្តែក្នុងករណីខ្លះ ដៃគូបាននិយាយថាពួកគេកំពុងស្វែងរកប្រជាជនងាយរងគ្រោះដែលមិនបានធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

### ប្រអប់លេខ៤៖ កំណត់ន័យ និងវាស់វែងភាពត្រឹមត្រូវនៃការកំណត់មុខសញ្ញានៃភាពក្រីក្រ

ភាពត្រឹមត្រូវនៃយន្តការកំណត់មុខសញ្ញានៃភាពក្រីក្រ ពិនិត្យមើល តើយន្តការនេះកំណត់បានល្អយ៉ាងដូចម្តេច ក្នុងការកំណត់ន័យអំពីអ្នកក្រ ហើយទុកអ្នកមិនក្រមួយឡែក អាចត្រូវបានពិចារណាតាមទិដ្ឋភាពរួមចំណែកជាច្រើន៖

១ ) តើសូចនាករ ឬ **លក្ខណៈវិនិច្ឆ័យដែលត្រូវបានប្រើ**ដើម្បីកំណត់ន័យភាពក្រីក្រអាចញែកអ្នកក្រីក្រពីអ្នកមិនក្រដែរ ឬទេ ? បើមិនដូច្នោះទេ គួរកែតម្រូវសូចនាករទាំងនោះ៖ ឧទាហរណ៍ ប្រសិនបើគ្រួសារភាគច្រើនមានដំបូលប្រក់ស័ង្កសី សំភារៈនោះលែងជាលក្ខណៈខុសគ្នានៃភាពក្រីក្រទៀតហើយ។

២) **តើដំណើរការនេះកំពុងត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវដែរឬទេ** ដើម្បីកំណត់អត្តសញ្ញាណគ្រួសារទាំងអស់ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យ និងចូលរួមក្នុងដំណើរការនេះ? ប្រសិនបើមិនបានត្រឹមត្រូវ គួរតែត្រួតពិនិត្យ និងការត្រួតពិនិត្យនៅនឹងកន្លែងឱ្យបានល្អប្រសើរដើម្បីធានានូវភាពត្រឹមត្រូវនៃដំណើរការនេះ។

៣ ) តើដំណើរការនេះ**មិនរាប់បញ្ចូលគ្រួសារ**ដែលអាចនឹងបំពេញតាមលក្ខណៈវិនិច្ឆ័យភាពក្រីក្រដែរឬទេ ? ប្រសិនបើមែន គួរសាកល្បងបង្កើនការផ្សព្វផ្សាយ ឬកែតម្រូវដំណើរការ ដើម្បីផ្តល់ ឱកាសឱ្យគ្រួសារក្រីក្រទាំងអស់ចូលរួមនៅក្នុងដំណើរការនេះ។

ការសិក្សាដើម្បីកំណត់ភាពត្រឹមត្រូវនៃយន្តការកំណត់មុខសញ្ញាត្រូវចំណាយខ្ពស់ និងមិនល្អឥតខ្ចោះនោះទេ ប៉ុន្តែអាចជួយកំណត់បានថាតើគ្រួសារក្រីក្រ ( ដូចដែលយន្តការបានកំណត់ ) ត្រូវបានធ្វើអត្តសញ្ញាណកម្មដែរឬទេ។ នៅឆ្នាំ ២០១១ ធនាគារពិភពលោក បានព្យាយាមប្រៀបធៀបគ្រួសារដែលត្រូវបានធ្វើអត្តសញ្ញាណថាជា " ក្រីក្រ " ដោយកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រជាមួយនឹងស្តង់ដារដទៃទៀត រួមមាន ការយល់ឃើញរបស់អ្នកភូមិ តាមរយៈអង្កេតដាច់ដោយឡែកមួយដែលបានធ្វើរយៈពេលប្រាំបីខែបន្ទាប់ពីបញ្ចប់ការប្រមូលទិន្នន័យគ្រួសារក្រីក្រតាមជុំ។ ដោយប្រើប្រាស់រង្វាស់នៃការយល់ឃើញរបស់អ្នកភូមិដែលចាត់ថា "ក្រខ្លាំង" "ក្រ" "មិនក្រ" ហើយប្រមាណជា១៤%នៃអ្នកដែលអ្នកភូមិយល់ថា" ក្រខ្លាំង " មិនត្រូវរាប់បញ្ចូលក្នុងបញ្ជីគ្រួសារក្រីក្រកម្រិតទី១ ឡើយ និងប្រមាណជា១២%នៃអ្នកដែលអ្នកភូមិយល់ថាមិនមែនក្រីក្រតែបែរជាត្រូវបានរាប់បញ្ចូលទៅក្នុងបញ្ជីគ្រួសារក្រីក្រទៅវិញ។ ភាគរយមិនរាប់បញ្ចូលកាន់តែខ្ពស់ ( 42,5% ) ត្រូវបានរកឃើញនៅពេលប្រៀបធៀបការយល់ឃើញរបស់អ្នកភូមិអំពីគ្រួសារក្រីក្រធៀបនឹងលទ្ធផលគ្រួសារក្រីក្រកម្រិតទី២ដែលឆ្លុះបញ្ចាំងពីភាពលំបាករឹតតែខ្លាំងនៃការវិនិច្ឆ័យដែលមានលក្ខណៈអត្តនោម័តអំពីភាពក្រីក្រដែលជាគ្រួសារស្ថិតនៅក្បែរកម្រិតគោលបើធៀបជាមួយអ្នកក្រីក្រខ្លាំង។

ចំណុចនេះនាំទៅដល់កត្តាទី២ ដែលថានិយមន័យផ្សេងគ្នានៃភាពក្រីក្រអាចនាំឱ្យមានលទ្ធផលផ្សេងគ្នា។ ឧទាហរណ៍សាមញ្ញមួយគឺថា កម្មវិធីអាចវាយតំលៃប្រាក់ចំណូល ឬទ្រព្យសម្បត្តិផ្ទាល់របស់បុគ្គលម្នាក់ៗ និងកំណត់អត្តសញ្ញាណបុគ្គលនោះថាជាអ្នកក្រ ទោះបីជាបុគ្គលរូបនោះរស់នៅក្នុងគ្រួសារជាមួយអ្នកដទៃ ដែលជារួម មិនមែនក្រីក្រតាមការកំណត់របស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្តី។

ទី៣ ទាក់ទងនឹងការប្រែប្រួលអំពីរបៀបកំណត់ភាពក្រីក្រ ឬលក្ខណៈវិនិច្ឆ័យ ឬការយល់ឃើញផ្ទាល់ខ្លួន ( ឧទាហរណ៍ ថាតើបុគ្គល ឬគ្រួសារដែលមើលទៅហាក់ដូចជាក្រីក្រ ) ជួនកាលពេលខ្លះត្រូវបានប្រើដើម្បីធ្វើការវិនិច្ឆ័យថាតើគ្រួសារមួយគួរមានស្ថានភាពជាគ្រួសារក្រីក្រដែរឬយ៉ាងណា។ លោក Ole Doetinchem មកពី GIZ និយាយថា " ប្រសិនបើអ្នកចង់វាយតម្លៃភាពត្រឹមត្រូវនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ អ្នកត្រូវប្រៀបធៀបវត្ថុដូចគ្នា។ ភាពក្រីក្រមិនមែនជាចំណុចទិន្នន័យគោលពីរនិងដែលអាចសង្កេតឃើញបាននោះទេ ហើយគ្មានការវាយតម្លៃណាមួយដែលអាចរក្សាបានជាមួយនឹងភាពពរបស់វាដែរ។ ប៉ុន្តែខ្ញុំនឹងជ្រើសយកការដាក់ពិន្ទុដែលមានលក្ខណៈជាប្រព័ន្ធជាមួយនឹងមតិយោបល់ពីសហគមន៍ចំពោះការយល់ឃើញផ្ទាល់របស់ខ្ញុំ។ '

របាយការណ៍របស់ធនាគារពិភពលោក ឆ្នាំ២០១១ ( សូមមើលប្រអប់ទី៤ ) បានបង្ហាញថា អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជារួមមានដំណើរការល្អ បើប្រៀបធៀបទៅនឹងប្រព័ន្ធនានានៅប្រទេសដទៃ និងបានផ្តល់អនុសាសន៍មួយចំនួនដើម្បីពង្រឹងបន្ថែមនូវទិដ្ឋភាពផ្សេងៗនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ រួមទាំងកម្រងសំណួរនៃឧបករណ៍វាស់វែងពីកម្រិតជីវភាព(ឧទាហរណ៍ ការពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពនូវសូចនាករដើម្បីរក្សាល្បឿនជាមួយសង្គមដូចជាភាពជាម្ចាស់នៃទូរស័ព្ទចល័តដែលលែងបង្ហាញពីទ្រព្យសម្បត្តិដែលគ្រប់គ្រងទិន្នន័យនានាដើម្បីឲ្យត្រូវគ្នាជាមួយការវិវត្តន៍សង្គម ) ការគ្រប់គ្រងទិន្នន័យ និងការអនុវត្តន៍ដំណើរការ។ ក្រសួងផែនការ ដោយមានការគាំទ្រពី GIZ បានពិចារណាអនុសាសន៍ទាំងនេះរួមជាមួយនឹងកង្វល់របស់ដៃគូ ហើយបានចាប់ផ្តើមដោះស្រាយបញ្ហាទាំងនោះជាលក្ខណៈប្រព័ន្ធ ដូចបានពណ៌នានៅផ្នែកជាបន្តបន្ទាប់។

ទោះបីជាក្រសួងផែនការ បន្តធ្វើការកែសម្រួលជាបន្តបន្ទាប់នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងអំឡុងដើមឆ្នាំដល់ពាក់កណ្តាលឆ្នាំនៃការអនុវត្តន៍យ៉ាងណាក៏ដោយ ក៏ដៃគូ និងអ្នកប្រើទិន្នន័យមានអារម្មណ៍ថាមន្ត្រីក្រសួង មិនបានប្រាស្រ័យទាក់ទងដោយចំហរនូវមតិត្រឡប់ និងបញ្ហាប្រឈម ឬសកម្មភាពអ្វីដែលពួកគេបានប្រកាន់យកក្នុងការឆ្លើយតបឡើយ។ ឥឡូវក្រសួងផែនការទទួលស្គាល់តម្រូវការឲ្យមានតម្លាភាពបន្ថែមទៀតក្នុងការកសាងទំនុកចិត្ត មិនត្រឹមតែជាមួយសហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែជាមួយដៃគូផងដែរ ដូចបានពណ៌នានៅចុងបញ្ចប់នៃជំពូកនេះ។

## ការរួមបញ្ចូលភាពក្រីក្របច្ចុប្បន្ននិងពលករចំណាកស្រុកទៅរកការងារធ្វើ

ខណៈដែលការកែសម្រួលជាបន្តបន្ទាប់ដើម្បីធ្វើឱ្យប្រសើរឡើងការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ទាំងក្រសួងផែនការ ទាំងដៃគូបានចាប់ផ្តើមដោះស្រាយមូលហេតុដទៃទៀតដែលគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះមួយចំនួននៅតែត្រូវបានដាក់បញ្ចូលក្នុងដំណើរការនៅឡើយ។

យោងតាម ឯកឧត្តម ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ បានឱ្យដឹងថាមូលហេតុសំខាន់មួយគឺសន្ទនីយភាពនៃស្ថានភាពក្រីក្ររបស់គ្រួសារ៖ " នៅកម្ពុជាប្រជាពលរដ្ឋធ្លាក់ចូល និងចាកផុតពីភាពក្រីក្រលឿនជាងការចាប់បាន(Capture)នៃវដ្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលមានរយៈពេលបីឆ្នាំ " ។ ថ្វីបើ ប្រជាជនប្រមាណជា២០ភាគរយប៉ុណ្ណោះ ដែលបំពេញលក្ខណៈវិនិច្ឆ័យក្នុងពេលណាមួយ ចំណែកឯ៥០%បន្ថែមទៀតងាយនឹងធ្លាក់ចូលក្នុងភាពក្រីក្រ។ ខណៈពេលដែលគ្រួសារទាំងនេះ ត្រឹមតែស្ថិតនៅពីលើខ្សែបន្ទាត់ភាពក្រីក្រ នៅពេលអត្តសញ្ញាណកម្មគ្រួសារក្រីក្រសម្ភាសពួកគេៗអាចធ្លាក់ចុះទាបជាងបន្ទាត់នៃភាពក្រីក្រនៅមុនជុំប្រមូលទិន្នន័យលើកក្រោយ ប៉ុន្តែគ្មានលក្ខណៈវិនិច្ឆ័យទទួលបានជាគ្រួសារក្រីក្រនៅពេលនោះ។ លើសពីនេះទៀត អ្នកដែលបានរៀបការ និងចាប់ផ្តើមមានគ្រួសារផ្ទាល់ខ្លួន ឬគ្រួសារដែលមានការចាប់កំណើត ឬការស្លាប់ធ្វើឲ្យប៉ះពាល់ដល់ស្ថានភាពក្រីក្ររបស់ពួកគេ ក៏ត្រូវរង់ចាំដល់អត្តសញ្ញាណកម្មគ្រួសារក្រីក្រជុំបន្ទាប់ទើបត្រូវបានកំណត់អត្តសញ្ញាណថាជាគ្រួសារក្រីក្រ។

មូលហេតុមួយទៀតគឺថា ប្រជាជនកម្ពុជាចំនួន៤លាននាក់គឺជាជនចំណាកស្រុកស្វែងរកការងារ ឬមួយពួកគេបែងចែកឆ្នាំរស់នៅរវាងលំនៅដ្ឋានពីរ ឬមួយបន្តទៅរកការងារធ្វើជាប្រចាំ ( សូមមើលប្រអប់៥ជាឧទាហរណ៍ស្រាប់ ) ( វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០១៣ ) ។ ជាទូទៅលំនាំនេះមិនសូវមានទេក្នុងឆ្នាំ២០០៥ នៅពេលកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រកំពុងត្រូវបានបង្កើតឡើង ប៉ុន្តែបច្ចុប្បន្ន លំនាំនេះមានផលប៉ះពាល់មកលើប្រជាជនកម្ពុជាម្នាក់ក្នុងចំណោមបួននាក់ទំនងជាអ្នកក្រ។

### *អត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅកន្លែងផ្តល់សេវា ៖ ជំហានដំបូងដើម្បីបន្ថយគំលាតការទទួលបានការថៃទាំសុខភាព*

ដើម្បីបំពេញបន្ថែមចំណុចខ្វះខាតទាំងនេះ កម្មវិធីសំខាន់ៗដែលផ្តោតលើអ្នកក្រីក្រជាពិសេស មូលនិធិសមធម៌សុខាភិបាល ដែលជាដំណោះស្រាយបណ្តោះអាសន្ន។

នៅពេលអ្នកជំងឺក្រីក្រដែលមិនមានប័ណ្ណសមធម៌ មកកាន់មណ្ឌលសុខភាពប្រតិបត្តិករមូលនិធិសមធម៌ ដែលត្រូវបានអនុញ្ញាតដោយក្រសួងសុខាភិបាលឲ្យប្រើកម្រងសំណួរ " អត្តសញ្ញាណកម្មអ្នកជំងឺក្រីក្រ " ដែលយកតាមគំរូដែលប្រើដោយកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីកំណត់ថាតើអ្នកជំងឺពិតជាមានជីវភាពក្រីក្រឬយ៉ាងណា ? បើឆ្លើយថា ក្រ ពួកគេនឹងទទួលបានប័ណ្ណអាទិភាពដើម្បីទទួលបានសេវាសុខភាពដោយមិនបង់ថ្លៃ។ ក្នុងករណីមួយចំនួន បុគ្គលិកសុខាភិបាលបញ្ជូនអ្នកជំងឺទៅកាន់ប្រតិបត្តិករមូលនិធិសមធម៌សុខាភិបាល នៅពេលពួកគេដឹងថាអ្នកជំងឺមិនអាចបង់ថ្លៃសេវាថៃទាំសុខភាព។ ក្នុងករណីផ្សេងទៀត ប្រជាជនយកសំបុត្របញ្ជាក់ពីមេភូមិរបស់ពួកគេដែលបញ្ជាក់ថាពួកគេរស់នៅក្នុងភូមិ ហើយក្រីក្រ ទោះបីជាគ្មានប័ណ្ណបញ្ជាក់ស្ថានភាពគ្រួសារក្រីក្រក៏ដោយ។

ដូចអ្នកទទួលផលពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែរ អ្នកកាន់ប័ណ្ណអាទិភាពមានសិទ្ធិទទួលបានសេវាសុខភាពដោយឥតគិតថ្លៃ និងថ្លៃចំណាយលើការដឹកជញ្ជូន និងប្រាក់ឧបត្ថម្ភអាហារប្រចាំថ្ងៃនៅមន្ទីរពេទ្យ ទោះជាពួកគេមិនទទួលបានអត្ថប្រយោជន៍ផ្សេងទៀតដែលមានភ្ជាប់ទៅនឹងប័ណ្ណក្រីក្រក្តី។ ទិន្នន័យរបស់ពួកគេត្រូវបានបញ្ជូនទៅមន្ទីរផែនការខេត្តដើម្បីឲ្យប្រាកដថាឈ្មោះរបស់ពួកគេត្រូវបានដាក់បញ្ចូលបញ្ជីគ្រួសារក្រីក្រនៅជុំបន្ទាប់។

យោងតាមការវិភាគមួយនៅឆ្នាំ២០១៦ របស់ University Research Co. (URC) ជាដៃគូនៃមូលនិធិសមធម៌សុខាភិបាល ក្នុងចំណោមប្រជាជនប្រមាណជា៣លាននាក់ដែលត្រូវបានផ្តល់ជូនតាមរយៈមូលនិធិសមធម៌សុខាភិបាល ប្រជាជនភាគច្រើន (93%) មានប័ណ្ណសមធម៌ ធៀបនឹងត្រឹមតែ 7% ប៉ុណ្ណោះដែលត្រូវបានកំណត់អត្តសញ្ញាណនៅកន្លែងផ្តល់សេវា។

គុណវិបត្តិនៃដំណើរការអត្តសញ្ញាណកម្មនៅកន្លែងផ្តល់សេវាគឺកាន់តែងាយកើតឡើងនូវភាពមិនប្រក្រតីមួយចំនួន ព្រោះថាអត្តសញ្ញណកម្មនៅកន្លែងផ្តល់សេវាប្រព្រឹត្តទៅនៅនឹងកន្លែងដែលមានទីតាំងនៅមណ្ឌលសុខភាពដែលគេមិនអាចមើលឃើញ ឬផ្ទៀងផ្ទាត់បានឡើយ។ ការកំណត់អត្តសញ្ញាណនៅកន្លែងផ្តល់សេវាត្រូវបានគ្រប់គ្រងដោយក្រសួងសុខាភិបាល ហើយក្រសួងផែនការដែលមានអាណត្តិការងារក្នុងការគ្រប់គ្រងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

ប៉ុន្តែបើគ្មានការកំណត់អត្តសញ្ញាណនៅកន្លែងផ្តល់សេវាមន្ទីរពេទ្យត្រូវគិតនូវថ្លៃចំណាយក្នុងការព្យាបាលអ្នកជំងឺក្រីក្រដែលគ្មានប័ណ្ណសមធម៌ ឬអ្នកជំងឺក្រីក្រត្រូវតែលក់ទ្រព្យសម្បត្តិសំខាន់ៗ ឬខ្ចីប្រាក់គេ ទោះជាពួកគេបំពេញតាមលក្ខណៈវិនិច្ឆ័យដើម្បីបានមូលនិធិសមធម៌សុខាភិបាលក្តី។ ប្រធានមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង លោកវេជ្ជបណ្ឌិត សូរិន ធីរ៉ាវុទ្ធី បាននិយាយថា មន្ទីរពេទ្យរបស់លោកប្រហែលជាត្រូវបិទទ្វារ ប្រសិនបើគ្មានមូលនិធិសមធម៌សុខភាព និងគ្មានកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

## ប្រអប់៥៖ ភាពជាប់គាំងនៃចំណាកស្រុក

អ្នកស្រី កេង សំព័រ អង្គុយនៅផ្ទះឪពុកម្តាយគាត់ ហើយផ្ទូតទឹកកូនប្រុសតូចរបស់គាត់ថ្មមៗ ខណៈដែលកូនពីរនាក់ទៀតដែលមានអាយុ២ឆ្នាំ និង ៣ឆ្នាំកំពុងលេងនៅក្បែរនោះ។ គាត់មានអាយុ២៤ឆ្នាំជាកូនម្នាក់ក្នុងចំណោមកូនប្រាំមួយនាក់ កូនទាំងអស់លើកលែងតែកូនម្នាក់ដែលបានចាកចេញពីផ្ទះឪពុកម្តាយទៅរកការងារធ្វើ ឬបានរៀបអាពាហ៍ពិពាហ៍ហើយ។

ឪពុកម្តាយរបស់សំព័រគឺ លោក កុល និងអ្នកស្រី តឹន ស្ថិតក្នុងវ័យ 50 ឆ្នាំ អ្នកទាំងពីរមានពិការភាពពីសម័យខ្មែរក្រហម និងក្រោយសម័យនោះ នៅពេលដែលពួកឧទ្ទាមបានលាក់ខ្លួននៅលើភ្នំហើយវាយប្រហារភូមិនានា។ លោក កុល មានរបួសជើងដែលធ្វើឲ្យគាត់ពិបាកទៅណាមកណា ចំណែកអ្នកស្រី តឹន វិញ មានស្លាកស្នាមរបួសនៅលើស្មារបស់គាត់។ លោក កុល អាចខ្ចីម៉ូតូកូនប្រុសគាត់ពីរឬបីដងក្នុងមួយខែ ធ្វើដំណើរទៅនេសាទបានខ្លះគ្រាន់បានរកចំណូលបន្ថែម។ ក្រៅពីនោះ  គាត់រកលុយដោយលក់ពលកម្មឱ្យគេ ដើម្បីប្តូរយកលុយកាក់ ឬម្ហូបអាហារ។



ចំណងជើង៖ អ្នកស្រី ខេង សំព័រ នៅទីនេះជាមួយកូនស្រីនិងកូនតូចរបស់នាង ខកខានមិនបានចូលរួមក្នុងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជុំចុងចុងក្រោយ ដោយសារធ្វើចំណាកស្រុកទៅរក

លោក កុល និងអ្នកស្រី តឹន មានប័ណ្ណក្រីក្ររយៈពេល៦ឆ្នាំមកហើយ។ ពួកគាត់បានចូលរួមក្នុងដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជុំចុងក្រោយក្នុងឆ្នាំ២០១៦ និងត្រូវបានកំណត់អត្តសញ្ញាណថានៅតែមានសិទ្ធិទទួលចំណាត់ថ្នាក់ជាគ្រួសារក្រីក្រ។ លោក កុល មិនចេះអាន ឬ សរសេរឡើយ គាត់មានជំងឺបេះដូង ហើយទៅមន្ទីរពេទ្យរៀងរាល់ពីរបីខែម្តង។ បើគ្មានប័ណ្ណសមធម៌ទេ គាត់ថាគាត់នឹងមិនខ្វល់ទៅមន្ទីរពេទ្យឡើយព្រោះពួកគាត់គ្មានលុយបង់ថ្លៃមន្ទីរពេទ្យទេ។

អ្នកស្រី សំព័រ ធ្លាប់មានឈ្មោះនៅលើប័ណ្ណសមធម៌របស់ឪពុកម្តាយគាត់ ហើយនៅពេលដែលគាត់រៀបការ គាត់ និង លោក ឡៅ ជាប្តីក៏ទទួលបានចំណាត់ថ្នាក់គ្រួសារក្រីក្រក្នុងឆ្នាំ២០១៣ដែរ។ ទោះយ៉ាងណាក្តី អ្នកទាំងពីរបានខកខានក្នុងការសម្ភាសន៍គ្រួសារនៅជុំចុងក្រោយ ដោយសារពួកគេរស់នៅកន្លែងផ្សេងទៀតពីខេត្តដែលលោក ឡៅ រកបានការងារសំណង់។ សព្វថ្ងៃឈ្មោះរបស់ពួកគាត់មិនមានឈ្មោះនៅក្នុងបញ្ជីគ្រួសារក្រីក្របន្តបីឆ្នាំទៀតឡើយ។

អ្នកស្រី សំព័រ និង លោក ឡៅ បានវិលត្រឡប់មកភូមិស្ថានវិញនៅពេលដែលកូនរបស់ពួកគាត់ឈ្មោះសីហា កើតមិនគ្រប់ខែ (ពីរខែមុនកាលកំណត់)។ ពេលនេះ សីហា អាយុ៤ខែ កំពុងមានជំងឺឈឺធ្ងន់ធ្ងរ។ ទ្រូងរបស់វាប៉ោងផតៗដោយសារវាប្រឹងដកដង្ហើម រីឯជើងរបស់វាស្វាបទៅត្រជាក់ស្រិប បើទោះបីជាមានកំដៅកាន់តែក្តៅឡើងនាពេលព្រឹកក្តី។ កាលពីសីហា ទើបកើតភ្លាមៗ គ្រូពេទ្យបានប្រាប់ថា សីហាមានបេះដូងប្រហោង។ មណ្ឌលសុខភាពមិនអាចគ្រប់គ្រងថែទាំជំងឺរបស់សីហាបានឡើយ គ្រូពេទ្យបានណែនាំអ្នកស្រី សំព័រ និង លោក ឡៅ យកកូនទៅមន្ទីរពេទ្យសប្បុរសធម៌សម្រាប់កុមារនៅភ្នំពេញដែលមានចម្ងាយជាង៩០គីឡូម៉ែត្រ ដែលព្យាបាលជំងឺឥតគិតថ្លៃ។ មន្ទីរពេទ្យនោះ បានបញ្ជូនគ្រួសារនេះទៅផ្ទះវិញ ដោយផ្តល់ថ្នាំពេទ្យសម្រាប់រយៈពេលពីរបីខែ ហើយពេទ្យប្រាប់ថា សីហាអាចត្រូវការការវះកាត់ ប្រសិនបើប្រហោងបេះដូងមិនជិតទៅវិញដោយខ្លួនឯង។ ពេលនោះ បេះដូងសីហាអាចឈប់លោត។

ឥឡូវវិលត្រឡប់មកភូមិវិញ អ្នកស្រី សំព័រ និងលោក ឡៅ ត្រូវចំណាយប្រាក់ដើម្បីបង់ថ្លៃថ្នាំពេទ្យ។ ឥឡូវពួកគាត់គ្រោងស្នាក់នៅភូមិ ហើយនឹងស្នើសុំលិខិតពីប្រធានភូមិឲ្យបញ្ជាក់ថាពួកគេក្រីក្រ ដើម្បីឲ្យពួកគេអាចទទួលបានប័ណ្ណអាទិភាពក្រោយអត្តសញ្ញាណកម្ម ដើម្បីទទួលបានសេវាសុខភាព។

*' អត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ ,៖ រយៈពេលមួយឆ្នាំនៃការអនុវត្តសាកល្បងអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ*

ប្រធានកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដឹងថាដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ ជាកិច្ចការបន្ទាន់ និងឆ្លើយតបកាន់តែប្រសើរជាងមុន ព្រោះថាវាជាវិធានប្រសើរមួយក្នុងការពិនិត្យបន្ថែមទៀត ដូចជា អត្តសញ្ញាណកម្មអ្នកជំងឺក្រីក្រជាដើម។ នៅខែមេសាឆ្នាំ២០១៧ ក្រសួងផែនការបានរៀបចំតច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីពិនិត្យឡើងវិញនូវជម្រើសដែលអាចធ្វើទៅបាន ចំពោះដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ ដែលត្រូវបានរៀបចំឡើងដើម្បីវាយតម្លៃគ្រួសារដែលសង្ស័យថាមានជីវភាពក្រីក្រក្នុងចន្លោះជុំប្រមូលទិន្នន័យនានា និងធ្វើបច្ចុប្បន្នកម្មព័ត៌មានអំពីគ្រួសារក្រីក្រដែលត្រូវបានកំណត់អត្តសញ្ញាណរួចហើយ។

ជម្រើសល្អមួយដែលបានកើតឡើង៖ សមាជិកក្រុមប្រឹក្សាឃុំនឹងទទួលសំណើសុំអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងចុះសំភាសន៍ដោយប្រើប្រាស់កម្រងសំណួរដែលមានទម្រង់ជាក្រដាស ឬប្រើគ្រឿងឧបករណ៍អេឡិកត្រូនិច ដូចជា ស្មាតហ្វូន ឬថេប្លេត។ ក្រុមប្រឹក្សាឃុំនឹងពិចារណាលើសំណូមពរនានាក្នុងអំឡុងកិច្ចប្រជុំប្រចាំខែរបស់ខ្លួន ហើយបញ្ជូនសមាជិកក្រុមប្រឹក្សាម្នាក់មកធ្វើសំភាសន៍ដោយមានការគាំទ្រពីប្រធានភូមិក្នុងរយៈពេលខ្លី។ បន្ទាប់មក ក្រុមប្រឹក្សានឹងធ្វើការសម្រេចចិត្តចុងក្រោយ ផ្អែកលើលទ្ធផលនៃកម្រងសំណួរ រួមទាំងស្ថានភាពពិសេស ដូចក្នុងដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រស្តង់ដារដែរ។ ប្រសិនបើប្រើគ្រឿងឧបករណ៍អេឡិកត្រូនិច គេនឹងអាចមានទិន្នន័យភ្លាមៗនៅក្នុងមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រជាមួយនឹងរូបថតគ្រួសារ។

ដូចការអនុវត្តកន្លងមកដែរ នៅពេលពិចារណាពីរបៀបកែលម្អដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បញ្ហាប្រឈមចំបងមួយគឺ វិធីរក្សាការចូលរួមរបស់សហគមន៍ដែលជាសកម្មភាពសំខាន់នៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ យោងតាមលោកស្រី Sabine Cerceau ទីប្រឹក្សាជីអាយហ្សិតគាំទ្រកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ កំពុងពិចារណាយ៉ាងយកចិត្តទុកដាក់ថ្លឹងថ្លែងនូវត្រឹមត្រូវ។ ធាតុចូលពីសហគមន៍មានសារៈសំខាន់ណាស់ចំពោះអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ហើយក្នុងពេលជាមួយគ្នានោះមានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងក្នុងការអនុញ្ញាតឱ្យមានការចុះឈ្មោះគ្រួសារក្រីក្រ នៅក្នុងចន្លោះជុំប្រមូលទិន្នន័យនីមួយៗ។ គោលដៅគឺដើម្បីរក្សាការចូលរួមប្រកបដោយអត្ថន័យ ហើយទន្ទឹមនឹងនោះបន្ថែមភាពបត់បែន និងការឆ្លើយតបបានទាន់ពេលាទៀតផង។

មតិយោបល់មួយចំនួនដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់បានលើកទឹកចិត្តក្រសួងផែនការ ដើម្បីពិចារណាថា តើក្រុមតំណាងភូមិដែលជាអ្នកយល់ដឹងអំពីសហគមន៍ អាចនៅតែមានតួនាទី ដូចជា សមាជិកក្រុមតំណាងភូមិចូលរួមកិច្ចសម្ភាសន៍ជាមួយសមាជិកក្រុមប្រឹក្សាឃុំដោយរបៀបណា។ ទោះជាយ៉ាងណាក៏ដោយ ភូមិទាំងមូលគ្មានឱកាសពិនិត្យមើល និងផ្តល់យោបល់អំពីស្ថានភាពគ្រួសារឡើយ ឬយ៉ាងហោចណាស់គ្មានឱកាសរហូតដល់ការធ្វើបច្ចុប្បន្នកម្មទិន្នន័យជុំបន្ទាប់។

ក្រសួងផែនការ បានចាប់ផ្តើមអនុវត្តសាកល្បងជម្រើសជាច្រើនក្នុងរយៈពេល១២ខែ នៅត្រីមាសទីបីឆ្នាំ២០១៧ រួមទាំងការសិក្សាថ្លៃចំណាយ និងការវិភាគយ៉ាងប្រុងប្រយ័ត្នអំពីសមត្ថភាពនៅមូលដ្ឋានក្នុងការប្រើប្រាស់បច្ចេកវិទ្យាចល័ត។ អាស្រ័យលើលទ្ធផល ការពង្រីកប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ អាចចាប់ផ្តើមជាផ្លូវការនៅឆ្នាំ២០១៩។ ការផ្តល់ហិរញ្ញប្បទាន និងការគាំទ្រផ្នែកបច្ចេកទេសសម្រាប់អនុវត្តសាកល្បង បង្ហាញនូវចំណាប់អារម្មណ៍យ៉ាងច្រើនក្នុងចំណោមដៃគូអភិវឌ្ឍន៍ ក្នុងការកែសម្រួលដែលមានសក្តានុពលនេះ៖ UNICEF, USAID តាមរយៈ Save the Children និងកម្មវិធីស្បៀងអាហារពិភពលោក សុទ្ធតែរួមចំណែកបន្ថែមលើការផ្តល់ហិរញ្ញប្បទានពីរដ្ឋាភិបាលអាល្លឺម៉ង់ និងអូស្ត្រាលី។

## ការឈានដល់អ្នកក្រីក្រនៅទីប្រជុំជន

ទោះបីជា អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានគេមើលឃើញថាជាយន្តការមួយសម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅតាមជនបទ ដោយសារមានប្រជាជនតំណាងឱ្យ៩០ភាគរយនៃចំនួនប្រជាជនក្រីក្រនៅកម្ពុជា។ ការកើនឡើងនៃការធ្វើចំណាកស្រុកទៅកាន់ទីក្រុង បានធ្វើឱ្យរដ្ឋាភិបាលកម្ពុជា និងដៃគូចាប់អារម្មណ៍កាន់តែខ្លាំងឡើងក្នុងការផ្តោតលើតំបន់ទីក្រុងដែលពីមុនមិនបានទទួលសេវាបានគ្រប់គ្រាន់[4] ។ ចំនួនប្រជាជននៅរាជធានីភ្នំពេញតែមួយគត់ ដែលជារាជធានី និងជាទីក្រុងធំបំផុតរបស់ប្រទេសកម្ពុជា បានកើនឡើងទ្វេដងចាប់តាំងពីឆ្នាំ២០០៨ គឺពីចំនួនប្រជាជនប្រមាណជា ១,៥ លានទៅ ៣លាននាក់ ដែលស្មើនឹងប្រជាជនម្នាក់ក្នុងចំណោមប្រជាជនកម្ពុជា៥នាក់។

ការិយាល័យជនក្រីក្រកដែលស្ថិតនៅក្នុងសាលារាជធានីរាជធានីភ្នំពេញត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១០ ក្នុងពេលដែលប្រជាជនមានកំណើនខ្ពស់ជាខ្លាំង ដែលទិន្នន័យនេះ បានរកឃើញនៅក្នុងការអង្កេតគោលក្នុងឆ្នាំ ២០១២ មានសំណង់មិនរៀបរយចំនួន ៥១៦កន្លែងក្នុងរាជធានី ដែលត្រូវបានគេកំណត់ថាជាសហគមន៍ក្រៅប្រព័ន្ធហើយយ៉ាងហោចណាស់៣០គ្រួសារបានសាងសង់លើដីសាធារណៈ (រាជធានីភ្នំពេញឆ្នាំ២០១២)។ ហានិភ័យផ្នែកសុខភាព និងសុវត្ថិភាពមានជាច្រើន៖ ការតាំងលំនៅទាំងនោះច្រើនតែសាងសង់នៅជិតបំពង់លូទឹកសំអុយ ផ្លូវដែក ឬផ្លូវទឹកតូចៗ និងខ្វះហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ដូចជា ទឹកស្អាត បង្គន់ ផ្លូវថ្នល់ អគ្គីសនី និងការប្រមូលសំរាម។ ប្រជាជនប្រហែល ២៥០.០០០នាក់រស់នៅក្នុងសហគមន៍ទាំងនេះ ក្នុងឆ្នាំ២០១២ ដែលពួកគេចំនួន៦០% រស់នៅដោយចំណាយប្រាក់តិចជាង 0,50 € ក្នុងមួយថ្ងៃ ហើយគ្រួសារច្រើនជាង៨០% ជាប់បំណុលដោយសារថ្លៃថ្នាំពេទ្យ ឬខ្ចីប្រាក់ដើម្បីចាប់ផ្តើមអាជីវកម្មខ្នាតតូច។

ក្នុងខែមេសា ឆ្នាំ២០១៤ ក្រសួងផែនការ បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធសំខាន់ៗ រួមមានក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន បន្ទាប់មកក្រុមការងារមួយបានពិនិត្យឡើងវិញ និងបានស្នើឲ្យមានការកែសម្រួលដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងកម្រងសំណួរ។ នៅឆ្នាំ២០១៦ ដំណើរការកែសម្រួលត្រូវបានសាកល្បងនៅតំបន់ទីប្រជុំជនចំនួនបីគឺ ទីក្រុងភ្នំពេញ ខេត្តកំពត និងខេត្តកំពង់ធំ។

[4] ជាក់ស្តែង ផ្នែកខ្លះនៃរាជធានីភ្នំពេញ បានធ្វើអត្តសញ្ញាណកម្មគ្រយសារក្រីក្រ ជាលើកដំបូងនៅឆ្នាំ២០១២ ចាប់តាំងពី " ជនបទ" ត្រូវបានកំណត់នៅក្នុងអនុក្រឹត្យថាជាភូមិមួយដែលមានគ្រួសារយ៉ាងតិច៥០% មានមុខរបរផ្អែកលើកសិកម្ម។ រាជធានីភ្នំពេញមានប្រមាណជា៩០០ 'ភូមិ' ក្នុងនោះ៤០០ភូមិជនបទ។

ស្ថានភាពប្រែប្រួលនៃចំនួនប្រជាជននៅតំបន់ទីប្រជុំជន មានន័យថាអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មិនអាចពឹងផ្អែកលើបណ្តាញទំនាក់ទំនងដែលមានស្ថេរភាព និងចំណេះដឹងផ្ទាល់អំពីគ្រួសារដែលបង្ហាញលក្ខណៈជាសហគមន៍ជនបទ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រុមការងារកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានបន្ថែមក្រុមដៃគូគាំទ្រមួយទៅក្នុងដំណើរការនេះ ដែលរួមមានតំណាងនៅមូលដ្ឋាន និងអង្គការនានា (ដែលមានវត្តមានជាយូរមកហើយនៅក្នុងសហគមន៍) អង្គភាពនានារបស់ក្រុង ដូចជា គណៈកម្មាធិការស្ត្រី និងកុមារ ប្រតិបត្តិករមូលនិធិសមធម៌សុខាភិបាល មេដឹកនាំសាសនា និងការិយាល័យជនពិការកម្ពុជា។ ក្រុមដៃគូគាំទ្រទាំងនេះជួយក្រុមតំណាងភូមិនៅតាមទីក្រុងក្នុងការកំណត់អត្តសញ្ញាណគ្រួសារដើម្បីសម្ភាស ជាមួយនឹងចំណេះដឹងមូលដ្ឋានខ្ពស់របស់ពួកគេជំនួសឱ្យទំនាក់ទំនងផ្ទាល់ខ្លួននៅសហគមន៍ ដែលជាមូលដ្ឋាននៃដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅទីប្រជុំជន។

ការកែសម្រួលមួយផ្សេងទៀតគឺថា បញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង និងបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ ត្រូវបានដាក់បង្ហាញរយៈពេល១០ថ្ងៃ មិនមែនបីថ្ងៃ ហើយលិខិតអញ្ជើញត្រូវបានផ្តល់ទៅឱ្យគ្រួសារដែលសង្ស័យថាជាគ្រួសារក្រីក្រ ទន្ទឹមនឹងការប្រកាសនៅតាមស្ថានីយវិទ្យុ និងទូរទស្សន៍ក្នុងស្រុក។ ដោយសារការសាកល្បងបានបង្ហាញថា អាចមានការប្រឈមមុខកាន់តែច្រើននៅទីប្រជុំជន ជាងនៅតាមទីជនបទក្នុងការស្វែងរកអ្នកនៅផ្ទះដើម្បីសម្ភាស អ្នកសម្ភាសន៍មួយក្រុមត្រូវបានចាត់ឲ្យតាមមើលគ្រួសារទាំងអស់ ដែលអ្នកសម្ភាសន៍ខកខានមិនបានសម្ភាសក្នុងអំឡុងពេលសម្ភាសន៍។

ការវាស់វែងភាពក្រីក្រ ក៏ត្រូវបានកែសម្រួលផងដែរ ដើម្បីគណនាពីភាពខុសគ្នានៃទ្រព្យសម្បត្តិ និងការចំណាយនៅទីប្រជុំជន។ គ្រួសារមានចំនួនតិចតួចដែលមានផ្ទះសម្បែង ហើយការរស់នៅរបស់គេ ត្រូវចាយវាយប្រាក់ច្រើនជាងនៅតាមទីជនបទ ដែលគេនៅតែលក់កម្លាំងពលកម្ម ប្តូរយកស្បៀងអាហារបាន។ នៅទីក្រុង ការគ្មានគោ ឬគ្មានមាន់គឺជារឿងធម្មតា ចំណែកឯការមានម៉ូតូ ឬមានអគ្គិសនីប្រើប្រាស់វិញ មិនសូវមានភាពហ៊ឺហាដូចនៅទីជនបទឡើយ។

សូចនាកវាស់វែងពីកម្រិតជីវភាពនៅក្នុងកម្រងសំណួរសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រទីប្រជុំជន ក៏បានដាក់បញ្ចូលសំណួរថ្មីៗអំពីប្រាក់ចំណូល (ជាចំនួនទឹកប្រាក់ជាក់លាក់ក្នុងមួយខែ) បំណុល ការប្រើប្រាស់ទឹកស្អាត និងភ្លើងអគ្គីសនីប្រើប្រាស់ ព្រមទាំងមុខរបរមួយចំនួនសម្រាប់អ្នកក្រីក្រនៅទីប្រជុំជន ដូចជា ការរើសសម្រាម និងការងារតាមរដូវ ជាដើម។

កម្រងសំណួរសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រទីប្រជុំជន ក៏ចាត់ទុកជំងឺរ៉ាំរ៉ៃ ពិការភាព និងកម្រិតអប់រំរបស់មនុស្សពេញវ័យ និងការចូលសាលារៀនរបស់កុមារនៃសមាជិកគ្រួសារ ជាសូចនាករតំណាងដែលត្រូវបានដាក់ពិន្ទុ ចំណែកឯនៅក្នុងដំណើរការនៅជនបទវិញ សូចនាករទាំងនេះគឺជាផ្នែកមួយនៃផ្នែកស្ថានភាពពិសេស ដែលមិនមានដាក់ពិន្ទុ។ ផ្នែកស្ថានភាពពិសេសដែលមិនមានដាក់ដាក់ពិន្ទុនៅតាមទីប្រជុំជន រួមបញ្ចូលទាំងសូចនាករស្តីពីភាពងាយរងគ្រោះបន្ថែមទៀត ដូចជា អំពើហិង្សាក្នុងគ្រួសារ ការញៀន ឬការរស់នៅក្នុងស្ថានភាពចង្អៀតកកកុញ។ ការផ្លាស់ប្តូរទាំងអស់នេះចំពោះកម្រងសំណួរ ត្រូវបានរៀបចំឡើងដើម្បីបង្ហាញឱ្យបានច្បាស់លាស់នូវភាពក្រីក្រពហុវិជ្ជភាពនៃគ្រួសារនៅទីប្រជុំជន ហើយក៏ជាឱកាសសម្រាប់ធ្វើតេស្តអំពីការផ្លាស់ប្តូរនានាដែលកម្រងសំណួរជនបទអាចទទួលបានអត្ថប្រយោជន៍ផងដែរ។

ការកែតម្រូវចុងក្រោយគឺថានៅពេលដែលបញ្ជីគ្រួសារក្រីក្រ ត្រូវបានពិនិត្យមើលត្រឹមត្រូវហើយ ក្រុមការងារសង្កាត់ធ្វើលិខិតបញ្ជាក់អត្តសញ្ញាណគ្រួសារក្រីក្រ ហើយចែកលិខិតទាំងនោះទៅឲ្យគ្រួសារទាំងអស់ដែលត្រូវបានកំណត់ថាជាគ្រួសារក្រីក្រ។ លិខិតទាំងនោះគឺជាភស្តុតាងអំពីស្ថានភាពគ្រួសារក្រីក្ររបស់ពួកគេ រហូតដល់ពួកគេទទួលបានប័ណ្ណសមធម៌។ នេះគឺជាការច្នៃប្រឌិតថ្មីមួយទៀតដែលបង្ហាញឲ្យឃើញថា នៅពេលទទួលបានជោគជ័យនៅទីប្រជុំជនក្នុងជុំដំបូងក៏អាចយកទៅប្រើប្រាស់ក្នុងដំណើរការនៅជនបទផងដែរ។

## ប្រអប់៦៖ ការរំពឹងទុកដ៏ត្រចេះត្រចង់ចំពោះកូនស្រីរបស់ យ៉ានី



ចំណងជើង៖ សមាជិក VRG ម្នាក់នៅសង្កាត់ទឹកល្អក់ក្រុងភ្នំពេញធ្វើសម្ភាសន៍អ្នកស្រី សាន យ៉ានី នៅឯជំរកបណ្តោះអាសន្នរបស់នាងនៅចន្លោះផ្លូវរថភ្លើងពីរខ្សែ។

គ្រួសារក្រីក្រជាច្រើនរស់នៅ ក្បែរផ្លូវដែកក្នុងរាជធានីភ្នំពេញ ប្រកបដោយគ្រោះថ្នាក់។ អ្នកស្រី សាន យ៉ានី អាយុ៥៩ឆ្នាំ ធ្លាប់រស់នៅក្នុងបន្ទប់ជួលជាមួយកូនស្រីអាយុ៣៧ឆ្នាំ និងចៅស្រីអាយុ១ឆ្នាំ។ ដោយសារបង្គន់អនាម័យរបស់ពួកគាត់ ហៀរហូរហើយម្ចាស់ផ្ទះបានបដិសេធមិនដោះស្រាយបញ្ហានោះ ក្រុមគ្រួសារបានសាងសង់ និងបានប្តូរទៅកាន់ជម្រកបណ្តោះអាសន្ននៅក្បែរផ្លូវរថភ្លើង។ ពួកគេបាននៅទីនោះអស់រយៈពេលមួយខែរួចមកហើយៗកំពុងព្យាយាមសន្សំប្រាក់ឲ្យបានគ្រប់គ្រាន់ដើម្បីជួលបន្ទប់មួយផ្សេងទៀតនៅក្នុងតំបន់នេះ។ បច្ចុប្បន្នពួកគេមិនបង់ថ្លៃជួលផ្ទះទេប៉ុន្តែខ្លាចអាជ្ញាធរផ្លូវរថភ្លើងនឹងបណ្តេញពួកគេក្នុងពេលឆាប់ៗ។ រថភ្លើងឆ្លងកាត់ខ្សែរថនេះប្រហែលបួនដងក្នុងមួយថ្ងៃ។

កូនស្រីរបស់អ្នកស្រី យ៉ានី មានបញ្ហាក្នុងការដើរ ដោយសារតែមានពិការភាពពីកំណើត។ ថ្មីៗនេះអ្នកស្រីក៏រងការឈឺខ្នង ប៉ុន្តែជាមួយនឹងប្រាក់ចំណូលបន្តិចបន្តួចដែលគាត់ និងកូនស្រីគាត់ស៊ីឈ្នួលបោកគក់ឲ្យអ្នកជិតខាង គាត់មានប្រាក់មិនគ្រប់គ្រាន់ដើម្បីទៅជួបគ្រូពេទ្យឡើយ។ ជួនកាលមន្ត្រីក្រុមប្រឹក្សាសង្កាត់ផ្តល់អាហារ និងអំណោយនិងជាប្រាក់ឧបត្ថម្ភដល់គ្រួសារគាត់ ហើយអ្នកជិតខាងមួយចំនួនក៏បានផ្តល់អាហារផងដែរ។ ឥឡូវអត្តសញ្ញាណកម្មគ្រួសារក្រីក្រកំពុងចូលទៅដល់តំបន់ទីក្រុង អ្នកស្រី យ៉ានី និងគ្រួសារមានឱកាសទទួលបានប័ណ្ណសមធម៌មួយ ដែលនឹងផ្តល់នូវការថែទាំសុខភាពនិងសេវាផ្សេងៗទៀតដោយឥតបង់ប្រាក់។

## ការសម្រួលដល់ការប្រមូល និងការផ្ទេរទិន្នន័យ៖ ពីការប្រើក្រដាសស្នាមទៅការប្រើប្រព័ន្ធឌីជីថល

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានវិវត្តវិធីសាស្ត្រទៅជាការគ្រប់គ្រងទិន្នន័យ និងការប្រើប្រាស់ទិន្នន័យក្នុងរយៈពេលជាច្រើនឆ្នាំ ដែលជាផ្នែកសំខាន់ទីពីរនៃការកែសម្រួល។ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មានចេតនាទទួលយកព័ត៌មានវិទ្យាមកប្រើប្រាស់បន្តិចម្តងៗដោយហេតុផលផ្សេងៗ ទី១ សមត្ថភាពរបស់អ្នកភូមិនៅទីជនបទក្នុងការប្រើថេប្លេត ឬស្មាតហ្វូនសម្រាប់បញ្ចូលទិន្នន័យ មានកម្រិតទាបពេកក្នុងការធ្វើឱ្យបច្ចេកវិទ្យាទាំងនេះ។ជាក់ស្តែងទើបតែពេលថ្មីៗនេះប៉ុណ្ណោះដែលទូរស័ព្ទស្មាតហ្វូន និងទូរស័ព្ទដៃ និងនៅពេលដែលប្រព័ន្ធអ៊ីនធឺណេតគ្របដណ្តប់ស្ទើរតែគ្រប់ទីកន្លែងរាប់ទាំងតំបន់ជនបទ។ លើសពីនេះទៀត ភាសាខ្មែរក៏មានបញ្ហាប្រឈមផងដែរចំពោះការវាយលើអេក្រង់ទូរស័ព្ទ ជាមួយនឹងនិមិត្តសញ្ញាព្យញ្ជនៈ៣៣តួ និងសញ្ញាសំគាល់បន្ថែមសម្រាប់សម្លេងស្រៈ។ សហ្វវែរក្តារចុចភាសាខ្មែរដែលងាយស្រួលប្រើដំបូងបង្អស់សម្រាប់ទូរស័ព្ទស្មាតហ្វូនទើបតែមានប៉ុន្មានឆ្នាំមុននេះប៉ុណ្ណោះ។ មានការព្រួយបារម្ភមួយដែលថាការផ្តោកលើជំហានសំខាន់ៗក្នុងដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ លើសមត្ថភាពរបស់អ្នកសម្ភាសន៍ ឧទាហរណ៍ ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗទាំងនេះនឹងធ្វើឲ្យការចូលរួមពីសំណាក់អ្នកភូមិមួយផ្នែកធំមានកម្រិតពិសេសគឺមនុស្សចាស់ៗ។

ក្រសួងផែនការ ក៏បានពិចារណាអំពីសមត្ថភាពនៅគ្រប់ថ្នាក់ក្នុងការគ្រប់គ្រងផ្នែករឹង និងផ្នែកទន់បន្ថែមទៀតផងដែរ។ តម្រូវការធនធានរួមមាន ការទិញសម្ភារៈដំណាក់កាលពីដំបូង និងការទិញសម្ភារផ្លាស់ប្តូរ ការតភ្ជាប់អ៊ីនធឺណិត ហេដ្ឋារចនាសម្ព័ន្ធដើម្បីធានាបាននូវផ្នែករឹង និងបុគ្គលិក IT ឬសមត្ថភាពក្នុងការផ្ញើបញ្ជីសារពើភណ្ឌ ការថែទាំ ការគ្រប់គ្រងទិន្នន័យ និងការគាំទ្រអ្នកប្រើប្រាស់។

វិធីសាស្ត្រនេះ ត្រូវបានពង្រឹងដោយបទពិសោធន៍ពីដំបូងជាមួយនឹងការបញ្ចូលទិន្នន័យពីកម្រងសំណួរសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ដំបូង ក្រសួងផែនការបានប្រគល់ភារកិច្ចនេះដល់បុគ្គលិកមន្ទីរផែនការខេត្ត ប៉ុន្តែបន្ទាប់មកក៏ប្រគល់ភារកិច្ច ទៅឱ្យក្រុមហ៊ុនមួយដែលមានជំនាញផ្នែកសេវាព័ត៌មានវិទ្យា ដើម្បីពន្លឿនដំណើរការ និងកាត់បន្ថយកំហុសក្នុងការបញ្ចូលទិន្នន័យ។

ម្យ៉ាងវិញទៀត អត្ថប្រយោជន៍ដែលអាចទទួលបានពីការធ្វើសមាហរណកម្មបច្ចេកវិទ្យាមានលក្ខណៈទាក់ទាញ៖ ការបញ្ចូលទិន្នន័យកម្រងសំណួរដោយផ្ទាល់ទៅក្នុងស្មាតហ្វូន ឬថេប្លេត ធ្វើឱ្យទិន្នន័យអាចរកបានភ្លាមៗ ដែលសន្សំសំចៃពេលវេលា និងចំណាយនៃការបញ្ចូលទិន្នន័យ និងកាត់បន្ថយចំណាយលើទំរង់ក្រដាសបោះពុម្ព។ លំដាប់លំដោយមុខវិជ្ជា សារមានកំហុស ការផ្លោះរំលង និងការគណនាពិន្ទុដោយស្វ័យប្រវត្តិ អាចធ្វើឱ្យកម្រងសំណួរងាយស្រួលក្នុងការអនុវត្ត និងកាត់បន្ថយកំហុស។ សហ្វវែរក៏អាចប្រើសម្រាប់បកប្រែកម្រងសំណួរទៅជាភាសាជនជាតិដើមភាគតិច សម្រាប់សហគមន៍ដែលចេះអក្សរខ្មែរមិនគ្រប់គ្រាន់។

### ប្រអប់៧៖ បទពិសោធន៍ជុំទីមួយនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

ក្រសួងផែនការ បានដំណើរការកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅទីប្រជុំជនលើកដំបូងនៅចុងឆ្នាំ ២០១៦ នៅតាមក្រុងនៃខេត្តចំនួនប្រាំបីគិតទាំងរាជធានីភ្នំពេញផងដែរ។ ការអនុវត្តន៍នោះត្រូវបានពន្យាពេលដោយសារការបោះឆ្នោតឃុំ / សង្កាត់ ដែលប្រព្រឹត្តទៅក្នុងពេលតែមួយដែលអាចប៉ះពាល់ដល់ការចូលរួមរបស់ប្រជាពលរដ្ឋ ដែលត្រូវបានស្នើសុំឱ្យចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង និងកិច្ចប្រជុំស្តីពីការបោះឆ្នោត។ ទោះជាយ៉ាងណាក្តី របាយការណ៍បឋមបង្ហាញថាការចូលរួមក្នុងកិច្ចប្រជុំមានលក្ខណៈស្រដៀងគ្នាទៅនឹងបទពិសោធន៍នៅទីជនបទ ដោយមានចំនួន ៣០-៤០គ្រួសារ ចូលរួមក្នុងព្រឹត្តិការណ៍នីមួយៗ។



ចំណងជើង៖ក្រុមតំណាងភូមិនៅទីប្រជុំជនពិនិត្យឡើងវិញនូវការសម្ភាសន៍ និងការដាក់ពិន្ទុពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រជុំទីមួយ នៅភ្នំពេញដែលបានប្រព្រឹត្តទៅនៅឆ្នាំ២០១៧

ក្រុមដៃគាំទ្រដែលគ្រប់គ្រងដោយសាលាក្រុង ត្រូវបានបង្កើតឡើងដោយជោគជ័យ ហើយជាពិសេសអ្នកចូលរួមមកពីអង្គការក្រៅរដ្ឋាភិបាល បានដើរតួនាទីយ៉ាងសកម្មក្នុងការផ្តល់បញ្ជីឈ្មោះអ្នកទទួលផល ដែលត្រូវបញ្ចូលក្នុងដំណើរការសំភាសន៍។ យោងតាមប្រធានមន្ទីរផែនការខេត្តម្នាក់ បានឲ្យដឹងថា នេះក៏អាចជារចនាសម្ព័ន្ធមួយដែលអាចផ្តល់អត្ថប្រយោជន៍ដល់អត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅទីជនបទផងដែរ។

ដំណើរការនិងកម្រងសំណួរលម្អិត តម្រូវឲ្យមានការបណ្តុះបណ្តាល ហើយកម្រងសំណួរនីមួយៗក៏ត្រូវការចំណាយពេលវេលាបន្ថែមដើម្បីធ្វើការសម្ភាសន៍គ្រួសារ។ ដូច្នេះ ចាំបាច់ត្រូវមានការវាយតម្លៃបន្ថែមក្រោយពេលដែលជុំនោះបានបញ្ចប់ ដើម្បីទទួលបានមតិត្រឡប់ចំពោះការអនុវត្ត កម្រងសំណួរ និងទទួលបានសំណើសុំកែសម្រួល។

អ្នកអនុវត្តពនៅទីប្រជុំជន បានព្យាករណ៍ថាសហគមន៍នានានឹងយល់ដឹងអំពីតម្លៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រកាន់តែប្រសើរ និងប័ណ្ណសមធម៌ដូចនៅទីជនបទដែរ ដោយសារពួកគេទទួលបានសេវាកម្ម និងអត្ថប្រយោជន៍កាន់តែច្រើន។ បច្ចុប្បន្ន ក្រសួងផែនការ និងថ្នាក់ក្រោមជាតិកំពុងពង្រីកការជំរុញការគាំទ្រជាមួយដៃគូ និងកម្មវិធី

ដំណើរការធ្វើតេស្តសាកល្បងមួយចំនួននៅទីប្រជុំជន នូវសក្តានុពលនេះ ។ ក្រុមថតរូបប្រើម៉ាស៊ីនថតទូរស័ព្ទដៃ និងកម្មវិធីដែលអនុញ្ញាតឱ្យបង្ហោះភ្លាមៗចូលកាន់ទិន្នន័យគ្រួសារនៅក្នុងមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ។ សកម្មភាពបែបនេះសន្សំពេលយ៉ាងតិចក្នុងមួយខែក្នុងការទាញយករូបថតទាំងនោះ។ ជាអត្ថប្រយោជន៍បន្ថែម គ្រួសារមិនចាំបាច់កាន់ស្លាកលេខកូដគ្រួសារក្រីក្ររបស់ខ្លួននៅក្នុងរូបថតរបស់ពួកគេឡើយ ជាពិសេសចំពោះប្រជាជនមានវ័យចំណាស់នៅរាជធានីភ្នំពេញ ។ ក្រសួងផែនការ ក៏មានគម្រោងបន្ថែមសហ្វវែរចាប់យកស្នាមខ្មៅដៃផងដែរ ដែលនៅពេលណាមួយអាចជំនួសឲ្យអ្នកទទួលផលយកប័ណ្ណសមធម៌ដើម្បីផ្ទៀងផ្ទាត់។ លើសពីនេះទៅទៀត ការអនុវត្តសាកល្បងអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ នឹងប្រើថេបប្លេតនៅកម្រិតមូលដ្ឋានដែលជាការសាកល្បងសំខាន់មួយនៃលទ្ធភាពបញ្ចូលទិន្នន័យឌីជីថល។

## ការលើកកម្ពស់ការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យ៖ ពីបញ្ជីអ្នកទទួលផលទៅជាទិន្នន័យគ្រួសារក្រីក្រ

ការកែសម្រួល និងការកែប្រែនានាមួយចំនួនផ្សេងទៀត ទាក់ទងនឹងវិធីដែលអត្តសញ្ញាណកម្មគ្រួសារក្រីក្របានគ្រប់គ្រង បានចែករំលែក និងបានប្រើប្រាស់កម្រងទិន្នន័យដែលកំពុងកើនឡើងឥតឈប់ឈរ។ នៅដំណាកើកាលដំបូង ក្រុមការងារកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ផ្តោតលើការផ្តល់បញ្ជីគ្រួសារក្រីក្រទៅឲ្យកម្មវិធីនានាដែលមានគោលដៅផ្តល់ការគាំទ្រដល់គ្រួសារ និងជនក្រីក្រ។ ក្រុមការងារបានធ្វើបញ្ជីគ្រួសារក្រីក្រនេះជាទម្រង់ Excel មួយក្នុងមួយឃុំ និងចម្លងទុកនៅលើឌីវីឌី។ ដែនកំណត់នៃការប្រើប្រព័ន្ធនេះមិនយូរប៉ុន្មានក៏កើតមានឡើង។ អាស្រ័យលើចរិតលក្ខណៈរបស់កម្មវិធី ដៃគូមួយចំនួនមានចំណាប់អារម្មណ៍ក្នុងការដាក់ទិន្នន័យជាក្រុមផ្សេងៗគ្នា ( ឧ. ទៅតាមមន្ទីរពេទ្យ ឬទីតាំងភូមិសាស្ត្រសាលារៀន )។ ជាមួយគ្នានេះផងដែរ ពួកគេសំដៅលើអនុផ្នែកនានានៃគ្រួសារក្រីក្រ ដូច្នេះមិនមែនត្រូវការតែលទ្ធផលនៃដំណើរការអត្តសញ្ញាណកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវការចម្លើយនៃកិច្ចសម្ភាសន៍ជាក់លាក់ផងដែរ ឧទាហរណ៍ ថាតើគ្រួសារមួយមានសមាជិកដែលមានពិការភាព ឬមនុស្សចាស់ជរា ឬមានសមាជិកដែលមានអាយុចូលរៀនដែរឬទេ។

### *ប្រព័ន្ធព័ត៌មានគ្រួសាក្រីក្រ( IIS )៖ ការធ្វើឱ្យមានទិន្នន័យនៅលើអ៊ីនធឺណិត*

នៅក្នុងឆ្នាំ២០១២ ក្រសួងផែនការ និងកម្មវិធីស្បៀងអាហារពិភពលោក បានសហការគ្នាបង្កើតសៀវភៅអាត្លាសស្តីពីគ្រួសារក្រីក្រ ដោយផ្អែកលើទិន្នន័យគ្រួសារក្រីក្រ និង ការធ្វើឲ្យមើលឃើញភាពក្រីក្រនៅកម្ពុជាតាមរយៈ ផែនទី តារាង និងក្រាហ្វិកនានា ដែលបង្ហាញពីការកែច្នៃទិន្នន័យនៃភាពក្រីក្រទៅតាមចរិតលក្ខណៈខុសៗគ្នា (ក្រសួងផែនការឆ្នាំ 2012a) ។ កិច្ចការនេះត្រូវបានដៃគូ និងស្ថាប័ននានារបស់រដ្ឋាភិបាល គាំទ្រនិងទទួលស្គាល់ ដែលឥឡូវគេអាចមើលឃើញ និងវិភាគលទ្ធផលរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្របានយ៉ាងងាយ។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ នៅក្នុងឆ្នាំ ២០១៣ ក្រសួងផែនការបានឆ្លើយតបទៅនឹងមតិរបស់អ្នកប្រើប្រាស់ទិន្នន័យ ហើយបានសម្រេចចិត្តបន្តពង្រីករបាយការណ៍របស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងធ្វើឱ្យគេអាចរកបានកាន់តែងាយស្រួលតាមអ៊ីនធឺណិត ជាជាងតាមឌីវីឌី។ ការបង្កើតវេទិកាអនឡាញ ក៏នឹងនាំមកនូវអត្ថប្រយោជន៍ផ្សេងៗទៀតផងដែរ ដូចជា លទ្ធភាពដើម្បីឲ្យអ្នកផ្តល់សេវាសង្គមងាយស្រួលផ្ទៀងផ្ទាត់សុពលភាពនៃប័ណ្ណសមធម៌ សន្តិសុខទិន្នន័យកាន់តែខ្ពស់តាមរយៈការការពារពាក្យសម្ងាត់ និងសមត្ថភាពក្នុងការតាមដានការប្រើប្រាស់ទិន្នន័យ ដូចជា របាយការណ៍ណាខ្លះដែលត្រូវបានគេប្រើញឹកញាប់បំផុត។ ទន្ទឹមនឹងរបាយការណ៍ថ្មីដែលបានកំណត់ទុកជាមុន ផែនទីភាពក្រីក្រត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការកំណត់ទីតាំងភូមិសាស្ត្រឲ្យបានកាន់តែងាយស្រួល ដោយពណ៌ខុសៗគ្នា តំណាងឱ្យភាគរយនៃភាពក្រីក្រខុសផ្សេងៗគ្នា។ ក្រសួងផែនការបានចាប់ផ្តើមបង្កើតប្រព័ន្ធព័ត៌មានគ្រួសារក្រីក្រ លើគេហទំព័រ (IIS) ដែលបានដាក់ឲ្យដំណើរការនៅខែកញ្ញាឆ្នាំ 2014 ជាពីរភាសា គឺខ្មែរ និងអង់គ្លេស។ នៅពេលដែល IIS ទទួលយកតួនាទីនៃការផ្តល់របាយការណ៍និងផែនទីកាន់តែពិស្តារ ផែនទីគ្រួសារក្រីក្រកម្រងអាត្លាសនឹងលែងមានការចាំបាច់ និងត្រូវបានរក្សាទុកក្នុងគេហទំព័រ IIS។

បច្ចុប្បន្ននេះ របាយការណ៍ទិន្នន័យគ្រួសារក្រីគ្រ ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅលើ IIS រួមទាំងស្ថិតិសង្ខេប និងការប្រៀបធៀបភាពក្រីក្រនៃខេត្តនីមួយៗ ស្រុកនីមួយៗ  និងឃុំនីមួយៗ រួមមាន ចំនួនប្រជាជនសរុប (គ្រួសារនិងឯកត្តបុគ្គល) ចំនួន និងភាគរយនៃគ្រួសារនីមួយៗដែលចាត់ជាគ្រួសារក្រីក្រកម្រិត 1 និងកម្រិត 2 និងមេគ្រួសារជាស្ត្រីនិងបុរសគិតតាមកម្រិតក្រីក្រ។

ចំណាងជើង៖ ជាឧទាហរណ៍មួយនៃផែនទីដែលមាននៅលើអ៊ីនធឺណេតតាមរយៈប្រព័ន្ធព័ត៌មានគ្រួសារក្រីក្រ រូបថតអេក្រង់នេះបង្ហាញភាគរយនៃគ្រួសារក្រីក្រ



អ្នកប្រើប្រាស់ អាចចុចមើលបន្តនូវបញ្ជីឈ្មោះ ឬផែនទីទៅកាន់កម្រិតរដ្ឋបាលនីមួយៗកាន់តែលម្អិត។ ផែនទីមួយទៀតបង្ហាញនៅពេលដែលខេត្តនីមួយៗ បានធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រលើកចុងក្រោយ។ ដោយសារការដាក់លេខកូដជាពណ៌ ទិដ្ឋភាពផែនទីទាំងនេះអនុញ្ញាតឱ្យកម្មវិធីផ្តោតលើតំបន់ដែលមានភាគរយភាពក្រីក្រខ្ពស់បំផុត។

ការចុះឈ្មោះ គឺជាតម្រូវការចាំបាច់ដើម្បីរកមើលលេខប័ណ្ណសមធម៌សំដៅបញ្ជាក់ពីសុពលភាពនៃលេខទាំងនោះ និងដើម្បីទទួលបានរបាយការណ៍ចំនួនបួនបន្ថែមទៀត រួមទាំងបញ្ជីគ្រួសារក្រីក្រ។ របាយការណ៍មួយផ្តល់ព័ត៌មានសង្ខេបអំពីគ្រួសារក្រីក្រ ទាំងអស់នៅក្នុងភូមិមួយ (ឈ្មោះ និងភេទនៃមេគ្រួសារ ឈ្មោះសហព័ទ្ធ និងកម្រិតភាពក្រីក្រ) និងស្ថិតិសង្ខេបសម្រាប់ភូមិ។ របាយការណ៍មួយទៀតផ្តល់នូវទិន្នន័យសំខាន់ៗអំពីសមាជិកទាំងអស់នៅក្នុងគ្រួសារ ដែលមានប្រយោជន៍សម្រាប់ពិនិត្យមើលសមាជិកគ្រួសារណានៅលើប័ណ្ណសមធម៌ ដែលមានសិទ្ធិទទួលសេវាដែលទាក់ទងនឹងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

### *PRISM៖ ភ្ជាប់ទិន្នន័យគ្រួសារក្រីក្រ ជាមួយព័ត៌មានផ្សេងទៀតសម្រាប់ការវិភាគកម្មវិធីនិងការកំណត់មុខសញ្ញា*

ដោយពិនិត្យអំពីលទ្ធភាពនៃការមើលឃើញនិងការបកស្រាយមួយជំហានបន្ថែមទៀត កម្មវិធីស្បៀងអាហារពិភពលោក បានភ្ជាប់ទិន្នន័យគ្រួសារក្រីក្រជាមួយនឹងទិន្នន័យកម្មវិធីអាហារូបករណ៍សាលារៀនរបស់ខ្លួន ក៏ដូចជាទិន្នន័យជំរឿនពីវិទ្យាស្ថានជាតិស្ថិតិនៅក្នុងបណ្តាញអ៊ិនធឺណេត និងអន្តរកម្មនៃបច្ចេកវិទ្យាដែលហៅថា វេទិកាព័ត៌មានទាន់ហេតុការណ៍ ឬ PRISM ។ ប្រព័ន្ធនេះ មានគោលបំណងគាំទ្រដល់ការសម្រេចចិត្តរបស់រដ្ឋាភិបាល ដោយការស្វែងរកទិន្នន័យ ការគ្រប់គ្រងស្វ័យប្រវត្តិកម្មនៃរបាយការណ៍ និងការដាស់តឿន និងការចែករំលែកទិន្នន័យក្រសួងក្នុងក្របខណ្ឌរដ្ឋាភិបាល។

ដោយប្រើកម្មវិធីចែករំលែកទិន្នន័យរបស់ PRISM កម្មវិធីស្បៀងអាហារពិភពលោក ទាញយកទិន្នន័យគ្រួសារក្រីក្រពី IIS ទៅជាផែនទីអន្តរកម្មដែលអ្នកប្រើអាចធ្វើការកត់សម្គាល់លើទិន្នន័យផ្សេងទៀតដើម្បីកំណត់មុខសញ្ញាឲ្យមានប្រសិទ្ធភាព។ ដូច្នេះអ្នករៀបចំគោលនយោបាយអាចដឹងអំពីតម្រូវការទាំងពីរ (ឧទាហរណ៍ ចំនួនគ្រួសារក្រីក្រច្រើនដែលមានកូនស្ថិតក្នុងវ័យចូលរៀន) និងវិសាលភាពនៃកម្មវិធីដែលមានស្រាប់ (ឧទាហរណ៍ អាហារូបករណ៍និងការផ្តល់អាហារនៅសាលារៀន) នៅតាមតំបន់ជនបទទូទាំងប្រទេសកម្ពុជា និងរៀបចំអន្តរាគមន៍នានាទៅតាមនោះ។ វិធីសាស្ត្រនេះកំពុងទទួលបានការចាប់អារម្មណ៍កាន់តែច្រើនឡើងដែលគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយកំពុងប្រើប្រាស់ PRISM ធ្វើជាប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយដោយមើលឃើញទិន្នន័យគ្រួសារក្រីក្រដែលមានលក្ខណៈអន្តរកម្មក្នុងការកំណត់ការឆ្លើយតបទៅកាន់តំបន់ និងគ្រួសារដែលងាយរងគ្រោះបំផុត។ លើសពីនេះទៅទៀត ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ កំពុងពិភាក្សាអំពីប្រព័ន្ធស្រដៀងគ្នាដើម្បីកំណត់សម្បទានដីសង្គមកិច្ច។

### *ការធ្វើបច្ចុប្បន្នភាពចំពោះ IIS៖ របាយការណ៍តាមតម្រូវការ និងការកែច្នៃផ្សេងទៀត*

អ្នកប្រើទិន្នន័យមួយចំនួន ចង់បានការដកស្រង់ទិន្នន័យដែលពួកគេចង់បានដើម្បីផ្តោតលើអនុផ្នែកនៃចំនួនប្រជាជនដែលបានកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។ ក្រសួងផែនការ ផ្តល់តាមសំណើបែបនេះរហូតដល់១០ក្នុងមួយសប្តាហ៍។ ការមានលទ្ធភាពចូលទៅកាន់កម្រងទិន្ន័យ គ្រួសារក្រីក្រ ពេញលេញសម្រាប់របាយការណ៍ផ្ទាល់ខ្លួន ដែលបង្កើតឡើងដោយអ្នកប្រើប្រាស់ គឺជាមូលហេតុចម្បងមួយនៅពីក្រោយផែនការផ្លាស់ប្តូរ IIS ដែលកំពុងដំណើរការក្នុងអំឡុងឆ្នាំ២០១៧។ អ្នកប្រើប្រាស់នឹងអាចជ្រើសរើសប៉ារ៉ាម៉ែត្រនានា ដើម្បីបង្កើតសំណួរផ្ទាល់ខ្លួនដោយផ្អែកលើភូមិសាស្ត្រ និងផ្នែកដទៃទៀតនៃទិន្នន័យពីកម្រងសំណួរសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ការងារនេះនឹងធ្វើឱ្យកម្រងទិន្នន័យ IIS និងគេហទំព័រកាន់តែងាយស្រួលគ្រប់គ្រងដោយមន្ត្រីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជៀសវាងការបង់ប្រាក់ចំពោះការដកយកទិន្នន័យតាមតម្រូវការ និងបច្ចុប្បន្នកម្មគេហទំព័រពីក្រុមហ៊ុនខាងក្រៅដែលបានបង្កើតឡើង ហើយបច្ចុប្បន្នកំពុងគ្រប់គ្រងប្រព័ន្ធIIS ។ ប្រព័ន្ធថ្មីនេះ ក៏នឹងអនុញ្ញាតឱ្យមានការបញ្ចូលទិន្នន័យពីបច្ចេកវិទ្យាចល័តផ្សេងៗ ដូចជា ការប្រើប្រាស់ថេបប្លេតជាផ្នែកមួយនៃការអនុវត្តសាកល្បងអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ។ កម្រងទិន្នន័យដែលបានធ្វើបច្ចុប្បន្នភាព ក៏នឹងញែកចេញពីគ្នារវាងអ្នកទទួលបានប័ណ្ណសមធម៌ក្នុងពេលកន្លងមក និងក្នុងពេលបច្ចុប្បន្ន ដូច្នេះកំណត់ត្រាកន្លងមក របស់គ្រួសារអាចត្រូវបានរក្សាទុកនៅពេលដែលស្ថានភាពភាពក្រីក្ររបស់ពួកគេវិវត្តន៍ទៅតាមពេលវេលា នេះគឺជាលក្ខណៈពិសេសមួយដែលមានប្រយោជន៍សម្រាប់អ្នកស្រាវជ្រាវ[5] ។ យន្តការគ្រប់គ្រងនិងការឆ្លើយតបបណ្តឹងក៏ជាផ្នែកមួយនៃវេទិកាដែលបានធ្វើបច្ចុប្បន្នភាពផងដែរ។

### *អន្តរប្រតិបត្តិការ និងអនាគតនៃមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ*

នៅក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម កាលពីពេលកន្លងទៅថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាអំពាវនាវឱ្យមានការភ្ជាប់ប្រព័ន្ធអត្តសញ្ញាណកម្ម និងប្រព័ន្ធចុះឈ្មោះចំពោះប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ព្រមទាំងផ្សារភ្ជាប់ ឬពង្រឹងប្រព័ន្ធចុះឈ្មោះរបស់អ្នកផ្តល់សេវាដើម្បីកាត់បន្ថយនូវភាពត្រួតគ្នា និងកាត់បន្ថយចំណាយប្រតិបត្តិការក្នុងការគ្រប់គ្រងទិន្នន័យរបស់គ្រួសារដដែលនៅច្រើនកន្លែង(រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០០១៧)។ ចក្ខុវិស័យនេះគឺ អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបង្កើតបញ្ជីគ្រួសារក្រីក្រឈ្មោះតែមួយដែលមានទិន្នន័យស្តីពីគ្រួសារក្រីក្រ ក៏ដូចជាមានព័ត៌មានស្តីពីកម្មវិធីគាំពារសង្គមទាំងឡាយ ហើយតើគ្រួសារណាខ្លះដែលជាអ្នកទទួលផល (OECD Social Protection System Review, 2017) ។ ការផ្លាស់ប្តូរមួយចំនួនចំពោះអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងកម្រងទិន្នន័យគ្រួសារក្រីក្រគឺជាសេចក្តីត្រូវការចាំបាច់ដើម្បីធ្វើកិច្ចការនេះឱ្យក្លាយជាការពិតនិងត្រូវធ្វើបច្ចុប្បន្នភាពជាញឹកញាប់នូវទិន្នន័យគ្រួសារក្រីក្រ វិសាលភាពថ្នាក់ជាតិពិតប្រាកដរាប់ទាំងតំបន់ទីប្រជុំជន និងបញ្ជីសេវាកម្មពេញលេញដែលគ្រួសារក្រីក្រអាចទទួលផលបាន ។

ការកែសម្រួលចាំបាច់បន្ថែមទៀត ក៏កំពុងដំណើរការជាផ្នែកមួយនៃការធ្វើឱ្យប្រសើរឡើងនៃប្រព័ន្ធព័ត៌មានគ្រួសារក្រីក្រគឺការបង្កើតស្រទាប់ចំណុចប្រទាក់កម្មវិធី (API) ដែលនឹងអនុញ្ញាតឱ្យមានអន្តរប្រតិបត្តិការ និងការប្តូរទិន្នន័យរវាង IIS និងប្រព័ន្ធរបស់អ្នកប្រើទិន្នន័យ ទាំងពីរនេះសម្រាប់ជំរុញទិន្នន័យដោយស្វ័យប្រវត្តិនៅពេលដែលមានបច្ចុប្បន្នភាព និងដើម្បីឲ្យដៃគូអាចធ្វើបច្ចុប្បន្នភាពអំពីព័ត៌មានគ្រួសារក្រីក្រ ដូចជាការបន្ថែមទារកថ្មី។ អន្តរប្រតិបត្តិការរវាងបញ្ជីអត្រានុកូលដ្ឋានថ្មីរបស់ប្រទេសកម្ពុជា និងទិន្នន័យយោងនៃផ្លាតហ្វ៍មនានា(Platform)ដោយប្រើស្នាមម្រាមដៃក៏ជាសក្តានុពលថ្មីជាមួយនឹង API និងគម្រោងបន្ថែមបច្ចេកវិទ្យាប្រមូលស្នាមខ្ទៅម្រាមដៃចំពោះការប្រមូលទិន្នន័យគ្រួសារក្រីក្រ។

[5] ទិន្នន័យទាំងនេះនឹងមានប្រយោជន៍បំផុតប្រសិនបើគ្រួសារដែលបានផ្តល់កិច្ចសម្ភាសន៍ទាំងអស់ត្រូវបានបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យ មិនមែនបញ្ចូលតែគ្រួសារដែលបានកំណត់អត្តសញ្ញាណថាជាគ្រួសារក្រីក្រនោះទេ ហើយប្រសិនបើអតីតគ្រួសារក្រីក្រដែលធ្លាក់ចូលទៅក្នុងភាពក្រីក្រជាថ្មី នោះអាចប្រើលេខកូដគ្រួសាររបស់ពួកគេដើម្បីងាយតាមដាន។

## ការកសាងទំនុកចិត្ត និងភាពជាម្ចាស់នៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រគ្រប់វិស័យ និងកម្មវិធី

ប្រភេទទីបីនៃការរៀនសូត្រ និងការកែសម្រួលអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាតម្រូវការចាំបាច់រួមក្នុងការរួមបញ្ចូលភាគីពាក់ព័ន្ធមួយចំនួនឲ្យបានល្អប្រសើរនៅក្នុងប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីទទួលបានព័ត៌មានត្រឡប់និងចែករំលែកព័ត៌មាន។ ក្រសួងផែនការបានចំណាយពេលពីរបីឆ្នាំដើម្បីដឹងថាការបើកចំហកាន់តែច្រើនឡើងជាមួយដៃគូនៅថ្នាក់ជាតិនឹងបង្កើនការយល់ដឹងរបស់ដៃគូអំពីនិយមន័យនៃភាពក្រីក្រ និងអំពីដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងវិធីធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រួសារក្រីក្រ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា។ ខណៈមានការលំបាកដែលច្រើនតែកើតមានកាលពីពេលចាប់ផ្តើមដោយជូនដំណឹងនិងរួមបញ្ចូលសហគមន៍មូលដ្ឋានជាបន្តបន្ទាប់ គេមិនសូវឃើញមានការសង្កត់ធ្ងន់លើការរួមបញ្ចូលនិងជូនដំណឹងដល់ដៃគូ និងអ្នកប្រើប្រាស់ទិន្នន័យឡើយ។ នៅប្រទេសកម្ពុជាដូចនៅអង្គភាពជាច្រើនផងដែរ អាចមានការមិនទុកចិត្តចំពោះគុណភាពទិន្នន័យដែលប្រមូលដោយអង្គភាពមួយផ្សេងទៀត។

ដើម្បីផ្លាស់ប្តូរចំណុចនេះ ' វេទិកាឆ្លុះបញ្ចាំងរបស់ភាគីពាក់ព័ន្ធ ' នឹងត្រូវប្រព្រឹត្តទៅបន្ទាប់ពីជុំប្រមូលទិន្នន័យគ្រួសារក្រីក្រនីមួយៗនៅក្នុងពីរទៅបីខេត្តដើម្បីប្រមូលមតត្រឡប់លើដំណើរការ និងរៀនសូត្រពីការងារនេះ។ ក្រសួងផែនការ ក៏បានរៀបចំកិច្ចប្រជុំជាលក្ខណៈបុគ្គល ឬកិច្ចប្រជុំជាក្រុមជាមួយភាគីពាក់ព័ន្ធច្រើនដងក្នុងមួយឆ្នាំៗ ដើម្បីពិភាក្សាពីផែនការអនាគត និងទទួលធាតុចូលអំពីអ្វីដែលដៃគូអភិវឌ្ឍន៍ និងស្ថាប័នរាជរដ្ឋាភិបាលត្រូវការ ( ច្រើនតែផ្តោតលើរបាយការណ៍ឬទម្រង់ទិន្នន័យ ) ។ ក្រសួង បានចាប់ផ្តើមរៀបចំវេទិកាអ្នកប្រើទិន្នន័យថ្នាក់ជាតិ ក្នុងបំណងធ្វើឲ្យក្លាយជាព្រឹត្តិការណ៍ប្រចាំឆ្នាំ តាមរយៈការប្រមូលផ្តុំអង្គភាពសំខាន់ៗដែលប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រសម្រាប់គំនិតផ្តួចផ្តើមស្តីពីការកាត់បន្ថយភាពក្រីក្រ។ ក្រុមពិគ្រោះយោបល់ដែលមានភាគីពាក់ព័ន្ធច្រើនកំពុងត្រូវបានបង្កើតឡើងជាវេទិកាមួយសម្រាប់ដៃគូ និងសម្រាប់ក្រសួងផ្សេងៗទៀតដើម្បីលើកសំណួរ ឬបញ្ហាពាក់ព័ន្ធនឹងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងដើម្បីរួមចំណែកដោះស្រាយបញ្ហា។ ជារួម គំនិតផ្តួចផ្តើមទាំងនេះ មានបំណងកសាងទំនុកចិត្តលើសមត្ថភាពរបស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រទាំងអស់ និងធ្វើជាមូលដ្ឋានគ្រឹះសម្រាប់វេទិកាគាំពារសង្គមរួមមួយនៅក្នុងប្រទេសកម្ពុជា។

# សមិទ្ធផលរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ

## អត្តសញ្ញាណកម្មគ្រួសារក្រីក្រ កំពុងឈានទៅកាន់វិសាលភាពជាតិ

តាមរយៈវដ្តបីឆ្នាំរំកិល អត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានឈានដល់ការគ្របដណ្តប់ទូទាំងតំបន់ជនបទក្នុងឆ្នាំ២០១៣ ហើយត្រូវបានរំពឹងថានឹងឈានដល់ការគ្របដណ្តប់ទូទាំងតំបន់ទីប្រជុំជនក្នុងឆ្នាំ២០១៩។ នៅកំឡុងពេលនៃការបោះពុម្ពផ្សាយ (ធ្នូ២០១៧) ប្រជាជនជិត១៣លាននាក់រស់នៅក្នុងតំបន់ដែលគ្របដណ្តប់ដោយកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និង ៩០%នៃភូមិទាំងអស់ -។

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានធ្វើការប្រមូលទិន្នន័យចំនួន១១ជុំរួចមកហើយរវាងពីឆ្នាំ២០០៧ និងឆ្នាំ២០១៧ គឺជាសមិទ្ធផលដ៏ធំមួយដោយហេតុថាធនាគារពិភពលោកបានលើកឡើងអំពី „ ការខ្វះទិន្នន័យ „ ជាកង្វល់ចម្បងមួយក្នុងការតាមដាន និងកាត់បន្ថយភាពក្រីក្រ៖ ប្រទេសចំនួន៥៧ (ក្នុងចំណោម១៥៥ ប្រទេសដែលធនាគារពិភពលោកតាមដានទិន្នន័យភាពក្រីក្រ) គ្មានទិន្នន័យភាពក្រីក្រ ឬមានទិន្នន័យតែមួយដងក្នុងរយៈពេល១០ឆ្នាំរវាងឆ្នាំ២០០២ និង ២០១១ ហើយគ្មានប្រទេសណាមួយធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមសហគមន៍ទូទាំងប្រទេសបានទៀងទាត់ដូចកម្ពុជាឡើយ (Serajuddin et al, 2015) ។

ក្នុងអំឡុងបីជុំកន្លងមក (ឆ្នាំ២០១៤ ដល់ ២០១៦) ជាមធ្យម គ្រួសារចំនួន ១៩២,000 ក្នុងមួយឆ្នាំត្រូវបានកំណត់អត្តសញ្ញាណថាជាគ្រួសារក្រីក្រ។ ជាសរុប កម្រងទិន្នន័យគ្រួសារក្រីក្រ មានតួលេខ27,9លានគ្រួសាររួមទាំងគ្រួសារក្រីក្រ បច្ចុប្បន្ន៥៧៥.000(តំណាងឱ្យ២,៤លាននាក់ប្រមាណជា១៩%នៃចំនួនប្រជាជន) និងកំណត់ត្រាប្រវត្តិមិនសកម្មដែលបន្សល់ទុកមក។

## ឧទាហរណ៍មួយនៃការអភិវឌ្ឍសមត្ថភាពប្រកបដោយប្រសិទ្ធភាព

កិច្ចសហប្រតិបត្តិការកម្ពុជា អាល្លឺម៉ង់ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាឧទាហរណ៍មួយនៃការអភិវឌ្ឍន៍សមត្ថភាពប្រកបដោយប្រសិទ្ធភាព ជាមួយនឹងការវិនិយោគប្រកបដោយជោគជ័យ មិនមែនត្រឹមតែជោគជ័យនៅក្នុងការអភិវឌ្ឍធនធានមនុស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងការកសាងស្ថាប័ន និងការទទួលស្គាល់តាមច្បាប់ផងដែរ។

ចាប់តាំងពីពេលចាប់ផ្តើមមក កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានកសាងសមត្ថភាពអនុវត្តនៅថ្នាក់មូលដ្ឋាន ថ្នាក់ឃុំ/សង្កាត់ និងថ្នាក់រាជធានី/ខេត្ត ដោយប្រើវិធីសាស្ត្របណ្តុះបណ្តាលគ្រូបង្គោលដើម្បីចុះទៅបណ្តុះបណ្តាលក្រុមតំណាងភូមិ។ នៅថ្នាក់ជាតិ GIZ បានផ្តល់ជំនួយបច្ចេកទេសដល់មន្ត្រីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមវិធីមួយចំនួន ដូចជា ការជួយដល់ការរៀបចំដំណើរការរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ រួមទាំងការជួយក្រសួងផែនការក្នុងការរៀបចំសិក្ខាសាលា ការរៀបចំកិច្ចប្រជុំក្រុមការងារ និងផ្តល់អ្នកជំនាញ រហូតដល់កសាងសមត្ថភាពរបស់មន្ត្រីក្រសួងផែនការ តាមរយៈវិធីសាស្ត្រផ្តល់ប្រឹក្សារៀនបណ្តើរធ្វើការបណ្តើរ ´ក្នុងផ្នែកនានានៃគម្រោង ការគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាល។ បុគ្គលិក GIZ ក៏បានលើកទឹកចិត្តដល់ក្រុមការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្រសួងផែនការ ក្នុងការបំពេញតួនាទីសំខាន់ៗឱ្យកាន់តែប្រសើរឡើង ក្នុងកិច្ចពិភាក្សាគោលនយោបាយអន្តរក្រសួង និងអន្តរវិស័យដែលទាក់ទងនឹងជំនួយសង្គម និងដើម្បីបង្កើតឱ្យមានបណ្តាញនៃស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ។ នាពេលថ្មីៗនេះបុគ្គលិកGIZ កំពុងគាំទ្រក្រសួងផែនការ ក្នុងការបន្តកែសម្រួលនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅទីប្រជុំជន និងអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ និងសិក្សាវាយតម្លៃ ព្រមទាំងសាកល្បងអនុវត្តបច្ចេកវិទ្យាថ្មីៗ ( IIS, ឧបករណ៍ប្រមូលទិន្នន័យចល័ត )។

នៅកម្រិតស្ថាប័ន អត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានវិវត្តន៍ពីកម្មវិធីមួយនៃកម្មវិធីជាច្រើន ដែលអនុវត្តដោយនាយកដ្ឋានផែនការសង្គមកិច្ចនៃក្រសួងផែនការក្នុងឆ្នាំ២០០៧ ទៅជានាយកដ្ឋានពេញលេញ ( នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ) នៅឆ្នាំ២០១៥។

ក្នុងកម្រិតច្បាប់ អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ទទួលបាននូវការទទួលស្គាល់តាមរយៈអនុក្រឹត្យលេខ២៩១ នៅក្នុងឆ្នាំ២០១១។ ការប្រព្រឹត្តទៅនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានឈានទៅដល់ការគ្របដណ្តប់គ្រប់ភូមិជនបទក្នុងឆ្នាំ២០១១ ហើយការប្តេជ្ញាចិត្តពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងទម្រង់ជាសហហិរញ្ញប្បទាន និងការដាក់បញ្ចូលអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គមឆ្នាំ២០១១ បានផ្តល់ឱកាសដល់ក្រសួងផែនការ ក្នុងការលើកសំណើសេចក្តីព្រាងអនុក្រឹត្យទៅទីស្តីការគណៈរដ្ឋមន្ត្រី។ ទោះបីជាមានអង្គការមិនមែនរដ្ឋាភិបាល និងដៃគូជាច្រើនបានចាប់ផ្តើមប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ រួចហើយក៏ដោយ ក៏វត្តមានថ្មីនៃទិន្នន័យកំណត់គោលដៅថ្នាក់ជាតិ (លើកលែងតំបន់ទីក្រុង) បានអនុញ្ញាតឱ្យរាជរដ្ឋាភិបាល

អនុវត្តអាណត្តិជាក់ស្តែងក្នុងការប្រើទិន្នន័យគ្រួសារក្រីក្រ សម្រាប់កម្មវិធីដែលផ្តោតលើភាពក្រីក្រ។ ការអនុម័តជាផ្លូវការនេះ បានពង្រឹងការគាំទ្រផ្នែកហិរញ្ញវត្ថុ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលចំពោះនិរន្តរភាពរបស់កម្មវិធី និងបានបន្ថែមតម្លៃរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ទៅដល់អ្នកទទួលផលដោយសារសេវាកម្មកាន់តែច្រើនឡើងៗ ត្រូវបានភ្ជាប់ទៅនឹងប័ណ្ណសមធម៌នៅក្នុងតំបន់ផ្សេងៗគ្នា។

## ថវិកាត្រូវបានផ្តល់ទាំងស្រុងពីរាជរដ្ឋាភិបាលកម្ពុជា

ចាប់តាំងពីឆ្នាំ ២០១៥ មក រដ្ឋាភិបាលកម្ពុជា បានទទួលខុសត្រូវទាំងស្រុងលើផ្នែកហិរញ្ញវត្ថុសម្រាប់ការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅទីជនបទ។ ជាមួយទស្សនវិស័យដើម្បីសម្រេចឱ្យបាននូវនិរន្តរភាព ភាគីអាល្លឺម៉ង់ អូស្ត្រាលី និងដៃគូអភិវឌ្ឍន៍កម្ពុជ បានឯកភាពគ្នាតាំងពីដំបូងថាហិរញ្ញប្បទានរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ នឹងផ្ទេរជាលំដាប់ពីម្ចាស់ជំនួយទៅរាជរដ្ឋាភិបាលកម្ពុជា។ អ្នកពាក់ព័ន្ធដែលបានចូលរួមជាមួយអត្តសញ្ញាណកម្មគ្រួសារក្រីក្រ  យល់ថាវាជាពេលវេលាច្បាស់លាស់ដែលត្រូវកំណត់ថានរណាគួរទទួលបានអត្ថប្រយោជន៍ពីមូលនិធិសមធម៌សុខាភិបាល និងកម្មវិធីជំនួយសង្គមផ្សេងៗទៀត ហើយការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការបង្កើតយុទ្ធសាស្ត្រគាំពារសង្គមដ៏ទូលំទូលាយស្របគ្នា បង្កើតបានជាករណីមួយរឹងមាំទៅកាន់ក្រសួងហិរញ្ញវត្ថុសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវដាក់បញ្ចូលអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្នុងការវិភាជន៍ថវិការបស់ក្រសួងផែនការ។

នៅដើមឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជា បានរួមចំណែក១០%នៃថ្លៃចំណាយប្រតិបត្តិការ ក្នុងពេលដែលដៃគូអាល្លឺម៉ង់ និងអូស្ត្រាលីរួមជាមួយសហភាពអឺរ៉ុប បានផ្តល់ថវិកា៩០% និងផ្តល់ជំនួយបច្ចេកទេស។ ក្នុងឆ្នាំ២០១២ ថវិកាហិរញ្ញប្បទានរបស់សហភាពអឺរ៉ុបត្រូវបានបញ្ចប់ហើយភាគីអាល្លឺម៉ង់ - អូស្ត្រាលី បានផ្តល់ហិរញ្ញប្បទាណជំនួស ចំពោះចំណាយប្រតិបត្តិការដែលបានថយចុះជាលំដាប់ នៅពេលដែលការរួមចំណែករបស់រាជរដ្ឋាភិបាលកម្ពុជាបានកើនឡើងដល់២០% បន្ទាប់មក៤០%ក្នុងឆ្នាំ២០១៣ ៦០%នៅក្នុងឆ្នាំ២០១៤ ហើយចាប់ពីឆ្នាំ២០១៥មក រាជរដ្ឋាភិបាលកម្ពុជាបានម្ចាស់ការទាំងស្រុងនៃការចំណាយលើជុំប្រមូលទិន្នន័យគ្រួសារក្រីក្រនៅទីជនបទទាំងអស់។

បច្ចុប្បន្ននេះ ការអភិវឌ្ឍន៍ និងការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ សម្រាប់ទីប្រជុំជននៅតែទទួលបានការគាំទ្រពីប្រទេសអាល្លឺម៉ង់ និងអូស្ត្រាលី ទន្ទឹមនឹងការវិនិយោគក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និងសកម្មភាពនានាដើម្បីលើកកម្ពស់ការផ្សព្វផ្សាយទិន្នន័យ និងគាំទ្រតួនាទីរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្នុងការកាត់បន្ថយភាពក្រីក្រ និងការបង្កើតគោលនយោបាយសង្គម។

## ការសម្រេចបាននូវគុណតម្លៃក្នុងការចំណាយ និងការទទួលបានអត្ថប្រយោជន៍នានា

ចំណាយប្រតិបត្តិការ សម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ មានប្រមាណ២,៥លានអឺរ៉ូក្នុងមួយឆ្នាំ។ ទោះបីជាមានការលំបាកក្នុងការប្រៀបធៀបថ្លៃចំណាយនៃប្រព័ន្ធអត្តសញ្ញាណកម្មភាពក្រីក្រ និងកម្រងទិន្នន័យពាក់ព័ន្ធនៃប្រព័ន្ធទាំងនោះជាមួយប្រទេសដទៃក៏ដោយ អត្តសញ្ញាណកម្មគ្រួសារក្រីក្រ យ៉ាងហោចណាស់ក៏មានលក្ខណៈស្រដៀងគ្នាទៅនឹងប្រទេសជាច្រើន ប្រសិនបើមិនចំណាយតិចជាង ហើយមានទិន្នន័យគួរជាទីទុកចិត្ត និងមានគុណភាពខ្ពស់ដូចលទ្ធផលដែរ (Leite et al, 2017 ) ។ ការចំណាយទាប របស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានធ្វើឱ្យកម្ពុជាមានលទ្ធភាពអនុវត្ត ដែលជាកត្តាដ៏មានសារៈសំខាន់ជាខ្លាំងសម្រាប់និរន្តរភាពរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

ចំណែកឯលទ្ធផលចំពោះការចំណាយវិញ នៅពេលប្រៀបធៀបទៅនឹងប្រទេសដទៃ រយៈពេលបីឆ្នាំ គឺជាពេលវេលាសមស្របបំផុតសម្រាប់ជុំប្រមូលទិន្នន័យគ្រួសារក្រីក្រទូទាំងប្រទេស។ លើសពីនេះទៅទៀត កម្មវិធីថ្នាក់ជាតិដែលប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ កំពុងកើនឡើង៖ សេវាសុខភាពដោយឥតគិតថ្លៃតាមរយៈមូលនិធិសមធម៌សុខាភិបាលត្រូវបានបង្កើនឡើង ជាមួយនឹងកម្មវិធីផ្សេងទៀតដែលកំពុងកំណត់ដោយរាជរដ្ឋាភិបាល និងពង្រីកតាមរយៈក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម។

យន្តការកំណត់មុខសញ្ញាផ្សេងទៀត មានវិធីសាស្ត្រខុសៗគ្នា និងមានចំណុចខ្លាំង និងចំណុចខ្សោយរបស់របស់វា។ ការអង្កេតប័ណ្ណពិន្ទុស្តីពីភាពក្រីក្រ របស់ប៉ាគីស្ថាន មិនត្រូវបានធ្វើបច្ចុប្បន្នភាពចាប់តាំងពីការអនុវត្តដំបូងរបស់ខ្លួនក្នុងឆ្នាំ២០១១ ទោះបីជាបច្ចុប្បន្នត្រូវបានពិភាក្សាសម្រាប់ឆ្នាំ២០១៧ក៏ដោយ។ អ្នកប្រើប្រាស់ទិន្នន័យកំណត់មុខសញ្ញរបស់ប៉ាគីស្ថានគឺកម្មវិធីគាំទ្រប្រាក់ចំណូល Benazir (BISP) ដែលផ្តល់ការផ្ទេរសាច់ប្រាក់សម្រាប់ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ធានារ៉ាប់រងសុខភាព និងប្រាក់កម្ចីគ្មានការប្រាក់។ កម្មវិធីផ្ទេរសាច់ប្រាក់ភ្ជាប់លក្ខខណ្ឌរបស់ហ្វីលីពីន Pantawid Pamilya បានធ្វើអង្កេតកំណត់មុខសញ្ញាជាលើកដំបូងក្នុងឆ្នាំ២០០៨ ហើយបានធ្វើបច្ចុប្បន្នភាពប្រាំពីរឆ្នាំក្រោយ គឺនៅឆ្នាំ២០១៥។ រហូតមកដល់ពេលនេះ អត្ថប្រយោជន៍ជាតិរបស់ហ្វីលីពីន គឺទាក់ទងជាចម្បងទៅនឹងការកើនឡើងនូវការចូលរៀន ប៉ុន្តែទោះបីជារដ្ឋាភិបាលបានកំណត់វិស័យបួនផ្សេងទៀតដែលត្រូវដោះស្រាយក៏ដោយ (រួមមានវិស័យសុខាភិបាល និងប្រព័ន្ធសោធន)។ សិទ្ធិទទួលបានគម្រោងធានារ៉ាប់រងសុខភាពរបស់ប្រជាជនឥណ្ឌាសម្រាប់ប្រជាជនក្រីក្រ (Rashtriya Swasthya Bima Yojana ឬ RSBY) ត្រូវបានផ្តោតទៅលើប្រជាជនដែលមានឈ្មោះនៅក្នុងបញ្ជី „ខ្សែក្រោមបន្ទាត់ភាពក្រីក្រ" ផ្អែកលើអង្កេតមួយដែលបានធ្វើកាលពីឆ្នាំ២០០២ ហើយការធ្វើបច្ចុប្បន្នភាពដែលបានគ្រោងទុកត្រូវបានពន្យារពេល។

បើប្រៀបធៀបទៅនឹងវិធីសាស្ត្រផ្សេងៗទៀត សមិទ្ធផលរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រទាក់ទងនឹងតម្លៃនិងប្រសិទ្ធភាព ច្បាស់ណាស់ថាមានលក្ខណៈលេចធ្លោ ទោះជាការកែលម្អបន្ថែមត្រូវបានកំណត់និងគ្រោងទុកក៏ដោយ។

## អត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានទទួលការទុកចិត្ត និងតំណាងទស្សនៈសហគមន៍អំពីភាពក្រីក្រ

មានមន្ត្រីគ្រប់គ្រងថ្នាក់ខេត្ត រហូតដល់អ្នកស្ម័គ្រចិត្តក្រុមតំណាងភូមិប្រមាណ ៣៥.000 នាក់ បានចូលរួមក្នុងដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្ររៀងរាល់ឆ្នាំ។  ក្នុងជុំនីមួយៗមានអ្នកភូមិប្រមាណ ១,៦លាននាក់ចូលរួមក្នុងកិច្ចប្រជុំជ្រើសរើសក្រុមតំណាងភូមិរបស់ពួកគេ។ នៅចន្លោះឆ្នាំ ២០១២ និង ២០១៤ ពួកគេបានជ្រើសតាំងសមាជិកស្រីចំនួន ៣១% ដែលគួរឲ្យចាប់អារម្មណ៍នៅក្នុងតំបន់ជនបទដែលបន្តផ្តល់ឋានៈស្ត្រីទាបជាងបុរស។

មេភូមិដែលត្រូវបានសម្ភាស ជាផ្នែកមួយនៃការស្រាវជ្រាវសម្រាប់ករណីសិក្សានេះមានអារម្មណ៍យ៉ាងមុតមាំថា កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ កំពុងកំណត់អត្តសញ្ញាណគ្រួសារក្រីក្រពិតប្រាកដ។ មេភូមិម្នាក់ក្នុងចំណោមមេភូមិដទៃទៀតឈ្មោះ សៀង សារិន នៅខេត្តកំពង់ឆ្នាំងនិយាយថា " វាគឺជាប្រព័ន្ធមានយុត្តិធម៌ " ។

អ្នកស្រី ភឿក ហឹង ប្រធានក្រុមប្រឹក្សាឃុំ និងជាអ្នករស់នៅភូមិក្បែរខាងយល់ស្របថា៖ " យើងមិនចង់ឱ្យអ្នកខាងក្រៅចូលមកប្រាប់យើងថានរណាក្រីក្រនោះទេ។ យើងស្គាល់គ្នាទៅវិញទៅមក។ គ្មានការតវ៉ា គ្មាននរណាម្នាក់ប្រាប់យើងថាយើងបានរកឃើញមនុស្សខុសឡើយ។ យើងដឹងថាអ្នកណាជាអ្នកក្រីក្រ។

ចំពោះលោក Thomas Waldraff ប្រធាន GIZ ប្រចាំប្រទេសកម្ពុជា យល់ថាការជឿជាក់ដ៏ទូលាយមកលើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាមូលដ្ឋានសម្រាប់និរន្តរភាពគម្រោង៖ 'IDPoor ពុំមែនជាអ្នកសិក្សាទាំងស្រុងនោះទេ ´ ` ប៉ុន្តែនេះគឺពិតជាអ្វីដែលយើងស្រឡាញ់ ´ ។ រដ្ឋាភិបាលកំពុងចំណាយប្រាក់លើ IDPoor ហើយអ្នកភូមិកំពុងដំណើរការដោយខ្លួនឯង។ វាមាននិរន្តរភាព´។

## រដ្ឋាភិបាលនិងដៃគូកោតសរសើរចំពោះតម្លៃទិន្នន័យគ្រួសារក្រីក្រ សម្រាប់ការរៀបចំផែនការកម្មវិធីនិងការកំណត់គោលដៅរបស់ខ្លួន

ចំនួនដៃគូអភិវឌ្ឍន៍ដែលប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រសម្រាប់គម្រោងរបស់ពួកគេ បានកើនឡើងជាលំដាប់ពី ៤២គម្រោងនៅឆ្នាំ២០១២ ទៅដល់ ១៣៦គម្រោង នៅឆ្នាំ២០១៥ ដែលតំណាងឱ្យ៦៣%នៃកម្មវិធីអភិវឌ្ឍន៍ទាំងអស់ដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា (សូមមើលប្រអប់៩)។ ឯកឧត្តម ឆាយ ថន ទេសរដ្ឋ រដ្ឋមន្ត្រីក្រសួងផែនការ បានចាត់ទុកថា នេះគឺជាទឡ្ហីករណ៍មួយអំពីជោគជ័យរបស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ៖ " នៅកម្រិតម៉ាក្រូ ជោគជ័យរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺការកាត់បន្ថយភាពក្រីក្រ។ ដៃគូកាន់តែច្រើនប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រសម្រាប់កំណត់គោលដៅរបស់ពួកគេ មានន័យថាអន្តរាគមន៍កាន់តែច្រើនបានទៅដល់អ្នកដែលត្រូវការ។ '

ដៃគូអភិវឌ្ឍន៍ពេញចិត្តនឹងគុណតម្លៃរបស់ទិន្នន័យគ្រួសារក្រីក្រ។ ក្នុងនាមជាប្រធានក្រុមគោលនយោបាយសង្គម របស់អង្គការយូនីសេហ្វប្រចាំនៅប្រទេសកម្ពុជា លោក Maki Kato គ្រប់គ្រងកម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះក្រីក្រ និងជនពិការ និងគាំទ្ររដ្ឋាភិបាលក្នុងការបង្កើតគោលនយោបាយជួយជនក្រីក្រ។ អ្នកស្រី យល់ឃើញថា " ការកំណត់អត្តសញ្ញាណអ្នកទទួលផលគឺជាផ្នែកមួយដ៏លំបាកបំផុតនៃកម្មវិធីជំនួយសង្គម។ តាមទស្សនៈរបស់លោកស្រី ទិន្ន័យគ្រួសារក្រីក្រ បានធ្វើឱ្យមានភាពងាយស្រួលជាងមុនយ៉ាងច្រើន សម្រាប់អាជ្ញាធរមូលដ្ឋានក្នុងការធ្វើផែនការ និងដាក់ចេញនូវកម្មវិធីគាំពារសង្គមដែលផ្តោតទៅលើគ្រួសារក្រីក្រ។ គ្មានមន្ទិលអ្វីអំពីរឿងនេះឡើយ ទិន្នន័យគ្រួសារក្រីក្រ គឺជាឧបករណ៍ដ៏សំខាន់មួយសម្រាប់ប្រទេសនេះ ´។

### ប្រអប់លេខ៨៖ ទស្សនៈរបស់អ្នកអនុវត្តន៍ម្នាក់៖ ប្រធានក្រុមប្រឹក្សាឃុំ អ្នកស្រី ភឿក ហឹង

អ្នកស្រី ភឿក ហឹង ជាប្រធានក្រុមប្រឹក្សាឃុំ នៅឃុំខ្លងពពក ស្ថិតនៅខេត្តកំពង់ឆ្នាំង។ ក្នុងតួនាទីនេះ គាត់បានចូលរួមយ៉ាងជិតស្និទ្ធជាមួយការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមរយៈការរៀបចំការកិច្ចប្រជុំក្រុមប្រឹក្សាឃុំ និងកិច្ចប្រជុំមេភូមិនៅក្នុងដំណើរការនេះទាំងមូល។

អ្នកស្រី ភឿក ហឹង សង្កេតឃើញថា ដំណើរការរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅសហគមន៍ មានសារៈសំខាន់ខ្លាំងណាស់ក្នុងការកំណត់ថាតើនរណាជាអ្នកក្រីក្រពិតប្រាកដ។ នៅក្នុងឃុំរបស់គាត់កាលពីឆ្នាំមុន មានគ្រួសារចំនួនប្រមាណ ៤១៩ ក្នុងចំណោម ១.៥00គ្រួសារត្រូវបានជ្រើសសម្រាប់សម្ភាសន៍។ ក្នុងចំណោមអ្នកទាំងនោះ ៣៦៦នាក់ ត្រូវបានកំណត់ថាជាគ្រួសារក្រីក្រ ( ជិត ២៤%នៃចំនួនគ្រួសារសរុប )។



គាត់មានអារម្មណ៍ថា ការស្វែងរកអ្នកក្រីក្រពិតប្រាកដគឺជាកាតព្វកិច្ច។ ` ឧបមាថាបើយើងដាក់បញ្ចូលសាច់ញាតិរបស់យើងទៅក្នុងបញ្ជីគ្រួសារក្រីក្រ ប្រជាជនក្រីក្រនៅជុំវិញយើងនឹងស្លាប់ ´ ។
អ្នកស្រី ហឹង ជឿថាកម្រងសំណួរ និងចរិតសាធារណៈនៃការសម្រេចចិត្តគឺជាវិធានការគណនេយ្យភាពដ៏រឹងមាំដែលបង្ការការក្លែងបន្លំ ឬបង្ការភាពលម្អៀងនិយម។

អ្នកស្រីហឹង ក៏មើលឃើញដោយផ្ទាល់អំពីស្ថានភាពអ្នកជិតខាងរបស់គាត់ ដែលបានកំណត់ថាជាគ្រួសារក្រីក្រផងដែរ។ គាត់ទទួលស្គាល់ថាសម្រាប់គ្រួសារក្រីក្រជាច្រើន ភាពក្រីក្រមិនមែនជាបញ្ហាតែមួយគត់ដែលពួកគេអាចប្រឈមមុខនោះទេ។ គាត់បានរៀបរាប់អំពីគ្រួសារមួយដែលកូនច្បងបានបោះបង់ចោលការសិក្សាបន្ទាប់ពីថ្នាក់ទី៧។ គ្រួសារមួយទៀតរងអំពើហិង្សាក្នុងគ្រួសារ ខណៈដែលគ្រួសារមួយទៀតមានជីវភាពរស់នៅក្រីក្រជាខ្លាំង ប៉ុន្តែឪពុកម្តាយយកចិត្តទុកដាក់មើលថែទាំកូនៗរបស់ពួកគេបានយ៉ាងល្អ។ គាត់ដឹងពីគ្រួសារក្រីក្រដែលលក់ដីរបស់ខ្លួនក្នុងករណីបន្ទាន់ដើម្បីទទួលបានប្រាក់កាសខ្លះ ប៉ុន្តែចុងក្រោយទៅ ច្រើនតែគ្មានលុយ និងអស់ដីធ្លីស្ថិតក្នុងស្ថានភាពអាក្រក់ជាងមុន។

## ប្រអប់៩៖ នរណាខ្លះកំពុងប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ

គម្រោង និងកម្មវិធីចំនួន១៣៦ (គិតត្រឹមឆ្នាំ២០១៥) បានប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ ដែលជាគម្រោងនិង កម្មវិធីធំៗបំផុត របស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលធ្វើការនៅក្នុងប្រទេសកម្ពុជា រួមមាន៖
មូលនិធិសមធម៌សុខាភិបាល គាំទ្រដោយគម្រោងលើកកម្ពស់សមធម៌ និងគុណភាពសុខាភិបាលកម្ពុជា (H-EQIP) និងស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល៖ ផ្តល់សេវាសុខភាព ការធ្វើដំណើរទៅកាន់មន្ទីរពេទ្យ និងអាហារឥតគិតថ្លៃក្នុងកំឡុងពេលព្យាបាលនៅមន្ទីរពេទ្យសម្រាប់អ្នកកាន់ប័ណ្ណសមធម៌។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងអតីតយុទ្ធជន និងកម្មវិធីយុវជនសម្រាប់កុមារកំព្រា និងកុមារងាយរងគ្រោះ៖ គាំទ្រដល់កុមារកំព្រា និងក្រុមជនងាយរងគ្រោះនៅកម្ពុជា (ជាពិសេសខេត្តពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ឆ្នាំង) ។

សេវាកម្មច្រកចេញចូលតែមួយ៖ ស្រុក និងក្រុង បានកាត់បន្ថយអត្រា ឬលើកលែងចំពោះម្ចាស់ប័ណ្ណសមធម៌លើកម្រៃសេវារដ្ឋបាលមួយចំនួន ដូចជាការចុះអត្រានុកូលដ្ឋាន ឬទំនាស់ដីធ្លីដីធ្លី។

កម្មវិធីផ្ទេរសាច់ប្រាក់របស់យូនីសហ្វ និងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ៖ ផ្តោតលើស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ៥ឆ្នាំ ដែលកំពុងរស់នៅក្នុងភាពក្រីក្រ រួមមាន ការផ្ទេរសាច់ប្រាក់និងវគ្គអប់រំស្តីពីសុខភាព និងអាហារូបត្ថម្ភ។

កម្មវិធីស្បៀងអាហារពិភពលោក និងកម្មវិធីអាហារូបករណ៍ក្រសួងអប់រំ យុវជន និងកីឡា៖ ផ្តល់កម្មវិធីអាហារូបករណ៍ (អាហារ ឬសាច់ប្រាក់) ដល់គ្រួសារក្រីក្រដែលមានកូនកំពុងរៀនចាប់ពីថ្នាក់ទី៤ ដល់ថ្នាក់ទី៦ និងទទួលបានកម្មវិធីសាធារណៈផ្សេងៗសម្រាប់សិស្ស។

គំរោងជួយសង្គ្រោះកុមារ និងកម្មវិធី USAID NOURISH៖ ផ្តោតទៅលើគ្រួសារក្រីក្រដែលមានកូនរហូតដល់អាយុ៣ឆ្នាំ ដោយផ្តោតលើការកាត់បន្ថយភាពក្រិន នៅក្នុង៥៥៥សហគមន៍ជនបទដាច់ស្រយាល នៅក្នុងខេត្តចំនួន៣ ដោយសមាហរណកម្មផ្នែកសុខភាព អាហារូបត្ថម្ភ ទឹក អនាម័យចំណីអាហារ អនាម័យខ្លួនប្រាណ និងអន្តរាគមន៍ផ្នែកកសិកម្ម។

ការគាំទ្រផ្នែកច្បាប់នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា៖ ផ្តល់សេវាផ្នែកច្បាប់ដល់គ្រួសារក្រីក្រ។

ទីភ្នាក់ងារអភិវឌ្ឍន៍ និងជំនួយសង្គ្រោះជនរងគ្រោះ (ADRA) កម្មវិធីទឹកស្អាត  អនាម័យនិងអាហារូបត្ថម្ភនៅកម្ពុជា៖ ផ្តោតទៅលើគ្រួសារក្រីក្រនៅសហគមន៍ជនបទ។ កម្មវិធីទឹកស្អាត  អនាម័យបរិស្ថាន អនាម័យខ្លួនប្រាណ និងអាហារូបត្ថម្ភនៅកម្ពុជានៃទីភ្នាក់ងារអភិវឌ្ឍន៍ និងជំនួយសង្គ្រោះជនរងគ្រោះ (ADRA)៖ ផ្តោតទៅលើគ្រួសារក្រីក្រនៅសហគមន៍ជនបទមួយចំនួន។

ការវិនិយោគលើកម្មវិធីវិនិយោគហេដ្ឋារចនាសម្ព័ន្ធ (3i) ដែលគាំទ្រដោយ DFAT និងអនុវត្តដោយក្រុមហ៊ុនPalladium៖ ពង្រីកការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដោយធ្វើជាដៃគូជាមួយវិស័យឯកជន ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានទឹកភ្លើងប្រើប្រាស់ និងសេវាកម្មផ្សេងទៀតរបស់គ្រួសារ និងអាជីវកម្ម។ កម្មវិធីនេះផ្តល់ឧបត្ថម្ភធនចំពោះការតភ្ជាប់បណ្តាញទឹកស្អាតចូលលំនៅដ្ឋានគ្រួសារក្រីក្រ។

កម្មវិធីរដ្ឋាភិបាលអាល្លឺម៉ង់ រួមមាន៖
គំរោងសន្តិសុខស្បៀង និងអាហារូបត្ថម្ភពហុវិស័យរបស់GIZ និងCARD៖ ជាផ្នែកមួយនៃគម្រោងពិសេស ONE WORLD របស់ BMZ  គ្មានទុរ្ភិក្ស (Sonderinitiative Eine Welt Ohne Hunger) គម្រោងនេះ មានគោលបំណងលើកកម្ពស់អាហារូបត្ថម្ភរបស់ស្ត្រីក្រីក្រ និងកុមារតូច។

កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់របស់ GIZ៖ គាំទ្រដល់ប្រជាជនក្រីក្រនៅតាមតំបន់ជនបទនៃខេត្តចំនួនបីក្នុងការទទួលបានឱកាសអាជីវកម្ម និងការងារប្រកបដោយនិរន្តរភាពដើម្បីបង្កើនប្រាក់ចំណូលរបស់ពួកគេ និងការលុបបំបាត់ភាពក្រីក្រ។

គម្រោងលើកកម្ពស់ជីវភាព និងសន្តិសុខស្បៀងរបស់ GIZ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ILF) ៖ គាំទ្រដល់អ្នកទទួលដីសម្បទានសង្គមកិច្ច នៅក្នុងខេត្តចំនួនប្រាំដើម្បីអភិវឌ្ឍជីវភាពរស់នៅដោយប្រើប្រាស់ដីថ្មី និងលើកកម្ពស់សន្តិសុខស្បៀង។ អ្នកទទួលផលគឺគ្រួសារក្រីក្រកម្រិតទី១ និងកម្រិតទី២។

កម្មវិធីគាំពារសុខភាពសង្គមរបស់ធនាគារអភិវឌ្ឍន៍ KfW ៖ ផ្តល់ការអប់រំអំពីផែនការគ្រួសារ ការសម្រាលកូន សុខភាពមាតា និងទារក និង សក្ខីបត្រទូទាត់សម្រាប់ថ្លៃដឹកជញ្ជូន និងអាហារទាក់ទងទៅនឹងការថែទាំសុខភាពចំពោះស្ត្រីក្រីក្រ។ សេវាសក្ខីបត្រ នឹងត្រូវដាក់បញ្ចូលទៅក្នុងកញ្ចប់សេវាមូលនិធិសមធម៌សុខាភិបាល។

# គោលគំនិតសំខាន់ៗ

ជំពូកនេះ ពិភាក្សាពីមេរៀនសំខាន់ៗដែលបានទទួលតាមរយៈការអនុវត្តកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ អស់រយៈពេលជាងមួយទសវត្សកន្លងមក តាមរយៈដំណោះស្រាយបញ្ហាប្រឈមនានាដែលនឹងកើតឡើង ដូចបានរៀបរាប់នៅក្នុងជំពូកមុនៗ។ គោលគំនិតទាំងនេះ អាចទាក់ទងមិនត្រឹមតែជាមួយបណ្តាប្រទេសដែលមានធនធានតិចតួច សម្រាប់កម្មវិធីអត្តសញ្ញាណកម្មភាពក្រីក្រផ្ទាល់របស់ពួកគេ ប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់បណ្តាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ក្នុងការពិចារណាអំពីរបៀបដោះស្រាយបញ្ហាប្រឈមផ្ទាល់ខ្លួនរបស់ពួកគេ ក្នុងការធ្វើឱ្យភាពក្រីក្រកាន់តែអាចមើលឃើញនិងកំណត់ឆន្ទៈសង្គម និងឆន្ទៈនយោបាយដើម្បីដោះស្រាយបញ្ហានោះ។

## អាចមានប្រព័ន្ធអត្តសញ្ញាណកម្មភាពក្រីក្រដែលមានវិសាលភាពជាតិ មានភាពត្រឹមត្រូវគ្រប់គ្រាន់ សហគមន៍ទទួលយក និងទទួលបានមូលនិធិទាំស្រុងពីរដ្ឋាភិបាល។

ប្រទេសកម្ពុជា អាចសម្រេចបាននូវការគ្របដណ្តប់ទូទាំងប្រទេសនៃការធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ដោយប្រើប្រាស់វិធីសាស្ត្រកំណត់មុខសញ្ញាដោយឧបករណ៍វាស់វែងពីកម្រិតជីវភាព ទោះបីជាសមត្ថភាពផ្នែករដ្ឋបាលមានកម្រិតក៏ដោយ យោងតាមឯកសារសិក្សាស្រាវជ្រាវជាច្រើន នេះគឺជាសមិទ្ធផលមួយដ៏កម្រ។ សមាសពភានៅសហគមន៍នៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានលើកកម្ពស់ភាពត្រឹមត្រូវនៃការកំណត់សញ្ញាហើយរក្សាចំណាយឲ្យមានកម្រិតទាប  និងមាននិរន្តភាពសម្រាប់រដ្ឋាភិបាល។ យោងតាមលោក កែវ អ៊ូលី ប្រធានកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្រសួងផែនការ បានឱ្យដឹងថា ៉ កត្តាជោគជ័យមួយរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺការមានរចនាសម្ព័ន្ធច្បាស់លាស់ដែលពឹងផ្អែកលើស្ថាប័នដែលមានស្រាប់ ពីថ្នាក់ជាតិទៅដល់ថ្នាក់មូលដ្ឋាន និងនៅតាមក្រសួងផ្សេងៗទៀតផងដែរ។ ជាសក្ខីភាពនៃការប្តេជ្ញាចិត្តផ្នែកនយោបាយ និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការការអនុម័តអនុក្រឹត្យលេខ២៩១ និងការផ្តល់មូលនិធិទាំងស្រុងពីសំណាក់រាជរដ្ឋាភិបាលចំពោះចំណាយប្រតិបត្តិការរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ រួមជាមួយការប្តេជ្ញាចិត្តរយៈពេលវែងរបស់ដៃគូអភិវឌ្ឍន៍បានធានាដល់ការពង្រីកការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងការបន្តបង្កើនការប្រើប្រាស់ទិន្នន័យពីសំណាក់អង្គការ និងក្រសួងនានារបស់រាជរដ្ឋាភិបាលសម្រាប់កំណត់គោលដៅកម្មវិធី។ ការកែសម្រួលកំពុងប្រព្រឹត្តទៅចំពោះអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដូចជាដំណើរការថ្មីនៅទីប្រជុំជន និង ការអនុវត្តសាកល្បងនូវយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ និងកំពុងពិចារណាបន្ថែមដោយប្រើរចនាសម្ព័ន្ធរដ្ឋាភិបាលដែលមានស្រាប់ និងប្រើប្រាស់អង្គការនៅមូលដ្ឋានដើម្បីធានាឲ្យបន្តទទួលយកបាននៅគ្រប់កម្រិត។



សមាជិកក្រុមតំណាងភូមិធ្វើការសម្ភាសន៍លោកជួប រី(អាយុ៤៧ឆ្នាំ) និងម្តាយរបស់គាត់ដែលមានអាយុ៨១ឆ្នាំ។ ពួកគាត់ស្នាក់នៅវត្តអារាមក្នុងរាជធានីភ្នំពេញជាមួយព្រះសង្ឃ។ លោក រីមានជំងឺសន្លាក់រ៉ាំរ៉ៃដែលធ្វើឱ្យគាត់មិនអាចធ្វើការងារពេញម៉ោងបានឡើយ តែគាត់បានរត់ម៉ូតូកង់បីម្រាប់ព្រះសង្ឃគ្រាន់បានចំណូលបន្តិចបន្តួច។ ឧបករណ៍និងដំណើរការសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្របានសម្របតាមស្ថានភាពក្រីក្រជាក់ស្តែងនានានៅទីប្រជុំជន។

## ដំណើរការរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដឹកនាំដោយសហគមន៍ មានតម្លាភាព ផ្តល់នូវគុណតម្លៃសង្គម និងភាពក្រីក្រនៅក្នុងយុត្តាធិការយោបាយ។

ការមានដំណើរការដែលមានលក្ខណៈបរិយាប័ន្ន និងមានលក្ខណៈចូលរួមបែបនេះ មិនត្រឹមតែធានាថារដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដឹងពីរបៀបកំណត់ទិសដៅវិធានការកាត់បន្ថយភាពក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើឱ្យសហគមន៍ជួបជុំគ្នានិយាយទៅកាន់គ្នាទៅវិញទៅមក អំពីភាពក្រីក្រ ពិនិត្យឡើងវិញនូវស្ថានភាពជាក់ស្តែង វិសាលភាព និងផលប៉ះពាល់ចំពោះគ្រួសារនីមួយៗ និងសហគមន៍ទាំងមូល។ លក្ខណៈនៃដំណើរការនេះ អនុញ្ញាតឱ្យពិចារណាអំពីស្ថានភាពពិសេស មានតម្លាភាព និងមានការតាមដាន រួមមានវិធីតវ៉ា ឬការស្នើសុំឲ្យវាយតម្លៃឡើងវិញ និងធ្វើឲ្យសហគមន៍ទាំងមូលពេញចិត្ត។ លើសពីនេះទៅទៀត ដំណើរការនេះធ្វើឲ្យចំនួនប្រជាជនកម្ពុជា បានដឹងច្បាស់អំពីអ្វីទៅដែលហៅថាការរស់នៅក្នុងភាពក្រីក្រ និងដឹងពីរបៀបដែលប្រជាជនក្រីក្រប្រើប្រាស់សេវាសង្គមដែលពួកគេទទួលបាន ដែលបង្ការបាននូវមន្ទិលសង្ស័យ និងជួនកាលបញ្ចៀសបាននូវការយល់ច្រឡំរបស់អ្នកទទួលផលអំពីការគាំទ្រសង្គមនៅបណ្តាប្រទេសដែលមានប្រាក់ចំណូលមធ្យម និងប្រទេសដែលមានប្រាក់ចំណូលខ្ពស់។

ជាមួយគ្នានេះ ការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រប្រចាំឆ្នាំ ជួយរក្សាភាពក្រីក្រឲ្យស្ថិតនៅក្នុងយុត្តាធិការយោបាយនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ។ ការកំណត់និយមន័យនៃភាពក្រីក្រនៅក្នុងបរិបទណាមួយ តែងមានទិដ្ឋភាពនយោបាយភ្ជាប់ជាមួយព្រោះថា គ្រប់រដ្ឋាភិបាលតែងសង្ឃឹមថានឹងមានការផ្លាស់ប្ដូរជាវិជ្ជមាន។ តាមរយៈការកំណត់និយមន័យដែលមានទិដ្ឋភាពចម្រុះជាជាងភាពក្រីក្រដែលផ្អែកលើប្រាក់ខែតែមួយមុខ អត្តសញ្ញាណកម្មគ្រួសារក្រីក្រអាចបង្ហាញថាមានមនុស្សជាច្រើននៅកម្ពុជានៅតែងាយរងគ្រោះ។ យោងតាម ឯកឧត្តម ថេង បញ្ញាធន ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកផែនការនៃក្រសួងផែនការ ដោយមិនគិតអំពីទីតាំងពិតប្រាកដនៃខ្សែបន្ទាត់ភាពក្រីក្រផ្លូវការ " អ្នកក្រីក្រនៅតែជាអ្នកក្រីក្រ ហើយរដ្ឋាភិបាលចាំបាច់ត្រូវផ្ដល់អន្តរាគមន៍ "ជាមួយនឹងទិន្នន័យគ្រួសារក្រីក្រ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានព័ត៌មានដែលពួកគេត្រូវការដើម្បីធ្វើការងារនេះ។

## ដើម្បីកសាងទំនុកចិត្តលើទិន្នន័យដែលបានបង្កើត កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវចូលរួម និងត្រូវមានតម្លាភាពជាមួយភាគីពាក់ព័ន្ធដែលរំពឹងថានឹងប្រើប្រាស់ទិន្នន័យ។

នៅដំណាក់កាលដំបូង ក្រសួងផែនការ បានផ្ដោតលើការកសាងការចូលរួមរបស់សហគមន៍ និងការប្រមូលទិន្នន័យ តាមរយៈការគាំទ្រពីមន្ត្រីរបស់ក្រសួង ការបណ្ដុះបណ្ដាលគ្រប់កម្រិតពីថ្នាក់ខេត្តរហូតដល់ភូមិ និងការតាមដានការអនុវត្តជាទៀងទាត់។ ជាច្រើនឆ្នាំកន្លងមកនេះ ក្រុមការងារកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្របានដឹងថាការផ្សព្វផ្សាយទិន្នន័យ ការប្រាស្រ័យទាក់ទង និងការកសាងទំនុកចិត្តជាមួយភាគីពាក់ព័ន្ធ និងអ្នកប្រើប្រាស់ទិន្នន័យ ក៏មានសារៈសំខាន់ដូចការប្រមូលទិន្នន័យដែរ។ នៅពេលអ្នកប្រើប្រាស់ទិន្នន័យមិនបានយល់ពីដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឬមិនដឹងពីការកែលម្អដើម្បីដោះស្រាយបញ្ហាពួកគេមិនទុកចិត្តលើទិន្នន័យឡើយ ហើយចង់កែសម្រួលវាឡើងវិញ ឬចង់ប្រមូលខ្លួនឯង។ ការត្រួតពិនិត្យនិងការវាយតំលៃច្បាស់លាស់គឺការចាំបាច់ណាស់ រួមទាំងការចែករំលែករបកគំហើញនិងលើកឡើងនូវសំណើដោះស្រាយនានា ទោះបីជារឿយៗវប្បធម៌នៃការទទួលស្គាល់ចំណុចខ្វះខាត ជាផ្នែកមួយនៃការកែលម្អការអនុវត្តមិនសុទ្ធតែត្រូវបានបង្កើតឡើងក៏ដោយ។ ក្រសួងផែនការកំពុងបង្កើនការយកចិត្តទុកដាក់របស់ខ្លួនលើបញ្ហានេះ តាមរយៈវេទិកាឆ្លុះបញ្ចាំងជាមួយអ្នកអនុវត្តបន្ទាប់ពីការប្រមូលទិន្នន័យជុំនីមួយៗ គឺជាវេទិកាអ្នកប្រើប្រាស់ទិន្នន័យប្រចាំឆ្នាំ និងការបង្កើតក្រុមការងារលើកកម្ពស់ប្រសិទ្ធភាពអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវការចំណាយពេលវេលាច្រើន ប៉ុន្តែទីបំផុតបង្កើតបានប្រព័ន្ធមួយដែលមានយន្តការឆ្លើយតបរឹងមាំ។

## ការពន្លឿននិងបរិយាប័ន្នមានទំនាក់ទំនងនឹងយន្តការកំណត់មុខសញ្ញាដែលត្រូវមានតុល្យភាព

អត្តសញ្ញាណកម្មគ្រួសារក្រីក្រ តម្រូវការឱ្យមានទិន្នន័យគ្រួសារក្រីក្របានឆាប់រហ័ស និងទាន់សម័យក្នុងការពិចារណាអំពីចំណាកស្រុក និងការផ្លាស់ប្ដូរស្ថានភាពក្រីក្រ ត្រូវមានតុល្យភាពក្នុងការក្សាគុណសម្បត្តិនៃទិដ្ឋភាពដំណើរការនៅសហគមន៍ ដែលមានលក្ខណៈចូលរួម។ យន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ ដែលបច្ចុប្បន្នកំពុងត្រូវបាន អនុញ្ញាតឱ្យធ្វើបច្ចុប្បន្នភាពចន្លោះជុំប្រមូលទិន្នន័យគ្រួសារក្រីក្រ ដោយបានលុបចោលនូវការអនុវត្តសាកល្បងកម្រិតភូមិ ហើយការចុះជួប និងសម្ភាសគ្រួសារ នឹងធ្វើឡើងដោយសមាជិកក្រុមប្រឹក្សាឃុំ។ ការដាក់ឲ្យមានការចាប់យកទិន្នន័យឌីជីថល និងដំណោះស្រាយព័ត៌មានវិទ្យាផ្សេងៗទៀតអាចបង្កើនប្រសិទ្ធភាព ប៉ុន្តែអាចរាំងការចូលរួមរបស់សមាជិកសហគមន៍ដែលខ្វះខាតជំនាញបច្ចេកវិទ្យា។ ការបង្កើនឡើងនូវការប្រើប្រាស់បច្ចេកវិទ្យា ក៏តម្រូវឱ្យមានធនធានដើម្បីគ្រប់គ្រង ថែរក្សា និងជំនួសផ្នែករឹងនិងផ្នែកទន់ តាមការចាំបាច់។ មិនគួរផ្ដល់អាទិភាពលើគុណសម្បត្តិ " ភាពឆាប់រហ័សទាន់ពេល និងមានលក្ខណៈឌីជីថល " លើសពីតម្លៃនៃលក្ខណៈ " ការដាក់បញ្ចូលក្នុងបញ្ជីបានពេញលេញ និងដោយមានការចូលរួម " នោះទេ ជាការប្រសើរ គួររួមបញ្ចូលទិដ្ឋភាពទាំងពីរ ដើម្បីបង្កើនអត្ថប្រយោជន៍ជាអតិបរមា និងកាត់បន្ថយកំហុស ហើយការចំណាយឲ្យនៅមានតិចបំផុតស្របតាមអាទិភាពរបស់រាជរដ្ឋាភិបាល និងសហគមន៍។ ចាំបាច់ត្រូវមានការវាយតម្លៃបន្ថែមដើម្បីឲ្យអត្តសញ្ញាណកម្មគ្រួសារក្រីក្រកំណត់បានចំនុចដែលមានតុល្យភាពនេះ។

# ការពិនិត្យឡើងវិញដោយអ្នកជំនាញ

ករណីសិក្សានីមួយៗ នៅក្នុងឯកសារសមូហកម្មនេះត្រូវបានពិនិត្យសាឡើងវិញដោយអ្នកជំនាញឯករាជ្យពីររូប ដែលជាអ្នកជំនាញដែលមានការទទួលស្គាល់ជាអន្តរជាតិនៅក្នុងវិស័យរបស់ខ្លួន និងវាយតម្លៃថាតើករណីសិក្សានេះ បានបង្កើតគោលគំនិតថ្មីដែរឬយ៉ាងណាអំពីវិធីសាស្ត្រដែលករណីសិក្សានេះបង្ហាញ និងបញ្ហាប្រឈមក្នុងការអភិវឌ្ឍដែលករណីសិក្សានេះដោះស្រាយ។

### អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ផ្តល់នូវឧទាហរណ៍មួយអំពីគំនិតផ្តួចផ្តើមការគាំពារសង្គមមួយប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសនានាដែលមានកម្រិតអភិវឌ្ឍសេដ្ឋកិច្ចស្រដៀងគ្នា

អ្នកជំនាញទាំងពីររូប វាយតម្លៃដល់វិធីសាស្ត្រដោយឡែករបស់កម្ពុជាចំពោះអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ពោលគឺការរួមបញ្ចូលគ្នារវាងការជ្រើសរើសសហគមន៍ជាមួយនឹងឧបករណ៍វាស់វែងពីកម្រិតជីវភាពគ្រួសារក្រីក្រទទួលបានការគាំទ្រពីសហគមន៍ និងសង្គតិភាពក្នុងការប្រើប្រាស់ព័ត៌មានគ្រួសារ។

ពួកគេយល់ឃើញថាករណីសិក្សានេះ មានប្រយោជន៍និងទាន់ពេលវេលា ព្រោះប្រទេសជាច្រើនដែលមានបញ្ហាប្រឈមផ្នែកសង្គម និងសេដ្ឋកិច្ចប្រហាក់ប្រហែលនឹងប្រទេសកម្ពុជា ក៏កំពុងស្វែងរកមធ្យោបាយដើម្បីផ្តល់ការគាំពារសង្គមដល់ប្រជាជនក្រីក្រផងដែរ។ ការបង្កើនមូលនិធិសមធម៌សុខាភិបាលរបស់កម្ពុជា ដែលជាផ្នែកមួយនៃកម្លាំងជំរុញការអភិវឌ្ឍន៍អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ផ្តល់នូវ (ឧទាហរណ៍ដ៏រឹងមាំមួយ) អំពីរបៀបដែលប្រព័ន្ធគាំពារសង្គមអាចមាននិរន្តរភាពទោះបីជាប្រាក់ចំណូលជាតិក្នុងម្នាក់ៗមានកម្រិតទាបក៏ដោយ។ ដូចអ្នកឯកទេសត្រួតពិនិត្យម្នាក់បានកត់សម្គាល់ហើយបានលើកឡើងថា កម្មវិធីអប់រំ កម្មវិធីការអភិវឌ្ឍជនបទ និងកម្មវិធីសម្រាប់ជនងាយរងគ្រោះប្រជាជនអាចទទួលអត្ថប្រយោជន៍ពីមេរៀនបទពិសោធន៍ តាមរយៈអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ការពិពណ៌នាលំអិតអំពីដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ការអភិវឌ្ឍ និងការកែសម្រួលដំណើរការនេះ ត្រូវបានមើលឃើញថាមានប្រយោជន៍ និងមានតែមួយគត់នៅក្នុងអក្សរសិល្ប៍ស្តីពីយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

### បរិបទ និងភាពជាដៃគូ មានសារៈសំខាន់សម្រាប់និរន្តរភាព។

អ្នកជំនាញទាំងពីររូប បានកត់សម្គាល់សារៈសំខាន់នៃការបង្កើតភាពជាដៃគូរឹងមាំ និងធ្វើការក្នុងស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន៖ „ ភាពជាដៃគូជាមួយក្រសួងពាក់ព័ន្ធមានសារៈសំខាន់ណាស់ ដើម្បីធានាថាគំនិតផ្តួចផ្តើមនេះត្រូវបានពង្រីកនិងមាននិរន្តរភាព" ដូចបានបង្ហាញដោយក្រសួងផែនការ ក្នុងការបង្កើនការផ្តល់ហិរញ្ញប្បទានក្នុងការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅទីជនបទ។ អ្នកពិនិត្យរូបនេះ ក៏បានបង្ហាញដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅទីប្រជុំជន ធ្វើជាឧទាហរណ៍អំពីការយកចិត្តទុកដាក់ និងការរៀបចំកម្មវិធីសម្រាប់បរិបទផ្សេងៗ។

អ្នកពិនិត្យផ្សេងទៀតបានរកឃើញថា „ របាយការណ៍នេះបានបញ្ជាក់យ៉ាងត្រឹមត្រូវថា ផ្នែកដ៏សំខាន់នៃដំណើរការកំណត់មុខសញ្ញាប្រជាជនក្រីក្រ គឺកសាងរចនាសម្ព័ន្ធជាតិចាំបាច់ ពឹងផ្អែកយ៉ាងរឹងមាំទៅលើការគ្រប់គ្រងសហគមន៍នៃប្រព័ន្ធនេះ និងរួមបញ្ចូលរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នៅក្នុងដំណើរការនេះ។

### ភាពខុសគ្នានៃបញ្ហាប្រឈមនៃភាពក្រីក្ររ៉ាំរ៉ៃ និងភាពក្រីក្រតាមរដូវកាល អត្តសញ្ញាណកម្មគ្រួសារក្រីក្រកំពុងកែសម្រួលដើម្បីព្យាយាមឆ្លើយតបទៅភាពក្រីក្រតាមរដូវកាលនិងភាពក្រីក្ររ៉ាំរ៉ៃផងដែរ

ចរិតលក្ខណៈនៃភាពក្រីក្រនៅកម្ពុជា ត្រូវបានពិភាក្សាដោយអ្នកឯកទេសផ្នែកត្រួតពិនិត្យពិនិត្យទាក់ទងនឹងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ យោងតាមអ្នកឯកទេសម្នាក់ អត្តសញ្ញាណកម្មគ្រួសារក្រីក្រមានលទ្ធភាពកំណត់អត្តសញ្ញាណភាពក្រីក្ររ៉ាំរ៉ៃ ឬភាពក្រីក្រដែលមានលក្ខណៈជារចនាសម្ព័ន្ធ បានប្រសើរជាងភាពក្រីក្រតាមរដូវកាល ជាមួយនឹងការធ្វើបច្ចុប្បន្នភាពជារៀងរាល់បីឆ្នាំម្តង។ អ្នកឯកទេសត្រួតពិនិត្យម្នាក់ទៀតបានរកឃើញថា ការសិក្សាករណីនេះគ្របដណ្តប់បានយ៉ាងល្អនូវ ´ ចលនាជាញឹកញាប់នៃប្រជាជនមួយផ្នែកធំធ្លាក់ខ្លួនក្នុងភាពក្រីក្រ និងចាកផុតពីភាពក្រីក្រ´ ខណៈដែលឯកទេសត្រួតពិនិត្យទាំងពីរ បានទទួលស្គាល់ ថាការកែសម្រួលដំណើរការរបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីចាប់បាននូវភាពក្រីក្រតាមរដូវកាលនឹងមានផលប៉ះពាល់ចំពោះថ្លៃចំណាយ និងប្រព័ន្ធព័ត៌មានវិទ្យា ហើយនឹងតម្រូវឱ្យមានការយល់ដឹងបន្ថែមពីសហគមន៍ ដើម្បីឲ្យគ្រួសារក្រីក្រយល់អំពីនីតិវិធីថ្មី និងយល់អំពីសិទ្ធិរបស់ពួកគេ។

## សំណួរបន្ថែមដែលត្រូវតាមដាន និង វាយតម្លៃបន្ថែម

អ្នកត្រួតពិនិត្យបានលើកយោបល់ថា សំណួរមួយចំនួនដែលការវាយតំលៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្នុងពេលអនាគតអាចផ្តោតការយកចិត្តទុកដាក់ រួមមាន ៖ សុពលភាពនៃលទ្ធផលអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ដូចជា ការសិក្សាដែលបានគ្រោងដោយក្រសួងផែនការសម្រាប់ឆ្នាំ២០១៨) ថាតើមានភាពមិនប្រក្រតី ឬមានភាពខ្វះចន្លោះណាមួយនៅក្នុងដំណើរការឬទេ ដូចជាថា តើគ្រួសារទាំងអស់ទទួលបានប័ណ្ណសមធម៌បានទាន់ពេលវេលាដែរឬទេ ហើយតើកំហុសនៃការដាក់បញ្ចូល និងការផាត់ចេញត្រូវបានត្រួតពិនិត្យ និងតាមដាន និងតាមពិនិត្យបន្តយ៉ាងដូចម្តេច។

ជាចុងក្រោយ ដូចអ្នកត្រួតពិនិត្យម្នាក់បានសង្កេតឃើញថាមានទិន្នន័យជិត៨លាន „ កម្រងទិន្នន័យគ្រួសារក្រីក្រ គឺជាធនធានដ៏មានតម្លៃ យ៉ាងហោចណាស់សម្រាប់បង្កើតភ័ស្តុតាងមួយផ្នែកដែលចាំបាច់សម្រាប់គោលនយោបាយសង្គម និងកំណែទម្រង់ជាតិដែលមានភាពឈ្លាសវៃ និងមានប្រសិទ្ធភាព នោះគឺប្រជាសាស្រ្តនៃភាពក្រីក្រនៅកម្ពុជា។

# សេចក្តីថ្លែងអំណរគុណ

ក្រសួងសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសហព័ន្ធ (BMZ) សូមថ្លែងអំណរគុណដល់ក្រសួងផែនការកម្ពុជា ជាពិសេស កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (បច្ចុប្បន្នជានាយកដ្ឋាន) និងលោក កែវ អ៊ូលី ប្រធានកម្មវិធីនេះ ចំពោះកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាអស់រយៈពេលជាច្រើនឆ្នាំមក។ ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី បានផ្តល់ការគាំទ្រ និងផ្តល់ជំនួយជិតមួយទសវត្ស ដោយទទួលស្គាល់នូវតម្រូវការក្នុងការប្តេជ្ញាចិត្តរយៈពេលវែងដើម្បីបង្កើតកម្មវិធីមួយប្រកបដោយនិរន្តរភាព។

យើងសូមថ្លែងនូវកត្តញ្ញូតាធម៌ ចំពោះលោក លោកស្រីជាច្រើនរូបដែលបានរួមចំណែកចំពោះឯកសារបោះពុម្ពផ្សាយនេះ ជាពិសេសគឺលោក Ole Doetinchem លោកស្រី Sabine Cerceau និង លោក សោម ចាន់តារិទ្ធិ ទីប្រឹក្សាអង្គការ GIZ គម្រោងគាំទ្រដល់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក៏ដូចជាលោក ស កុសល លោក ម័ន្ត ច័ន្ទសារ៉ាក់ និង លោក ប៊ូ វណ្ណា មកពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្រសួងផែនការចំពោះការឧបត្ថម្ភគាំទ្រក្នុងអំឡុងពេលនៃការសរសេរករណីសិក្សានេះ។

បុគ្គលដទៃទៀតមកពីអង្គការដៃគូ និងក្រសួងនានាដែលបានចែករំលែកការយល់ឃើញរបស់ពួកគេចំពោះអត្តសញ្ញាណកម្មគ្រួសារក្រីក្រ រួមមាន លោកស្រីវេជ្ជបណ្ឌិត សុខ កញ្ញា (ក្រសួងសុខាភិបាល) ឯកឧត្តមបណ្ឌិត សាន វឌ្ឍនា (កបអក ) Tapley Jordanwood (URC) Maki Kato (UNICEF), Jonathan Rivers និង Francesca Erdelmann (កម្មវិធីស្បៀងអាហារពិភពលោក) អ្នកស្រី Benita Sommerville និងបណ្ឌិត Premprey Suos (DFAT), Birgit Stube (BMZ), Thomas Waldraff នាយក GIZ ប្រចាំប្រទេសកម្ពុជា និងទីប្រឹក្សា GIZ ផ្សេងទៀត។ លោក ឌឹម ជន (ប្រធានមន្ទីរផែនការខេត្តកំពង់ឆ្នាំង) និងអ្នកស្រី ភឿក ហឹង (ប្រធានក្រុមប្រឹក្សាឃុំខ្លងពពក) ជាបុគ្គលសំខាន់ក្នុងការស្វែងយល់ការអនុវត្ត និងផលប៉ះពាល់របស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅថ្នាក់ខេត្ត និងថ្នាក់ភូមិ។

Oliver Schell បានផ្តល់ជំនួយបកប្រែដ៏មានតម្លៃ និងបានផ្តល់ចំណេះដឹងស្តីពីសាវតាររបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងវិស័យសុខាភិបាលនៅកម្ពុជា។

លើសពីនេះ យើងសូមថ្លែងអំណរគុណចំពោះការរួមចំណែករបស់អតីតបុគ្គលិក GIZ ចំពោះការយល់ឃើញរបស់ពួកគេអំពីសាវតាររបស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រះ Anne Erpelding, Angelika Fleddermann (ដែលបន្តធ្វើការឱ្យ GIZ) Julian Hansen, Peter Kaufmann និង Jürgen Schilling ។

យើងក៏សូមថ្លែងកតញ្ញូតាធម៌ផងដែរចំពោះសាស្ត្រាចារ្យ Frank Bliss ដែលបានផ្តល់មតិលើសេចក្តីព្រាងនៃអត្ថបទនេះ។

ចំពោះការពិនិត្យឡើងវិញដ៏មានតម្លៃរបស់អ្នកពិនិត្យឯករាជ្យ យើងសូមថ្លែងអរគុណចំពោះលោកសាស្ត្រាចារ្យ Peter Annear ប្រធានផ្នែកអភិបាលកិច្ចប្រព័ន្ធសុខាភិបាល និងផ្នែកហិរញ្ញវត្ថុនៅវិទ្យាស្ថាន Nossal សម្រាប់សុខភាពសាកលនៅសាកលវិទ្យាល័យមែលប៊ន និងលោក Armando Barrientos សាស្ត្រាចារ្យភាពក្រីក្រ និងយុត្តិធម៌សង្គម នៅវិទ្យាស្ថានអភិវឌ្ឍន៍គោលនយោបាយ និងគ្រប់គ្រងនៅសាកលវិទ្យាល័យ Manchester ។

ករណីសិក្សានេះ ត្រូវបានស្រាវជ្រាវ និងរៀបរៀងដោយ Emily de Riel ។ ធាតុចូលដ៏មានតំលៃរបស់ Anna von Roenne អ្នកចាត់ការទូទៅនៃកម្រងសមូហកម្មស្តីពីកិច្ចបដិបត្តិផ្នែកសុខភាពអាល្លឺម៉ង់(German Health Practice Collection) ក្នុងដំណើរការបោះពុម្ពផ្សាយត្រូវបានទទួលស្គាល់ដោយកត្តញ្ញូតាធម៌។

# ឯកសារយោង

Alatas V, Banerjee A, Hanna R, Olken BA, Tobias J. (2012). Targeting the poor: evidence from a field experiment in Indonesia. *American Economic Review*, Vol 102, No 4, pp 1206-1240.

ASEAN Parliamentarians for Human Rights (2017). ASEAN MPs decry political parties bill as "death knell for democracy" in Cambodia. Statement 19 February 2017. Jakarta: ASEAN Parliamentarians for Human Rights.

Asia Pacific Observatory on Health Systems and Policies (2015). The Kingdom of Cambodia health system review. Health Systems in Transition, Vol. 5, No. 2. Manila: World Health Organization Regional Office for the Western Pacific, on behalf of the Asia Pacific Observatory on Health Systems and Policies.

Asian Development Bank (2012). Cambodia: Urban sector assessment, strategy, and roadmap. Mandaluyong City, Philippines: Asian Development Bank.

Asian Development Bank (2014). Cambodia Country Poverty Analysis. Mandaluyong City, Philippines: Asian Development Bank.

AusAID (2011). Targeting the poorest: An assessment of the proxy means test methodology. Canberra: Australian Agency for International Development.

Bigdeli M, Annear PL. (2009). Barriers to access and the purchasing function of health equity funds: lessons from Cambodia. *Bulletin of the World Health Organization*, Vol 87, No 7.

Cambodia Ministry of Planning (2012a). IDPoor Atlas: Identification of poor households: Cambodia. Results from data collection rounds 4 (2010) and 5 (2011). Phnom Penh.

Cambodia Ministry of Planning (2012b). *Implementation manual on the procedures for identification of poor households.* Phnom Penh.

Cambodia Ministry of Planning (2013). Poverty in Cambodia – a new approach: Redefining the poverty line. Phnom Penh.

Cambodia National Institute of Statistics, Directorate General for Health, ICF Macro (2011). Cambodia demographic and health survey, 2010. Phnom Penh and Calverton, Maryland: National Institute of Statistics, Directorate General for Health and ICF Macro.

Cambodia National Institute of Statistics, Directorate General for Health, ICF International (2014). Cambodia demographic and health survey, 2014. Phnom Penh and Rockville, Maryland: National Institute of Statistics, Directorate General for Health and ICF International.

Cambodia National Institute of Statistics, Ministry of Planning (2013). Cambodia inter-censal population survey 2013: Final report. Phnom Penh.

Conning J, Kevane M. (2002). Community-based targeting mechanisms for social safety nets: A critical review. *World Development*, Vol 30, No 3, pp 375-394.

Cruz M, Foster J, Quillen B, Schellekens P. (2015) Ending extreme poverty and sharing prosperity: Progress and policies. Policy Research Note. Washington, DC: World Bank Group.

Alatas V, Banerjee A, Hanna R, Olken BA, Tobias J. (2012). Targeting the poor: evidence from a field experiment in Indonesia. *American Economic Review*, Vol 102, No 4, pp 1206-1240.

ASEAN Parliamentarians for Human Rights (2017). ASEAN MPs decry political parties bill as "death knell for democracy" in Cambodia. Statement 19 February 2017. Jakarta: ASEAN Parliamentarians for Human Rights.

Asia Pacific Observatory on Health Systems and Policies (2015). The Kingdom of Cambodia health system review. Health Systems in Transition, Vol. 5, No. 2. Manila: World Health Organization Regional Office for the Western Pacific, on behalf of the Asia Pacific Observatory on Health Systems and Policies.

Asian Development Bank (2012). Cambodia: Urban sector assessment, strategy, and roadmap. Mandaluyong City, Philippines: Asian Development Bank.

Asian Development Bank (2014). Cambodia Country Poverty Analysis. Mandaluyong City, Philippines: Asian Development Bank.

AusAID (2011). Targeting the poorest: An assessment of the proxy means test methodology. Canberra: Australian Agency for International Development.

Bigdeli M, Annear PL. (2009). Barriers to access and the purchasing function of health equity funds: lessons from Cambodia. *Bulletin of the World Health Organization*, Vol 87, No 7.

Cambodia Ministry of Planning (2012a). IDPoor Atlas: Identification of poor households: Cambodia. Results from data collection rounds 4 (2010) and 5 (2011). Phnom Penh.

Cambodia Ministry of Planning (2012b). *Implementation manual on the procedures for identification of poor households.* Phnom Penh.

Cambodia Ministry of Planning (2013). Poverty in Cambodia – a new approach: Redefining the poverty line. Phnom Penh.

Cambodia National Institute of Statistics, Directorate General for Health, ICF Macro (2011). Cambodia demographic and health survey, 2010. Phnom Penh and Calverton, Maryland: National Institute of Statistics, Directorate General for Health and ICF Macro.

Cambodia National Institute of Statistics, Directorate General for Health, ICF International (2014). Cambodia demographic and health survey, 2014. Phnom Penh and Rockville, Maryland: National Institute of Statistics, Directorate General for Health and ICF International.

Cambodia National Institute of Statistics, Ministry of Planning (2013). Cambodia inter-censal population survey 2013: Final report. Phnom Penh.

Conning J, Kevane M. (2002). Community-based targeting mechanisms for social safety nets: A critical review. *World Development*, Vol 30, No 3, pp 375-394.

Cruz M, Foster J, Quillen B, Schellekens P. (2015) Ending extreme poverty and sharing prosperity: Progress and policies. Policy Research Note. Washington, DC: World Bank Group.

Food and Agriculture Organization of the United Nations (2017). FAO Rice Market Monitor, Vol 20, Issue 1.

Furuya J, Kobayashi S, Yamauchi K. (2014). Impacts of climate change on rice market and production capacity in the Lower Mekong Basin. *Paddy and Water Environment,* Vol 12, Suppl 2, pp 255-274.

Grosh, ME. (1994). *Administering targeted social programs in Latin America: From platitudes to practice.* World Bank Regional and Sectoral Studies. Washington, DC: World Bank.

Handa S, Huang C, Hypher N, et al. (2012). Targeting effectiveness of social cash transfer programs in three African countries. *Journal of Development Effectiveness*, Vol 4, No 1, pp 78-108.

Hickel J. (2016). The true extent of poverty and hunger: Questioning the good news narrative of the Millennium Development Goals. *Third World Quarterly*, Vol 37, No 5, pp 749-767.

Human Rights Watch (2017). Country summary: Cambodia. New York: Human Rights Watch.

Ir P, Bigdeli M, Meessen B, Van Damme W. (2010). Translating knowledge into policy and action to promote health equity: The Health Equity Fund policy process in Cambodia 2000-2008. *Health Policy*, Vol 96, pp 200-209.

Kelsall T, Heng S. (2014). The political economy of inclusive healthcare in Cambodia. Effective States and Inclusive Development Working Paper No. 43. Manchester: Effective States and Inclusive Development Research Centre, University of Manchester.

Lavallée E, Olivier A, Pasquier-Doumer L, Robilliard A-S. (2010). Poverty alleviation policy targeting: A review of experiences in developing countries. Paris: Institut pour le recherche pour le développement.

Leite P, George T, Sun C, Jones T, Lindert K. (2017). Social registries for social assistance and beyond: A guidance note and assessment tool. Social Protection and Labor Discussion Paper 1704. Washington, DC: World Bank Group.

McArthur J. (2014). The origins of the Millennium Development Goals. *SAIS Review*, Vol 34, No 2, pp 5-24.

Mendoza R. (2009). Aggregate shocks, poor households and children: Transmission channels and policy responses. *Global Social Policy,* Vol 9 (Suppl), pp 55-78.

Murotani R. (2014). Land problems in Cambodia: The historical influence of conflict. In: *Confronting land and property problems for peace.* Ed. S. Takeuchi. Milton Park and New York: Routledge. Pp 190.

National Institute of Statistics (2015). Cambodia Socio-Economic Survey 2014. Phnom Penh: Ministry of Planning.

Neef A, Touch S, Chiengthong J. (2013). The politics and ethics of land concessions in rural Cambodia. *Journal of Agricultural and Environmental Ethics*, Vol 26, pp 1085-1103.

OECD & Cambodia Development Resource Institute (2017). Interrelations between public policies, migration and development in Cambodia. OECD Development Pathways. Paris: OECD Publishing.

Oxford Poverty and Human Development Initiative (2015). Measuring multidimensional poverty: Insights from around the world. Oxford: Oxford Department of International Development.

Parsons L, Lawreniuk S, Pilgrim J. (2014). Wheels within wheels: Poverty, power and patronage in the Cambodian migration system. *Journal of Development Studies*, Vol 50, Issue 10, pp 1362-1379.

Phnom Penh Capital (2012). *The Phnom Penh urban poor assessment: A baseline survey on the social and economic situations and capacity of existing services in urban poor communities*. Phnom Penh.

Rattana E. (2013). Enforcement trends and compliance challenges in Cambodia. Presentation at the Fourth IMF-Japan High-Level Tax Conference for Asian Countries. Tokyo.

Reddy S, Pogge T. (2009). *How not to count the poor.* Initiative for Policy Dialogue Working Paper Series. New York: Initiative for Policy Dialogue.

Rigg J. (2013). From rural to urban: A geography of boundary crossing in Southeast Asia. *TRaNS: Trans-Regional and -National Studies of Southeast Asia*, Vol 1, No 1, pp 5-26.

Royal Government of Cambodia (2011). Sub-Decree on Identification of Poor Households: No. 291 ANKr. BK. Phnom Penh: Royal Government of Cambodia.

Royal Government of Cambodia (2013). “Rectangular strategy” for growth, employment, equity, and efficiency: Phase III. Phnom Penh: Royal Government of Cambodia.

Royal Government of Cambodia (2014). National strategic development plan 2014-2018. Phnom Penh: Royal Government of Cambodia.

### បោះផ្សាយដោយ
Deutsche Gesellschaft für
Internationale Zusammenarbeit (GIZ) GmbH

### ការិយាល័យដែលបានចុះបញ្ជី
Bonn and Eschborn
អាល្លឺម៉ង់

សារតារសង្ខេប - កម្មវិធីជំរុញការច្នៃបង្កើតថ្មី ការរៀនសូត្រ និងភស្តុតាង
ក្នុងកម្មវិធីអេដស៍ និងកម្មវិធីសុខភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់អាល្លឺម៉ង់

Friedrich-Ebert-Allee 36
53113 Bonn, Germany
Tel. +49 228 44 60 – 0
Fax +49 228 44 60 - 17 66

German Health Practice Collection
ghpc@giz.de
www.health.bmz.de/good-practices

### អ្នកនិពន្ធ
Emily deRiel

### រចនា និងសម្រាំង
Karsten van der Oord

### ប្រភពរូបថត
ទំព័រគ្របដណ្តប់ p. 3, p. 6, p. 7, p. 9, p. 13, p. 16, p. 17, p. 22, p. 24, p. 25, p. 26, p. 31, p. 33 © GIZ / Conor Wall

### កាលបរិច្ឆេទធ្វើ
ខែវិច្ឆិកា ឆ្នាំ2017

GIZ ទទួលខុសត្រូវលើខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ

ក្នុងនាម
ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហព័ន្ធ (BMZ);
ផ្នែកសុខភាព ប្រជាជន និងការគាំពារសង្គម